ក

មាតិកា

I_ខុទ្ទកាល័យព្រះមហាក្សត្រ

១_ព្រះរាជក្រម

២០-៧-២០០៧ -ព្រះរាជក្រម នស/រកម/០៧០៧/០១៧ ស្ដីពីការប្រកាសឱ្យប្រើ ច្បាប់ស្ដីពីគយ ៦១១៥

២_ព្រះរាជក្រឹត្យ

០១-៨-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៨០៧/៣២២ ស្ដីពីការតម្លើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ត្រី ជូនលោកវរសេនីយ៍ឯក **សួន ផល្លា** នាយនគរបាល ជាតិជាន់ខ្ពស់នៃក្រសួងមហាផ្ទៃ ៦១៦០

០១-៨-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៨០៧/៣២៣ ស្ដីពីការប្រោសព្រះរាជទានជាកិច្ចបច្ឆាមរណៈ ចំពោះសពឯកឧត្ដម ឧត្ដមសេនីយ៍ឯក **ពត សុខ** នូវគ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ៦១៦១

០១-៨-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៨០៧/៣២៤ ស្ដីពីការលុបឈ្មោះឯកឧត្ដម **នូច ភានុន** ឧត្ដមមន្ត្រី ថ្នាក់លេខ ៤ និងជាអគ្គលេខាធិការក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ចេញពីក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៃទីស្ដីការគណៈរដ្ឋមន្ត្រី ដោយមូលហេតុ ទទួលមរណភាព ៦១៦២

០១-៨-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៨០៧/៣២៥ ស្ដីពីរូបសញ្ញាអប់រំ យុវជន និងកីឡា សញ្ញាសក្តិ ឯកសណ្ឋាន និងសក្តិខ្វាស់លើអាវ ឬ ក្រមាពានា សម្រាប់មន្ត្រីអប់រំក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្ដម និងក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន ៦១៦៣

II_រាជរដ្ឋាភិបាល

អនុក្រឹត្យ

០១-៨-២០០៧ -អនុក្រឹត្យលេខ ៩១ អនក្រ.បក ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម ៦១៨២

០២-៨-២០០៧ -អនុក្រឹត្យលេខ ៩២ អនក្រ.បក ស្ដីពីការកែសំរួលមាត្រា៧ថ្មីជំពូកទី៥ នៃអនុក្រឹត្យលេខ ១០០ អនក្រ.បក ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ ២០០៥ និងការច្របាច់បញ្ចូលជំពូកទី ១០ និងទី ១១ នៃអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី ០៨ ខែសីហា ឆ្នាំ ២០០១ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពមីន និងសង្គ្រោះជនពិការដោយសារមីន ៦២០៣

០៣-៨-២០០៧ -អនុក្រឹត្យលេខ ៩៣ អនក្រ.បក ស្តីពីប្រតិទិនឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ ២០០៨ ៦២០៦

០៣-៨-២០០៧ -អនុក្រឹត្យលេខ ៩៤ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៦២០៨

៣០-៧-២០០៧ -អនុក្រឹត្យលេខ ៦២១ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៦២១០

៣០-៧-២០០៧ -អនុក្រឹត្យលេខ ៦២២ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៦២១៤

៣១-៧-២០០៧ -អនុក្រឹត្យលេខ ៦២៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦២១៦

៣១-៧-២០០៧ -អនុក្រឹត្យលេខ ៦២៤ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៦២១៧

៣១-៧-២០០៧ -អនុក្រឹត្យលេខ ៦២៥ អនក្រ.តត ស្តីពីការតែងតាំង ផ្ទេរសម្រួលភារកិច្ច និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៦២១៨

០១-៨-២០០៧ -អនុក្រឹត្យលេខ ៦២៦ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៦២២០

០១-៨-២០០៧ -អនុក្រឹត្យលេខ ៦២៧ អនក្រ.តត ស្តីពីការផ្ទេរក្របខ័ណ្ឌ នាយទាហាន ៦២២១

០១-៨-២០០៧ -អនុក្រឹត្យលេខ ៦២៨ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិ នាយអាវុធហត្ថ ៦២២២

០២-៨-២០០៧ -អនុក្រឹត្យលេខ ៦២៩ អនក្រ.តត ស្តីពីការសំរូល និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៦២២៣

០២-៨-២០០៧ -អនុក្រឹត្យលេខ ៦៣០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦២២៥

III. ការងារបណ្តាក្រសួង

១. ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាស

១២-៦-២០០៧ -ប្រកាសលេខ ៤៦៥ សបវ ស្តីពីការដាក់ឱ្យប្រើប្រាស់តារាងពន្ធគយកម្ពុជា ឆ្នាំ ២០០៧ (*ត មកពីរាជកិច្ច លេខ ៤៩...ដល់...៥៨*) ៦២២៦

២. ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

០៩-៨-២០០៧ -ប្រកាសលេខ ៨០៥ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ស្កាយ ហាយ (ខេមបូឌា) ខូ អិលធីឌី បង្កើតរោងចក្រ "ចាក់ និងកាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា " ស្កាយ ហាយ (ខេមបូឌា) ខូ អិលធីឌី " ៦២៥៦

៣. ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១៩-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៨៣៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សារិកា អ៊ែរ ស៊ីវិស អិលធីឌី** ៦២៥៨

២១-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៨៣៤ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ី.ខេ.យូ. ឌីវេឡុបមេន** ៦២៥៩

២២-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៨៣៦ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សៅ ផេង អ៊ីមផត អិចផត** ៦២៦១

២២-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៨៣៧ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន និង **សាខាក្រុមហ៊ុន ខូរៀន អ៊ែរឡាញ** ៦២៦៣

២២-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៨៤៣ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ធី ដាប់ប៊ែលយូ អិម** ៦២៦៤

២២-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៨៤៥ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **និមល គ្រុប អ៊ីន** ៦២៦៦

នស/រកម/០៧០៧/០១៧

ព្រះរាជក្រម

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីគយ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី ៦ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៣ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ច្បាប់

ស្តីពី

គយ

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

គោលបំណងនៃច្បាប់នេះគឺ :

-ផ្តល់សិទ្ធិគ្រប់គ្រង ត្រួតពិនិត្យ ប្រមូលពន្ធ អាករ និងកម្រៃផ្សេងៗលើទំនិញនាំចេញ ឬ នាំចូល

-ផ្តល់សិទ្ធិដាក់បទប្បញ្ញត្តិលើការធ្វើចរាចរ ការធ្វើសន្និធិ និងការដឹកជញ្ជូនឆ្លងកាត់នៃទំនិញនាំចេញ ឬ នាំចូល

-ជំរុញការបង្ការ និងបង្ក្រាបអំពើល្មើស និងអំពើរត់ពន្ធ

-ចូលរួមអនុវត្តគោលនយោបាយពាណិជ្ជកម្មអន្តរជាតិរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-ជំរុញនូវការអនុវត្តតាមស្តង់ដាអន្តរជាតិ និងការអនុវត្តល្អប្រសើរដែលពាក់ព័ន្ធទៅនឹងការត្រួតពិនិត្យគយ និងការសម្រួលពាណិជ្ជកម្ម ។

ទីចាត់ការគយ និងរដ្ឋាករជាស្ថាប័នទទួលខុសត្រូវក្នុងការគ្រប់គ្រង និងការអនុវត្តតាមបញ្ញត្តិនៃច្បាប់នេះ ។ ស្ថាប័ននេះស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

មាត្រា ២.-

ដែនគយមាន ដែនដី ដែនទឹក ដែនអាកាស និងកោះនានានៃព្រះរាជាណាចក្រកម្ពុជា ។ រាជរដ្ឋាភិបាលមានសិទ្ធិបង្កើតតំបន់រួចពន្ធនានា ដែលមិនស្ថិតនៅក្រោមការអនុវត្តទាំងស្រុង ឬ ភាគខ្លះនូវនីតិវិធីគយ ។

មាត្រា ៣.-

ច្បាប់នេះត្រូវអនុវត្ត :

-ដូចគ្នានៅក្នុងដែនគយទាំងមូល

-ស្មើភាពដោយឥតយោគយល់ចំពោះបុគ្គលណាឡើយ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

3/95

-ដោយពុំមានផ្តល់នូវអភ័យឯកសិទ្ធិ ឬ ឱ្យរួចផុតពីការអនុវត្តនៃច្បាប់នេះ ចំពោះទំនិញនាំចេញ និងនាំចូល ដោយក្នុងនាមរដ្ឋ ។

មាត្រា ៤.-

ប្រតិបត្តិការគយត្រូវប្រព្រឹត្តនៅក្នុងដែនគយទាំងមូល រាប់បញ្ចូលទាំងវង់អំណាចគយតាមបណ្តោយព្រំដែនគោក និងតំបន់ឆ្នេរ ក្រោមល័ក្ខខ័ណ្ឌដែលមានចែងនៅក្នុងច្បាប់នេះ ។

វង់អំណាចគយមានមណ្ឌលសមុទ្រ និងមណ្ឌលដីគោក :

ក-មណ្ឌលសមុទ្រមានព្រំដែនពីឆ្នេរទៅក្រៅចម្ងាយម្ភៃ (២០) គីឡូម៉ែត្រ ។

ខ-មណ្ឌលដីគោកលាតសន្ធឹង :

-ពីឆ្នេរសមុទ្រចូលមកក្នុងចម្ងាយម្ភៃ (២០) គីឡូម៉ែត្រ ព្រមទាំងដីចម្ងាយម្ភៃ (២០) គីឡូម៉ែត្រ ពីមាត់ទន្លេ មាត់ស្ទឹង មាត់ព្រែក ដែលហូរចាក់ទៅសមុទ្រមកទល់នឹងការិយាល័យគយនៅដើមគេបង្អស់ គិតពីសមុទ្រមក និងរង្វង់ម្ភៃ (២០) គីឡូម៉ែត្រជុំវិញការិយាល័យនេះ ។

-តាមព្រំដែនគោកចូលមកខាងក្នុងចម្ងាយម្ភៃ(២០) គីឡូម៉ែត្រ ។

ដើម្បីឱ្យងាយស្រួលដល់ការបង្ក្រាបបទល្មើស រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញប្រកាស :

ក-ពង្រីកជម្រៅមណ្ឌលដីគោករហូតដល់ហុកសិប (៦០) គីឡូម៉ែត្រ សម្រាប់ទីកន្លែង និងរយៈពេលកំណត់មួយ ។

ខ-កំណត់វង់អំណាចគយរហូតដល់បី (៣)គីឡូម៉ែត្រ ជុំវិញការិយាល័យគយដែលមិនស្ថិតក្នុងវង់អំណាចដូចមានចែងក្នុងកថាខណ្ឌទី ១ កថាខណ្ឌទី ២ និងវាក្យខណ្ឌ ក កថាខណ្ឌទី ៣ នៃមាត្រានេះ ។

ទោះបីជាមានបញ្ញត្តិដូចមានចែងនៅក្នុងកថាខណ្ឌទី ១ នៃមាត្រា នេះក៏ដោយរាជរដ្ឋាភិបាលអាចចេញអនុក្រឹត្យ :

ក-ចាត់តាំងឱ្យមន្ត្រីគយអនុវត្តការងាររបស់ខ្លួន ដូចមានចែងនៅក្នុងច្បាប់នេះ នៅក្រៅដែនគយ ដោយឈរលើមូលដ្ឋានបដិការ និង អនុលោមតាមកិច្ចព្រមព្រៀង

អន្តរជាតិ សន្ធិសញ្ញា ឬ អនុសញ្ញាដែលព្រះរាជាណាចក្រកម្ពុជា បានចូលរួម ។

ខ-អនុញ្ញាតឱ្យមន្ត្រីគយនៃប្រទេសដទៃអនុវត្តការងាររបស់ខ្លួន ដូចមានចែង នៅក្នុងច្បាប់របស់ប្រទេសទាំងនោះ ដែលពាក់ព័ន្ធទៅនឹងការនាំចូល និងនាំចេញទំនិញ នៅក្នុងដែនគយ ដោយឈរលើមូលដ្ឋានបដិការ និង អនុលោមតាមកិច្ចព្រមព្រៀងអន្តរ-ជាតិ សន្ធិសញ្ញា ឬ អនុសញ្ញាដែលព្រះរាជាណាចក្រកម្ពុជា បានចូលរួម ។

ទម្រង់ការគយអាចនឹងបំពេញបានតែក្នុងការិយាល័យគយ លើកលែងតែមានការ កំណត់ដោយឡែក ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កំណត់ការបង្កើត កិច្ចដំណើរការ និងការលុបចោលការិយាល័យគយ ។

ពេលម៉ោងធ្វើការរបស់ការិយាល័យគយ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ នាយកទីចាត់ការគយ និងរដ្ឋាករ ។ សេចក្តីសម្រេចនេះត្រូវបិទផ្សាយនៅតាមការិយាល័យ គយនីមួយៗ ។

មាត្រា ៥.-

ទំនិញនាំចេញ ឬនាំចូលទាំងអស់ គឺជាកម្មវត្ថុនៃការអនុវត្តតាមបញ្ញត្តិនៃច្បាប់នេះ ។

ទំនិញទាំងឡាយដែលចូលមកក្នុង ឬ ចេញពីដែនគយ ត្រូវជាប់ពន្ធនាំចូល ឬ នាំចេញ និងអាករ ដូចមានចែងក្នុងតារាងពន្ធគយ ។ បែបបទស្តីពីការរៀបចំ និងការអនុវត្ត តារាងពន្ធគយត្រូវចែងលំអិតនៅក្នុងអនុក្រឹត្យ ។

ក្នុងករណីមានពាក់ព័ន្ធនឹងផលប្រយោជន៍ជាតិ រាប់បញ្ចូលទាំងករណីមានភាពអាសន្ន រាជរដ្ឋាភិបាលអាចចេញបញ្ជាឱ្យផ្អាកទាំងស្រុង ឬភាគខ្លះនូវពន្ធ និងអាករលើទំនិញសម្រាប់ ជាតម្រូវការរបស់ប្រជាពលរដ្ឋ ឬ ផ្អាកការនាំចេញ ឬ ការនាំចូលនូវទំនិញប្រភេទខ្លះ ។

មាត្រា ៦.-

ពន្ធគយអនុគ្រោះអាចផ្តល់ជូនបាន ប្រសិនបើមានចែងក្នុងការសន្យា កិច្ចព្រមព្រៀង សន្ធិសញ្ញា ឬ អនុសញ្ញាអន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជា បានចូលរួម ។ ពន្ធគយ អនុគ្រោះដែលចេញមកពីកាតព្វកិច្ចក្រោមការសន្យា កិច្ចព្រមព្រៀង សន្ធិសញ្ញា ឬ អនុ-សញ្ញាអន្តរជាតិទាំងនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

៧/៤៥

មាត្រា ៧.–

រាជរដ្ឋាភិបាលអាចកំណត់បានដោយអនុក្រឹត្យចាត់វិធានការចាំបាច់នានារាប់បញ្ចូលទាំងការដំឡើងអត្រាពន្ធ ដើម្បីការពារផលិតករកម្ពុជា នៅពេលដែលផលិតករក្នុងស្រុកត្រូវទទួលរងគ្រោះដោយកំណើននៃការនាំចូល ឬ ដោយឧបត្ថម្ភធនដែលបានផ្តល់ដោយរដ្ឋាភិបាលនៃប្រទេសផ្សេងទៀត ចំពោះការនាំចេញផលិតផលរបស់ខ្លួនមកកម្ពុជា ឬ ដោយការលក់បង្ខូចថ្លៃទំនិញនៅលើទីផ្សារកម្ពុជា ។

មាត្រា ៨.–

រាជរដ្ឋាភិបាលអាចកំណត់បានដោយអនុក្រឹត្យនូវមុខទំនិញមួយចំនួនឱ្យជាប់អាជ្ញាប័ណ្ណ ឬ កម្រិតកំណត់ក្រោមល័ក្ខខ័ណ្ឌលើការនាំចេញ ឬ នាំចូលក្នុងគោលបំណងណាមួយដូចតទៅ :

-សន្តិសុខជាតិ

-សណ្តាប់ធ្នាប់សាធារណៈ និងតាមស្តង់ដានៃសុភាវធម៌ និង សីលធម៌

-ការការពារសុខភាព និង ជីវិតមនុស្ស សត្វ ឬ រុក្ខជាតិ

-ការការពារបេតិកភណ្ឌជាតិ ដែលមានតម្លៃខាងសិល្បៈ ប្រវត្តិសាស្ត្រ ឬ បុរាណវត្ថុវិទ្យា

-ការអភិរក្សធនធានធម្មជាតិ

-ការតម្រូវតាមបញ្ញត្តិនានានៃច្បាប់ណាមួយជាធរមាននៃព្រះរាជាណាចក្រកម្ពុជា

-ការបំពេញកាតព្វកិច្ចក្រោមធម្មនុញ្ញសហប្រជាជាតិ ។

ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើល្មើសនិងអំពើរត់ពន្ធ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអាចចេញប្រកាសកំណត់នូវមុខទំនិញមានវេទយិតភាព ឬ ទំនិញដែលជាប់ពន្ធខ្ពស់ជាទំនិញកំណត់ពិសេស សម្រាប់គោលបំណងនៃច្បាប់នេះ ហើយអាចកំណត់បន្ថែមលើការត្រួតពិនិត្យ និងការដាក់កម្រិតបានលើការដឹកជញ្ជូន ចរាចរ សន្និធិ និងការកាន់រក្សាទំនិញទាំងនេះ ។

មាត្រា ៩.-

លើកលែងតែបរិបទតម្រូវផ្សេងពីនេះ សម្រាប់គោលបំណងនៃច្បាប់នេះ :

- **ពន្ធគិតតាមតម្លៃ “Ad Valorem duty”** គឺជាពន្ធដែលគណនាដោយផ្អែកលើមូលដ្ឋាននៃតម្លៃគិតពន្ធគយ ។

- **ពន្ធគិតតាមឯកតា** គឺជាពន្ធដែលគណនាផ្អែកតាមឯកតា ទម្ងន់ ចំណុះ ឬ បរិមាណនៃទំនិញ ។

- **គណ្ឋាគារគយមានដែនកំណត់** គឺជាអគារ ទីកន្លែង ឬ ទីលានណាមួយដែលបំពេញគ្រប់ល័ក្ខខ័ណ្ឌ ដែលកំណត់ដោយរដ្ឋបាលគយ សម្រាប់បម្រើដល់ការធ្វើសន្និធិ ការកែច្នៃ ការតាំងបង្ហាញសម្រាប់លក់ ឬ សម្រាប់គោលបំណងពាក់ព័ន្ធផ្សេងទៀត ដែលទំនិញត្រូវព្យួរពន្ធ និងអាករ ជាបណ្តោះអាសន្ន ។

- **មធ្យោបាយដឹកជញ្ជូន** គឺជាជលយាន អាកាសយាន ឬ មធ្យោបាយផ្សេងទៀតដែលប្រើប្រាស់សម្រាប់ដឹកជញ្ជូនមនុស្ស ឬ ទំនិញ ។

- **ការគេចពន្ធ** គឺជាការនាំចេញ ឬ នាំចូលទំនិញនៅក្រៅការិយាល័យគយព្រមទាំងការបំពានលើបញ្ញត្តិច្បាប់ ឬ បទបញ្ញាដែលទាក់ទងដល់ការនាំចេញ ឬ នាំចូល ការកាន់កាប់ និងការដឹកជញ្ជូនទំនិញនៅក្នុងផ្ទៃនៃដែនគយ ។

- **ប្រទេសដើមកំណើត** គឺជាប្រទេសដែលទំនិញត្រូវបានផលិត ឬ កែច្នៃស្របតាមលក្ខណៈវិនិច្ឆ័យ ដែលមានចែងសម្រាប់ជាគោលបំណងនៃការប្រើប្រាស់តារាងពន្ធគយ ស្របតាមការកម្រិតកំណត់លើបរិមាណ ឬ ករណីផ្សេងទៀតដែលពាក់ព័ន្ធនឹងវិស័យពាណិជ្ជកម្ម ។

- **គយ ឬ រដ្ឋបាលគយ** គឺសំដៅលើទីចាត់ការគយ និងរដ្ឋាករនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយរាប់បញ្ចូលមន្ត្រីគយដែលទទួលខុសត្រូវក្នុងការគ្រប់គ្រងត្រួតពិនិត្យការអនុវត្តច្បាប់គយ ការប្រមូលពន្ធ អាករ និងកម្រៃផ្សេងៗ ព្រមទាំងទទួលខុសត្រូវផងដែរក្នុងការអនុវត្តច្បាប់ និង បទប្បញ្ញត្តិផ្សេងទៀត ដែលទាក់ទងនឹងការនាំចេញ ឬ នាំចូល ប្រតិបត្តិការ និង សន្និធិទំនិញ ។

ជើងសារគយ គឺជាបុគ្គលដែលបានទទួលការអនុញ្ញាតតាមផ្លូវច្បាប់ ដើម្បីធ្វើ

7/45

អាជីវកម្មបំពេញបែបបទបញ្ចេញទំនិញពីគយ ដោយផ្ទាល់ជាមួយរដ្ឋបាលគយ ក្នុងនាមបុគ្គលផ្សេងទៀត ។

-**ការបំពេញបែបបទបញ្ចេញទំនិញពីគយ** គឺជាការបំពេញនូវទម្រង់ការគយចាំបាច់នានា ដើម្បីទទួលបានការអនុញ្ញាតឱ្យទំនិញអាចដាក់ឱ្យប្រើប្រាស់បានក្នុងប្រទេស អាចឱ្យនាំចេញ ឬ ដាក់ក្រោមរបបគយមួយផ្សេងទៀតបាន ។

-**កន្លែងបំពេញបែបបទបញ្ចេញទំនិញពីគយ** គឺជាកន្លែងដែលស្ថិតនៅក្រោមការគ្រប់គ្រង ការឃ្លាំមើលដោយរដ្ឋបាលគយ ។

-**ការត្រួតពិនិត្យគយ** គឺជានីតិវិធីដែលកំណត់ដោយរដ្ឋបាលគយលើការដឹកជញ្ជូន ចរាចរ និងសន្និធិទំនិញនាំចេញ ឬ នាំចូល ។

-**ប្រតិវេទន៍គយ** គឺជាសេចក្តីប្រកាសដែលធ្វើឡើង សម្រាប់គោលបំណងនៃការនាំចេញ ឬ នាំចូល តាមទម្រង់ និងរបៀបដូចមានចែងក្នុងច្បាប់នេះ ។

- **ការពិនិត្យឆែកឆេររបស់គយ** គឺជាការធ្វើអធិការកិច្ចជារូបវ័ន្តលើទំនិញ ឬ ឯកសារដោយរដ្ឋបាលគយ ដើម្បីបញ្ជាក់ថាប្រភេទ ដើមកំណើត ល័ក្ខខ័ណ្ឌ បរិមាណ និងតម្លៃទំនិញ សមស្របតាមការប្រកាសនៅក្នុងប្រតិវេទន៍គយ ។

- **ទម្រង់ការគយ** គឺជាប្រតិបត្តិការដែលត្រូវអនុវត្តដោយបុគ្គលពាក់ព័ន្ធ និងដោយរដ្ឋបាលគយក្នុងគោលបំណងគោរពតាមច្បាប់នេះ និងច្បាប់ផ្សេងទៀតដែលរដ្ឋបាលគយមានភារៈចាត់ចែងគ្រប់គ្រង និងអនុវត្ត ។

-**គណ្ឌាគារផលិតកម្មមានដែនកំណត់ស្ថិតក្រោមការគ្រប់គ្រងរបស់គយ** គឺជារោងចក្រដែលស្ថិតក្រោមការត្រួតពិនិត្យរបស់គយ លើទំនិញនាំចូលដោយលើកលែងជាបណ្តោះអាសន្ននូវពន្ធ និងអាករនានា សម្រាប់ប្រើប្រាស់ក្នុងដំណើរការផលិតកម្ម ។

- **ការិយាល័យគយ** គឺជាអង្គភាពរដ្ឋបាលគយដែលមានសមត្ថកិច្ចគ្រប់គ្រងត្រួតពិនិត្យ ទម្រង់ការគយ អគារ ឬ ទីតាំងផ្សេងទៀតដែលទទួលការអនុញ្ញាតសម្រាប់គោលបំណងនៃបទប្បញ្ញត្តិច្បាប់នេះ ។

- **មន្ត្រីគយ** គឺជាជនដែលបានទទួលសិទ្ធិក្នុងការចាត់ចែង គ្រប់គ្រង និងអនុវត្ត

- **តម្លៃគិតពន្ធគយ ឬ តម្លៃ** ពាក់ព័ន្ធទៅនឹងទំនិញនាំចូល គឺជាតម្លៃគិតពន្ធគយនៃទំនិញទាំងនោះដែលត្រូវបានកំណត់ស្របតាមមាត្រា ២១ នៃច្បាប់នេះ ។

- **ប្រតិវេទនករ** គឺជាបុគ្គលដែលធ្វើការប្រកាសដល់គយក្នុងនាមខ្លួនផ្ទាល់ ឬ ក្នុងនាមអ្នកដទៃ ។

- **ឯកសារ** គឺជាឯកសារតាមទម្រង់ណាមួយ ទោះជាមាន ឬ គ្មានចុះហត្ថលេខា ឬ ចុះអាទិសង្កេត ឬធ្វើយថាភូតដោយអ្នកតាក់តែង និងរាប់បញ្ចូលទាំង :

-ទម្រង់ណាមួយដែលសរសេរលើសម្ភារៈ

-ព័ត៌មានថតទុក បញ្ជូន ឬ រក្សាទុកដោយមធ្យោបាយនានា ដូចជា : ឧបករណ៍ថត កុំព្យូទ័រ ឬឧបករណ៍ផ្សេងទៀត និងសម្ភារៈដែលយកចេញពីព័ត៌មានទាំងនេះ ។

-ស្លាក ឬ សញ្ញាសម្គាល់ផ្សេងទៀត ឬ ការសរសេរដែលភ្ជាប់នឹងវត្ថុអ្វីមួយ ឬ សម្ភារៈជាភាគណាមួយនៃវត្ថុនោះ ។

-សៀវភៅ ផែនទី ប្លង់ ក្រាហ្វ ឬ គំនូរ

-រូបថត ហ្វីល ខ្សែអាត់ ឬឧបករណ៍ផ្សេងទៀតដែលផ្ទុកនូវរូបភាព ហើយមានលទ្ធភាពអាចធ្វើការផ្តិតចម្លងបាន ។

- **ពន្ធ** គឺជាពន្ធ ពន្ធបន្ថែម អាករ កម្រៃ ឬ បន្ទុកផ្សេងទៀតដែលយកលើទំនិញស្របតាមបញ្ញត្តិណាមួយនៃច្បាប់នេះ ឬ ច្បាប់ និងបទប្បញ្ញត្តិផ្សេងទៀតដែលអនុវត្ត និងគ្រប់គ្រងដោយគយ ។

- **តំបន់រួចពន្ធ** គឺជាតំបន់បង្កើតឡើងដោយរាជរដ្ឋាភិបាល ដែលទំនិញនាំចូលពុំមែនជាកម្មវត្ថុនៃការជាប់ពន្ធ និងអាករក្រោមល័ក្ខខ័ណ្ឌកំណត់ច្បាស់លាស់ ។

- **ទំនិញ** គឺជាចលនទ្រព្យទាំងឡាយ ។

- **ការដាក់ឱ្យប្រើប្រាស់ក្នុងប្រទេស** គឺជាការចរាចរទំនិញនាំចូលដោយសេរីក្នុងរង្វង់ដែនគយ បន្ទាប់ពីបានបញ្ចេញទំនិញពីគយ ។

- **អ្នកនាំចូល** គឺជាបុគ្គលដែលនាំចូលទំនិញដោយខ្លួនឯង ឬ ដោយអ្នកដទៃ ។ ត្រូវចាត់ជាអ្នកនាំចូលផងដែរនូវអ្នកទទួលទំនិញ បុគ្គលដែលជាម្ចាស់កម្មសិទ្ធិ បុគ្គលដែលនឹងក្លាយជាម្ចាស់កម្មសិទ្ធិ ឬ អ្នកមានសិទ្ធិចាត់ចែងលើកម្មសិទ្ធិទំនិញទាំងនោះ មុនពេលដែលទំនិញនោះឈប់ជាកម្មវត្ថុនៃការត្រួតពិនិត្យគយ ។

9/45

- **ការនាំចូល** ពាក់ព័ន្ធទៅនឹងទំនិញ គឺជាការមកដល់ដែនគយនូវទំនិញតាមរបៀបណាក៏ដោយ ទោះជាស្របច្បាប់ ឬមិនស្របច្បាប់ពីចំណុច ឬទីកន្លែងនៅក្រៅដែនគយ ។

- **ការអនុញ្ញាតឱ្យយកចេញ** គឺជាការអនុញ្ញាតរបស់គយឱ្យយកទំនិញដែលបានបំពេញបែបបទគយរួចចេញពីការគ្រប់គ្រងរបស់គយដល់បុគ្គលពាក់ព័ន្ធ ។

- **និមុត្តិធានា** គឺជាការធានាផ្នែកហិរញ្ញវត្ថុ ឬ លិខិតុបករណ៍ហិរញ្ញវត្ថុផ្សេងទៀត ដែលប្រើប្រាស់សម្រាប់ធានាក្នុងការទូទាត់បង់ពន្ធ អាករ និងកម្រៃផ្សេងទៀតជាយថាហេតុតាមបញ្ញត្តិនៃច្បាប់នេះ ។

- **ទំនិញកំណត់ពិសេស** គឺជាទំនិញទាំងឡាយដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមកថាខណ្ឌទី ២ ក្នុងមាត្រា ៨ នៃច្បាប់នេះ ។

- **តម្រាយផ្លូវស្របច្បាប់** គឺជាផ្លូវគោក ផ្លូវដែក ផ្លូវទឹក និងផ្លូវផ្សេងទៀតណាមួយដែលគយកំណត់ឱ្យប្រើប្រាស់ សម្រាប់ការដឹកជញ្ជូនទំនិញនាំចេញ ឬ នាំចូលក្រោមការគ្រប់គ្រង និងត្រួតពិនិត្យរបស់គយ ។

- **ប្រទេសន៍កាលិក** គឺជានីតិវិធីគយ ដែលអាចអនុញ្ញាតឱ្យទំនិញនាំចូលបានក្នុងដែនគយក្រោមល័ក្ខខ័ណ្ឌរួចផុតពីការបង់ពន្ធ និងអាករទាំងស្រុង ឬ ភាគខ្លះ ។ ទំនិញទាំងនោះត្រូវបាននាំចូលក្នុងគោលបំណងច្បាស់លាស់ ហើយត្រូវនាំចេញទៅវិញក្នុងកម្រិតពេលវេលាជាក់លាក់មួយ និងមិនធ្វើការ កែច្នៃ ឬ ផ្លាស់ប្តូរ លើកលែងតែការរិលរស់ធម្មតាតាមការប្រើប្រាស់ ។

- **ការឆ្លងកាត់** គឺជានីតិវិធីគយ ដែលអនុញ្ញាតឱ្យដឹកជញ្ជូនទំនិញពីការិយាល័យគយមួយទៅការិយាល័យគយមួយទៀត ក្រោមការត្រួតពិនិត្យរបស់គយ ។

- **ការផ្ទេរមធ្យោបាយដឹកជញ្ជូន** គឺជានីតិវិធីគយ ដែលអនុញ្ញាតឱ្យផ្ទេរទំនិញពីមធ្យោបាយដឹកជញ្ជូននាំចូល ទៅមធ្យោបាយដឹកជញ្ជូននាំចេញ ក្រោមការត្រួតពិនិត្យរបស់គយនៅក្នុងរង្វង់ការិយាល័យគយតែមួយ ដែលជាការិយាល័យនៃការនាំចូល និងការនាំ

- **ការដឹកជញ្ជូនត្រង់** គឺជាការដឹកជញ្ជូនជាអន្តរជាតិនូវទំនិញពីប្រទេសដើម

កំណើតទំនិញនោះទៅប្រទេសនាំចូល ដោយមិនមានការឆ្លងកាត់ប្រទេសដទៃ ក្រៅពីប្រទេសដើមកំណើតទំនិញ និងប្រទេសគម្យដ្ឋាន លើកលែងតែការឆ្លងកាត់នេះត្រូវបានធ្វើដោយសារលក្ខណៈភូមិសាស្ត្រ ឬ ចលនូបត្ថម្ភ ហើយទំនិញទាំងនោះមិនស្ថិតនៅក្នុងពាណិជ្ជកម្ម ឬការប្រើប្រាស់ និងមិនត្រូវរងនូវប្រតិបត្តិការណាមួយក្រៅពីការលើកដាក់ ឬ ប្រតិបត្តិការដើម្បីថែរក្សាទំនិញទាំងនោះឱ្យបានប្រសើរនៅប្រទេសដែលបានឆ្លងកាត់នោះ ។

- **បុគ្គល** គឺជារូបវន្តបុគ្គល ឬ នីតិបុគ្គល ។

ជំពូកទី ២

ការនាំចូល និងការនាំចេញ

ផ្នែកទី ១

ការនាំចូល

មាត្រា ១០.-

ទំនិញនាំចូលទាំងអស់ត្រូវបានរាយការណ៍នៅការិយាល័យគយ ឬ ទីកន្លែងផ្សេងទៀតទៅតាមការកំណត់របស់នាយកទីចាត់ការគយ និងរដ្ឋាករ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវចេញប្រកាសកំណត់ពេលវេលា របៀបរបប តម្រូវការ ឯកសារ កាលៈទេសៈ និងការលើកលែងនានាពាក់ព័ន្ធនឹងការរាយការណ៍ពីទំនិញនាំចូល ។

មាត្រា ១១.-

ទំនិញនាំចូលទាំងអស់ត្រូវបានរាយការណ៍នៅការិយាល័យគយដែលជិតបំផុតតាមតម្រាយផ្លូវស្របច្បាប់ :

ក-ក្នុងករណីទំនិញដែលកាន់រក្សាដោយជនណាម្នាក់ ដែលបានមកដល់កម្ពុជា ឬ ជាផ្នែកនៃអីវ៉ាន់ផ្ទាល់ខ្លួន ត្រូវរាយការណ៍ដោយជននោះ ។

ខ-ក្នុងករណីទំនិញដែលបាននាំចូលដោយសេវាកម្មបញ្ញើ ឬ តាមរយៈបញ្ញើប្រៃសណីយ៍ ត្រូវរាយការណ៍ដោយបុគ្គលដែលបាននាំចេញទំនិញនោះមកកម្ពុជា ។

គ-ក្នុងករណីទំនិញដែលនាំចូលផ្សេងពីវាក្យខណ្ឌ ក និងវាក្យខណ្ឌ ខ ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ដែលបានផ្ទុកនៅលើមធ្យោបាយដឹកជញ្ជូនរាប់បញ្ចូលទាំងមធ្យោបាយដឹកជញ្ជូនយោធាដែលមកដល់កម្ពុជា ត្រូវរាយការណ៍ដោយជនទទួលខុសត្រូវមធ្យោបាយដឹកជញ្ជូនទាំងនោះ ។

ឃ- ក្នុងករណីទំនិញដែលនាំចូលតាមបែបផ្សេងទៀតត្រូវរាយការណ៍ដោយបុគ្គលដែលធ្វើក្នុងនាមអ្នកនាំចូល ។

បុគ្គលគ្រប់រូបដែលរាយការណ៍ពីទំនិញ ក្រោមបញ្ញត្តិនៃមាត្រានេះត្រូវ :

ក-ឆ្លើយនូវការពិត ចំពោះរាល់សំណួរដែលសួរដោយមន្ត្រីគយពាក់ព័ន្ធនឹងទំនិញរបស់ខ្លួន ។

ខ- បង្ហាញនូវទំនិញទាំងឡាយ តាមរបៀបដែលកំណត់ដោយនាយកទីចាត់ការគយ និងរដ្ឋាករសម្រាប់ធ្វើអធិការកិច្ចនៅពេលដែលមន្ត្រីគយតម្រូវ ។

មាត្រា ១២.-

គ្មានជនណាម្នាក់អាចរើទំនិញចេញពីមធ្យោបាយដឹកជញ្ជូនពេលមកដល់កម្ពុជាបានទេ មុនពេលដែលទំនិញទាំងនេះ ត្រូវបានរាយការណ៍ដល់គយស្របតាមច្បាប់នេះ លើកលែងតែក្នុងករណីដែលសុវត្ថិភាពមធ្យោបាយដឹកជញ្ជូនទំនិញ ជននានាលើមធ្យោបាយដឹកជញ្ជូន ឬ តតិយជនផ្សេងទៀតត្រូវបានគំរាមកំហែងក្នុងល័ក្ខខ័ណ្ឌមានអាសន្ន ដូចមានចែងក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ១៣.-

រដ្ឋបាលគយអាចអនុញ្ញាតឱ្យទំនិញដូចមានចែងក្នុងមាត្រា ១០ នៃច្បាប់នេះយកចេញបានពីកន្លែងបំពេញបែបបទបញ្ចេញទំនិញពីគយ មុនពេលបង់ពន្ធ អាករ និងកម្រៃនានាបន្ទាប់ពីបានបំពេញទម្រង់ការគយរួច និងនៅក្រោមការត្រួតពិនិត្យគយក្នុងគោល

-ធ្វើសន្និធិគយបណ្តោះអាសន្ន

-ធ្វើសន្និធិគយមានដែនកំណត់

-ដឹកជញ្ជូនបន្តក្នុងរង្វង់ ឬ កាត់តាមដែនគយ ឆ្ពោះទៅគម្យដ្ឋានមួយតាមតម្រោយផ្លូវស្របច្បាប់ និងក្នុងរយៈពេលកំណត់ដោយគយរួមមាន ការឆ្លងកាត់ ការផ្ទេរមធ្យោបាយដឹកជញ្ជូន ឬ ការដឹកជញ្ជូនឆ្ពោះទៅកាន់មកពី ឬ រវាងការិយាល័យគយ និងភណ្ឌាគារគយនានា ។

មាត្រា ១៤.-

ទំនិញដូចមានចែងក្នុងមាត្រា ១០ នៃច្បាប់នេះ អាចត្រូវបានអនុញ្ញាតដោយរដ្ឋបាលគយឱ្យយកចេញ បន្ទាប់ពីបានបំពេញទម្រង់ការគយរួច ដោយរាប់បញ្ចូលទាំងការបង់ពន្ធអាករ ឬ កម្រៃផ្សេងៗ និងការតម្កល់និមុត្តិធានាចំពោះទំនិញដើម្បី :

-នាំចូលសម្រាប់ការប្រើប្រាស់ក្នុងប្រទេស

-នាំចូលបណ្តោះអាសន្ន

-ប្រើប្រាស់ក្រោមល័ក្ខខ័ណ្ឌលួរពន្ធ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវចេញប្រកាសកំណត់ល័ក្ខខ័ណ្ឌនានាចំពោះទំនិញដែលអាចត្រូវបានអនុញ្ញាតឱ្យយកចេញ មុនពេលបង់ពន្ធ អាករ និងកម្រៃផ្សេងៗ ។

មាត្រា ១៥.-

ទំនិញនាំចូលទាំងឡាយ អាចទទួលបានការអនុញ្ញាតដោយរដ្ឋបាលគយឱ្យយកចេញតាមរបបប្រវេសន៍កាលិកបាន ប្រសិនបើក្នុងពេលនាំចូលអាចត្រូវបានបង្ហាញថាទំនិញទាំងនោះនឹងត្រូវនាំចេញទៅវិញ ។

ទំនិញនាំចូលបណ្តោះអាសន្ន ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យគយ រហូតដល់ពេលដែលល័ក្ខខ័ណ្ឌផ្សេងៗតាមរបបប្រវេសន៍កាលិកត្រូវបានបំពេញរួចរាល់ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញប្រកាសកំណត់បញ្ញត្តិនានាសម្រាប់គ្រប់គ្រងទំនិញនាំចូលក្រោមរបបប្រវេសន៍កាលិកទាំងនេះ រួមមានការកំណត់រយៈពេលកម្រៃនានា ការត្រួតពិនិត្យ និងការដាក់កម្រិតកំណត់ផ្សេងទៀត ។

ROYAUME DU CAMBODGE LE IMPRIMERIE DU PALAIS ROYAL

ផ្នែកទី ២
ការនាំចេញ

មាត្រា ១៦.-

ទំនិញគ្រប់ប្រភេទដែលនាំចេញត្រូវរាយការណ៍នៅការិយាល័យគយ ឬ ទីកន្លែងណាមួយតាមការកំណត់របស់នាយកទីចាត់ការគយ និងរដ្ឋាករ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញប្រកាសកំណត់ពេលវេលា របៀបរបប តម្រូវការ ឯកសារ កាលៈទេសៈ និងការលើកលែងមួយចំនួនពាក់ព័ន្ធនឹងការរាយការណ៍ ចរាចរ សន្និធិនិងការដឹកជញ្ជូនទំនិញទាំងឡាយដែលត្រូវនាំចេញ ។

បុគ្គលគ្រប់រូបដែលរាយការណ៍ពីទំនិញ ក្រោមបញ្ញត្តិនៃមាត្រានេះ ត្រូវ:

ក-ឆ្លើយនូវការពិតចំពោះរាល់សំណួរដែលសួរដោយមន្ត្រីគយ ពាក់ព័ន្ធនឹងទំនិញរបស់ខ្លួន ។

ខ-បង្ហាញនូវទំនិញទាំងឡាយ តាមរបៀបដែលកំណត់ដោយនាយកទីចាត់ការគយ និងរដ្ឋាករ សម្រាប់ធ្វើអធិការកិច្ចនៅពេលដែលមន្ត្រីគយតម្រូវ ។

មាត្រា ១៧.-

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញប្រកាសកំណត់ល័ក្ខខ័ណ្ឌនានាដែលរដ្ឋបាលគយអាចអនុញ្ញាតឱ្យធ្វើការនាំចេញបណ្ដោះអាសន្ននូវទំនិញទៅក្រៅដែនគយដើម្បីជួសជុល បំប្លែង ឬ ទទួលពលកម្មបន្ថែម ព្រមទាំងបែបបទដែលទំនិញទាំងនោះត្រូវជាប់ពន្ធ និងអាករនាពេលនាំចូលត្រឡប់មកវិញ ។

ជំពូកទី ៣
ចំណាត់ថ្នាក់តាមតារាង ដើមកំណើត និង តម្លៃគិតពន្ធគយ

មាត្រា ១៨.-

ចំណាត់ថ្នាក់តាមតារាង ដើមកំណើត និងតម្លៃគិតពន្ធគយនៃទំនិញនាំចូលដែលបានបង្ហាញនៅក្នុងប្រតិវេទន៍គយ ត្រូវបានប្រកាសស្របទៅតាមវិធានដូចខាងក្រោមនេះ :

ក-ចំណាត់ថ្នាក់តាមតារាង និង ដើមកំណើត

-បុគ្គល អ្នកនាំចូល ឬ ភ្នាក់ងាររបស់ខ្លួនដែលបំពេញប្រតិវេទន៍គយនៃទំនិញនាំចូលត្រូវតែប្រកាសអំពីចំណាត់ថ្នាក់តាមតារាង និងដើមកំណើតនៃទំនិញទាំងនោះដើម្បីធ្វើការគណនាពន្ធ និងអាករ ។ រដ្ឋបាលគយត្រូវធ្វើការផ្ទៀងផ្ទាត់ចំណាត់ថ្នាក់តាមតារាង និងដើមកំណើតនៃទំនិញនាំចូល ។

- បុគ្គល អ្នកនាំចូល ឬភ្នាក់ងាររបស់ខ្លួន ដែលបំពេញប្រតិវេទន៍គយនៃទំនិញនាំចូលត្រូវតែធ្វើឡើងស្របតាមបញ្ញត្តិមាត្រា ៥១ និងមាត្រា ៥២ នៃច្បាប់នេះ ។

- រដ្ឋបាលគយអាចតម្រូវឱ្យបុគ្គល អ្នកនាំចូល ឬ ភ្នាក់ងាររបស់ខ្លួនបង្ហាញនូវសំអាងជាការប្រកាស ឬ ជាសំណុំឯកសារចាំបាច់ដែលតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិជាធរមាន អំពីភាពត្រឹមត្រូវនៃប្រតិវេទន៍ ហើយអាចបដិសេធមិនបញ្ចេញទំនិញរហូតដល់ភស្តុតាងទាំងនេះត្រូវបានផ្តល់ជូន ។

-ក្នុងរយៈពេលបី (៣) ឆ្នាំ គិតពីថ្ងៃចុះបញ្ជិកាប្រតិវេទន៍គយ បន្ទាប់ពីការធ្វើសវនកម្ម ការស៊ើបអង្កេត អធិការកិច្ច ឬ ការត្រួតពិនិត្យឡើងវិញនូវទំនិញនាំចូល រដ្ឋបាលគយអាចកំណត់ឡើងវិញនូវចំណាត់ថ្នាក់តាមតារាង ឬ ដើមកំណើត ដែលបានប្រកាសដោយចេញនូវប្រវេសន៍ ។ ប្រវេសន៍នេះត្រូវមានចែងអំពីហេតុផលនៃការកំណត់ឡើងវិញនូវចំណាត់ថ្នាក់ តាមតារាង ឬ ដើមកំណើត ។

-នៅពេលដែលការធ្វើសវនកម្ម ការស៊ើបអង្កេត អធិការកិច្ច ឬ ការត្រួតពិនិត្យឡើងវិញ ត្រូវបានធ្វើឡើងនៅក្រោមមាត្រានេះ បានរកឃើញនូវសកម្មភាពខុសឆ្គងណាមួយនោះ ប្រវេសន៍អាចត្រូវបានចេញចំពោះតែទំនិញដែលស្ថិតនៅក្រោមការស៊ើបអង្កេត ក្នុងរយៈពេលមិនលើសពីដប់ (១០) ឆ្នាំ គិតពីថ្ងៃចុះបញ្ជិកាប្រតិវេទន៍គយ ។

- ពន្ធ និងអាករបន្ថែម កម្រៃផ្សេងទៀត និងការពិន័យទាំងអស់ ដែលជាប់ពីការចេញប្រវេសន៍នេះ ត្រូវតែបង់ជូនរដ្ឋបាលគយ ។

-រាល់ការបង្វិលសងវិញណាមួយនូវពន្ធ អាករ កម្រៃ និងការពិន័យដែលបានបង់លើស ដោយបុគ្គល អ្នកនាំចូល ឬ ភ្នាក់ងាររបស់ខ្លួន ដែលកើតឡើងពីការចេញប្រវេសន៍ត្រូវតែបង្វិលសងវិញដោយរដ្ឋបាលគយ ។

ខ-តម្លៃគិតពន្ធគយ

-បុគ្គល អ្នកនាំចូល ឬភ្នាក់ងាររបស់ខ្លួនដែលបំពេញប្រតិវេទន៍គយត្រូវតែប្រកាសអំពីតម្លៃគិតពន្ធគយនៃទំនិញនាំចូល ដូចដែលបានបញ្ជាក់នៅក្នុងបញ្ញត្តិមាត្រា ២១ នៃច្បាប់នេះ ដើម្បីធ្វើការវាយតម្លៃពន្ធ និងអាករ ។ រដ្ឋបាលគយត្រូវធ្វើការផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយនៃទំនិញនាំចូលដែលបានប្រកាស ។

- បុគ្គល អ្នកនាំចូល ឬភ្នាក់ងាររបស់ខ្លួនដែលបំពេញប្រតិវេទន៍គយនៃទំនិញនាំចូលត្រូវតែធ្វើឡើងស្របតាមបញ្ញត្តិមាត្រា ៥១ និងមាត្រា ៥២ នៃច្បាប់នេះ ។

-បុគ្គល អ្នកនាំចូលឬ ភ្នាក់ងាររបស់ខ្លួនត្រូវទទួលខុសត្រូវក្នុងការប្រកាសឱ្យបានត្រឹមត្រូវនូវតម្លៃគិតពន្ធគយ ដើម្បីបង់ប្រាក់ពន្ធ និងអាករ និង ត្រូវលាតត្រដាងរាល់ព័ត៌មានទាំងអស់ វិក្កយបត្រ និងឯកសារផ្សេងទៀត ដើម្បីឱ្យរដ្ឋបាលគយអាចផ្ទៀងផ្ទាត់ និងធ្វើការកំណត់ឱ្យ បានត្រឹមត្រូវនូវតម្លៃគិតពន្ធគយនៃទំនិញនាំចូល ។

-រដ្ឋបាលគយអាចតម្រូវឱ្យបុគ្គល អ្នកនាំចូល ឬ ភ្នាក់ងាររបស់ខ្លួនបង្ហាញនូវសំអាងជាការប្រកាស ឬជាសំណុំឯកសារចាំបាច់ដែលតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិជាធរមាន អំពីភាពត្រឹមត្រូវនៃប្រតិវេទន៍ ហើយអាចបដិសេធមិនបញ្ចេញទំនិញរហូតដល់ភស្តុតាងទាំងនេះត្រូវបានផ្តល់ជូន ។

-ក្នុងរយៈពេល បី (៣) ឆ្នាំ គិតពីថ្ងៃចុះបញ្ជិកាប្រតិវេទន៍គយ បន្ទាប់ពីការធ្វើសវនកម្ម ការស៊ើបអង្កេត អធិការកិច្ច ឬ ការត្រួតពិនិត្យឡើងវិញនូវទំនិញនាំចូល រដ្ឋបាលគយអាចកំណត់ឡើងវិញនូវតម្លៃគិតពន្ធគយ ដែលបានប្រកាសដោយចេញនូវប្រវេសន៍ ។ ប្រវេសន៍នេះត្រូវមានចែងអំពីហេតុផលនៃការកំណត់ឡើងវិញនូវតម្លៃគិតពន្ធគយ ។

- រដ្ឋបាលគយអាចកែប្រែតម្លៃគិតពន្ធគយដែលបានប្រកាស ប្រសិនបើតម្លៃគិតពន្ធគយដែលបានប្រកាស មិនស្របទៅតាមបញ្ញត្តិមាត្រា ២១ នៃច្បាប់នេះ ឬ មិនត្រឹមត្រូវដោយហេតុផលផ្សេងទៀត ។

-នៅពេលដែលការធ្វើសវនកម្ម ការស៊ើបអង្កេត អធិការកិច្ច ឬ ការត្រួតពិនិត្យឡើងវិញត្រូវបានធ្វើឡើងនៅក្រោមមាត្រានេះ បានរកឃើញនូវសកម្មភាពខុសឆ្គងណាមួយនោះ ប្រវេសន៍អាចត្រូវបានចេញចំពោះតែទំនិញដែលស្ថិតនៅក្រោមការស៊ើបអង្កេតក្នុង

រយៈពេលមិនលើសពីដប់ (១០) ឆ្នាំ គិតពីថ្ងៃចុះបញ្ជិកាប្រតិវេទន៍គយ ។

គ-ការប្រកាសដោយស្ម័គ្រចិត្តអំពីពន្ធ អាករ ឬ កម្រៃផ្សេងៗបន្ថែម ដែលត្រូវបង់

បុគ្គល អ្នកនាំចូល ឬ ភ្នាក់ងាររបស់ខ្លួន អាចធ្វើការប្រកាសដោយស្ម័គ្រចិត្តជូនរដ្ឋបាលគយអំពីពន្ធ អាករ ឬ កម្រៃផ្សេងៗ ដែលពុំទាន់បានបង់លើទំនិញនាំចូលដោយពុំទទួលរងនូវការពិន័យ ឬទោសទណ្ឌនានាឡើយ ប្រសិនបើការប្រកាសនេះត្រូវបានធ្វើជូនរដ្ឋបាលគយក្នុងរង្វង់មួយ (១) ឆ្នាំ គិតចាប់ពីថ្ងៃចុះបញ្ជិកាប្រតិវេទន៍គយ ។

ឃ-អ្នកនាំចេញ និង ទំនិញនាំចេញ

បញ្ញត្តិនៃកថាខណ្ឌ ក និងកថាខណ្ឌ គ នៃមាត្រានេះត្រូវអនុវត្តផងដែរចំពោះទំនិញនាំចេញ ។

មាត្រា ១៩.-

សម្រាប់គោលបំណងនៃការនាំចេញ និងនាំចូល ទំនិញទាំងឡាយត្រូវបានធ្វើចំណាត់ថ្នាក់ ហើយពន្ធ និងអាករ ត្រូវបានគណនាស្របតាមតារាងពន្ធគយ វៀរលែងតែត្រូវបានលើកលែងដោយច្បាប់នេះ ឬ ច្បាប់ផ្សេងទៀតជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវចេញប្រកាសកំណត់នូវបញ្ញត្តិពាក់ព័ន្ធនឹងការធ្វើចំណាត់ថ្នាក់តាមតារាង ។

មាត្រា ២០.-

សម្រាប់ការនាំចូល ការប្រមូលពន្ធ និងអាករនានា ត្រូវអនុវត្តស្របតាមដើមកំណើតនៃទំនិញ ។

ដើមកំណើតនៃផលិតផលធម្មជាតិនានា គឺជាប្រទេសដែលផលិតផលនោះត្រូវបានប្រមូល ឬ ទាញយកពីដី ។

ទំនិញឧស្សាហផលដែលបានផលិតនៅក្នុងប្រទេសតែមួយ ដោយពុំមានការដាក់បញ្ចូលវត្ថុធាតុដើមពីប្រទេសដទៃ គឺមានដើមកំណើតពីប្រទេសដែលឧស្សាហផលនោះត្រូវបានផលិត ។

បែបបទដែលរដ្ឋបាលគយត្រូវអនុវត្ត ដើម្បីផ្ទៀងផ្ទាត់ដើមកំណើតទំនិញ ដែលបានផលិតនៅក្នុងប្រទេសមួយ ដោយប្រើប្រាស់ផលិតផលដែលបានមកពីការប្រមូល ឬ ទាញ

17/45

យកពីដី ឬ ផលិតនៅប្រទេសផ្សេងទៀត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ទំនិញនាំចូលទាំងឡាយនឹងទទួលសេចក្តីអនុគ្រោះចំពោះដើមកំណើតបាន លុះត្រាតែមានការជូនសំអាងដោយត្រឹមត្រូវអំពីដើមកំណើត និងការដឹកជញ្ជូនត្រង់ពីប្រទេសដើមកំណើតទៅប្រទេសនាំចូល ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញប្រកាសកំណត់ល័ក្ខខ័ណ្ឌដែលតម្រូវ និង មិនតម្រូវឱ្យជូនសំអាង ។

ប្រទេសនាំចេញគឺជាប្រទេសដែលទំនិញត្រូវបានគេបញ្ជូនដោយត្រង់សំដៅមកដែនគយ ។

មាត្រា ២១.-

តម្លៃគិតពន្ធគយលើទំនិញនាំចូល ត្រូវបានកំណត់ទៅតាមវិធានដូចខាងក្រោមនេះ :

ក- តម្លៃគិតពន្ធគយលើទំនិញនាំចូល គឺជាតម្លៃចម្លងការ មានន័យថាថ្លៃដែលបានទូទាត់ ឬ នឹងត្រូវទូទាត់ពិតប្រាកដ លើទំនិញដែលបានលក់សម្រាប់នាំចេញមកព្រះរាជាណាចក្រកម្ពុជា ស្របតាមបញ្ញត្តិនៃប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដូចមានកំណត់ក្នុងវាក្យខណ្ឌ ជ នៃមាត្រានេះ ។

ខ- ប្រសិនបើតម្លៃគិតពន្ធគយនៃទំនិញនាំចូលពុំអាចត្រូវបានកំណត់ក្រោមបញ្ញត្តិនៃវាក្យខណ្ឌ ក នៃមាត្រានេះ តម្លៃគិតពន្ធគយគឺជាតម្លៃចម្លងការនៃទំនិញដូចគ្នា ។

គ- ប្រសិនបើតម្លៃគិតពន្ធគយនៃទំនិញនាំចូលពុំអាចត្រូវបានកំណត់ក្រោមបញ្ញត្តិនៃវាក្យខណ្ឌ ក និងវាក្យខណ្ឌ ខ នៃមាត្រានេះ តម្លៃគិតពន្ធគយ គឺជាតម្លៃចម្លងការនៃទំនិញប្រហាក់ប្រហែលគ្នា ។

ឃ-ប្រសិនបើតម្លៃគិតពន្ធគយនៃទំនិញនាំចូលពុំអាចត្រូវបានកំណត់ក្រោមបញ្ញត្តិនៃវាក្យខណ្ឌ ក វាក្យខណ្ឌ ខ និងវាក្យខណ្ឌ គ នៃមាត្រានេះ តម្លៃគិតពន្ធគយត្រូវផ្អែកលើវិធីសាស្ត្រអនុមាន ។

ង- ប្រសិនបើតម្លៃគិតពន្ធគយនៃទំនិញនាំចូលពុំអាចត្រូវបានកំណត់ក្រោមបញ្ញត្តិនៃវាក្យខណ្ឌ ក វាក្យខណ្ឌ ខ វាក្យខណ្ឌ គ និងវាក្យខណ្ឌ ឃ នៃមាត្រានេះ តម្លៃគិតពន្ធគយត្រូវផ្អែកលើវិធីសាស្ត្រគណនា ។

ROYAUME du CAMBODGE LE MINISTRE du PALAIS ROYAL

១៤/៩៥

៦

ព- លំដាប់នៃការអនុវត្តនៃវាក្យខណ្ឌ ឃ និងវាក្យខណ្ឌ ង នៃមាត្រានេះអាចត្រូវត្រឡប់ចុះឡើងបានតាមសំណើរបស់អ្នកនាំចូល ។

ឆ- ប្រសិនបើតម្លៃគិតពន្ធគយនៃទំនិញនាំចូលពុំអាចត្រូវបានកំណត់ក្រោមបញ្ញត្តិនៃវាក្យខណ្ឌ ក វាក្យខណ្ឌ ខ វាក្យខណ្ឌ គ វាក្យខណ្ឌ ឃ និងវាក្យខណ្ឌ ង នៃមាត្រានេះ តម្លៃគិតពន្ធគយត្រូវកំណត់ដោយប្រើប្រាស់មធ្យោបាយសមស្របនានាដែលស៊ីចង្វាក់ទៅនឹងគោលការណ៍ និងបញ្ញត្តិនានានៃវាក្យខណ្ឌ ក វាក្យខណ្ឌ ខ វាក្យខណ្ឌ គ វាក្យខណ្ឌ ឃ និង វាក្យខណ្ឌ ង នៃមាត្រានេះ ដោយផ្អែកលើមូលដ្ឋានទិន្នន័យដែលមានស្រាប់នៅក្នុងដែនគយក្រោមល័ក្ខខ័ណ្ឌច្បាស់លាស់ ។

ជ-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬ រដ្ឋមន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុ ត្រូវចេញប្រកាសកំណត់នូវរាល់បញ្ហាដែលពាក់ព័ន្ធនឹងការកំណត់តម្លៃគិតពន្ធគយ ។

មាត្រា ២២.-

តម្លៃគិតពន្ធគយនៃទំនិញនាំចេញ គឺជាតម្លៃទំនិញនៅចំណុចនាំចេញ ។

តម្លៃគិតពន្ធគយនេះនឹងត្រូវកំណត់ដោយត្រូវបូកថ្លៃដឹកជញ្ជូនទំនិញរួមទាំងរាល់ចំណាយទាំងឡាយ ដែលត្រូវបង់សម្រាប់ប្រតិបត្តិការនាំចេញរហូតដល់ព្រំដែន លើកលែងអាករនាំចេញ អាករក្នុងប្រទេស និងបន្ទុកប្រហាក់ប្រហែលដែលអ្នកនាំចេញបានបង់និងមានបង្កាន់ដៃ ។

មាត្រា ២៣.-

តម្លៃគិតពន្ធគយនៃទំនិញនាំចូល និងទំនិញនាំចេញត្រូវប្រកាសជាប្រាក់រៀល ។

ប្រសិនបើតម្លៃគិតពន្ធគយ ត្រូវបានបង្ហាញជារូបិយវត្ថុផ្សេងពីរូបិយវត្ថុកម្ពុជា អត្រាប្តូរប្រាក់ដែលត្រូវអនុវត្ត គឺជាអត្រាដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា ។ ប៉ុន្តែចំពោះអត្រាប្តូរប្រាក់ដែលមិនមានកំណត់ក្នុងតារាងអត្រាប្តូរប្រាក់របស់ធនាគារជាតិនៃកម្ពុជា រដ្ឋបាលគយអាចកំណត់បាន ។

អត្រាប្តូរប្រាក់ដែលត្រូវអនុវត្ត គឺជាអត្រាប្តូរប្រាក់ដែលប្រើនៅក្នុងថ្ងៃចុះបញ្ជិកាប្រតិវេទន៍គយ ។

អត្រាប្តូរប្រាក់ត្រូវផ្សព្វផ្សាយជាសាធារណៈដោយរដ្ឋបាលគយ ។

ROYAUME DU CAMBODGE ... SECRETARIAT ... DU PALAIS

19/48

មាត្រា ២៥.–

បុគ្គល អ្នកនាំចូល ឬ ភ្នាក់ងាររបស់ខ្លួនដែលមិនពេញចិត្តចំពោះហេតុផល ឬ ភាពត្រឹមត្រូវនៃការកំណត់ឡើងវិញនូវចំណាត់ថ្នាក់តាមតារាង ដើមកំណើត ឬ តម្លៃគិតពន្ធគយដែលបានផ្តល់ជូនក្នុងប្រវេសន៍ ដូចមានចែងក្នុងបញ្ញត្តិនៃកថាខណ្ឌ ក និងកថាខណ្ឌ ខ មាត្រា ១៨ នៃច្បាប់នេះ អាចជំទាស់ទៅនឹងការសម្រេចនេះជាលាយលក្ខណ៍អក្សរទៅនាយកទីចាត់ការគយ និងរដ្ឋាករ ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ គិតពីថ្ងៃដែលប្រតិវេទករបានទទួលប្រវេសន៍ពីការកំណត់ឡើងវិញនូវចំណាត់ថ្នាក់តាមតារាង ដើមកំណើត ឬ តម្លៃគិតពន្ធគយនេះ ។

នៅក្នុងករណីដែលតម្លៃគិតពន្ធគយ គឺជាកម្មវត្ថុនៃការតវ៉ា ទំនិញត្រូវបានអនុញ្ញាតឱ្យយកចេញពីគយដោយគ្មានការបង់ប្រាក់ពន្ធ និងអាករឡើយ ប្រសិនបើអ្នកនាំចូលតម្កល់នូវនិមុត្តិធានាគ្រប់គ្រាន់ ដើម្បីធានាប្រាក់ពន្ធ និង អាករ ។

នាយកទីចាត់ការគយ និងរដ្ឋាករ ត្រូវធ្វើសេចក្តីសម្រេចលើការជំទាស់ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ក្នុងរយៈពេលហុកសិប (៦០) ថ្ងៃ បន្ទាប់ពីការជំទាស់ត្រូវបានទទួល ។ បើមិនដូច្នោះទេ ការជំទាស់នឹងត្រូវចាត់ទុកថា បានយល់ព្រម ហើយនិមុត្តិធានាត្រូវប្រគល់ជូនវិញ ។

បុគ្គលណា ដែលជំទាស់ទៅនឹងការសម្រេចរបស់នាយកទីចាត់ការគយ និងរដ្ឋាករ ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ អាចធ្វើការតវ៉ាជាលាយលក្ខណ៍អក្សរទៅគណៈកម្មាធិការតារាងពន្ធគយបាន ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការតារាងពន្ធគយ ត្រូវកំណត់ដោយអនុក្រឹត្យ ។

អ្នកនាំចេញ ឬ អ្នកនាំចូល មានសិទ្ធិធ្វើការតវ៉ាទៅតុលាការមានសមត្ថកិច្ច ជំទាស់នឹងការសម្រេចរបស់គណៈកម្មាធិការតារាងពន្ធគយក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ គិតពីថ្ងៃបានទទួលនូវសេចក្តីជូនដំណឹងពីការសម្រេចនេះ ។

ជំពូកទី ៤

ការលើកលែង ការលើកលែងជាភាគ និង
ការបង្វិលសងវិញនូវពន្ធ និងអាករ

មាត្រា ២៥.–

ទំនិញដែលចូលក្នុងដែនគយសម្រាប់ឆ្លងកាត់ ឬ ផ្ទេរមធ្យោបាយដឹកជញ្ជូន មិនត្រូវជាប់ពន្ធ និងអាករនាំចូលឡើយ ។

មាត្រា ២៦.–

ការលើកលែងពន្ធនិងអាករនាំចូលត្រូវអនុញ្ញាតផ្តល់ជូនចំពោះការនាំចូល ៖

ក- ទំនិញសម្រាប់បេសកកម្មការទូត ឬបេសកកម្មកុងស៊ុលបរទេស អង្គការអន្តរជាតិ និងភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលផ្សេងទៀត ដើម្បីប្រើប្រាស់ក្នុងការិយកិច្ចនៃមុខងារជាផ្លូវការ ដោយមានការបញ្ជាក់ពីប្រធានបេសកកម្ម និងពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

ខ-ទំនិញសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួនរបស់បុគ្គលិកផ្លូវការនៃបេសកកម្ម និងអង្គការ ដូចបានរៀបរាប់នៅក្នុងវាក្យខណ្ឌ ក កថាខណ្ឌទី ១ នៃមាត្រានេះ ។ ការអនុវត្តនូវវាក្យខណ្ឌនេះ និងវាក្យខណ្ឌ ក កថាខណ្ឌទី ១ នៃមាត្រានេះ ត្រូវផ្អែកលើគោលការណ៍ច្បាប់អន្តរជាតិ និងគោលការណ៍បដិការរវាងរដ្ឋាភិបាលពាក់ព័ន្ធ ។

គ- ទំនិញមានដើមកំណើតកម្ពុជា ឬទំនិញនាំចូលដែលបានបង់ពន្ធ និងអាកររួច ដែលចេញពីដែនគយហើយត្រូវនាំចូលត្រឡប់ពីបរទេសមកវិញ ដោយពុំមានការបង្កើនតម្លៃ ។

ឃ- ទំនិញដែលត្រូវលើកលែងពន្ធ និងអាករក្រោមបញ្ញត្តិនៃច្បាប់ផ្សេងទៀតរបស់ព្រះរាជាណាចក្រកម្ពុជា ។

ង- ទំនិញជាអំណោយសម្រាប់មនុស្សធម៌ទំនិញសម្រាប់ការស្រាវជ្រាវ និងគោលបំណងវិទ្យាសាស្ត្រ ទំនិញគំរូ និងទំនិញតាំងពិព័រណ៍ដែលគ្មានតម្លៃពាណិជ្ជកម្ម

មឈូសដែលមានសាកសពមនុស្ស និងទំនិញផ្សេងទៀត ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ទំនិញនាំចូលដែលត្រូវលើកលែងពន្ធ និងអាករក្រោមបញ្ញត្តិកថាខណ្ឌទី ១ នៃមាត្រានេះ មិនអាចត្រូវបានលក់ ផ្ទេរ បង្វែរទៅប្រើប្រាស់អ្វីផ្សេង ឬ បោះបង់ចោលដោយគ្មានការអនុញ្ញាតជាមុនពីរដ្ឋបាលគយឡើយ ។

ទំនិញដែលមានតម្លៃ និងបរិមាណច្បាស់លាស់មួយចំនួន កំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលនាំចូលដោយអ្នកដំណើរ អ្នកបម្រើការតាមមធ្យោបាយដឹកជញ្ជូន និងជនទាំងឡាយដែលឆ្លងកាត់ព្រំដែនត្រូវលើកលែងពន្ធ និងអាករនាំចូល ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញប្រកាសកំណត់បាននូវបញ្ញត្តិនានាដែលពាក់ព័ន្ធចំពោះទំនិញដូចមានចែងក្នុងវាក្យខណ្ឌ ក វាក្យខណ្ឌ ខ វាក្យខណ្ឌ គ វាក្យខណ្ឌ ឃ និងវាក្យខណ្ឌ ង ក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ដោយរួមទាំងការលក់ ការផ្ទេរ ការបង្វែរ និងការបោះបង់ចោល ក្រោមបញ្ញត្តិកថាខណ្ឌទី ២ នៃមាត្រានេះ ។

មាត្រា ២៧.-

ការលើកលែងជាភាគនៃពន្ធ និងអាករនាំចូល អាចនឹងផ្តល់ជូនបានចំពោះការនាំចូល ៖

ក-ទំនិញ និងសម្ភារៈដែលមានចែងដោយច្បាប់ផ្សេងទៀតរបស់ព្រះរាជាណាចក្រកម្ពុជា ។

ខ-ពូជដំណាំ និងពូជសត្វសម្រាប់កសិកម្ម ទំនិញដែលនឹងត្រូវទទួលការជួសជុល ការកែច្នៃ ឬ ពិសោធន៍ ទំនិញដែលបាននាំចូលវិញតាមសភាពដើម ទំនិញដែលនាំចូលដោយរដ្ឋាភិបាលដើម្បីជាប្រយោជន៍សាធារណៈ ទំនិញនាំចូលសម្រាប់របបប្រវេសន៍កាលិក និងទំនិញផ្សេងទៀតដែលបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ទំនិញដែលនាំចូលក្រោមបញ្ញត្តិនៃមាត្រានេះ មិនអាចត្រូវបានលក់ ផ្ទេរ បង្វែរ ឬ បោះបង់ចោលដោយគ្មានការអនុញ្ញាតជាមុនពីរដ្ឋបាលគយបានឡើយ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញប្រកាសកំណត់នូវបញ្ញត្តិនានាដែលពាក់ព័ន្ធចំពោះទំនិញដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រា នេះរួមទាំងការលក់ ការផ្ទេរ ការបង្វែរ និងការបោះបង់ចោលក្រោមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រានេះផង ។

មាត្រា ២៨.–

រដ្ឋបាលគយអាចផ្តល់បាននូវការបង្វិលសងវិញទាំងស្រុង ឬ ភាគខ្លះនូវពន្ធ និងអាករនាំចូលដែលបានបង់រួចចំពោះ :

ក- ការបង់លើសដោយប្រការណាមួយ រាប់បញ្ចូលទាំងករណីដែលបណ្តាលមកពីការភ័ន្តច្រឡំរដ្ឋបាលផង ។

ខ-ទំនិញនាំចូលដែលនៅមុនពេលអនុញ្ញាតឱ្យយកចេញពីគយត្រូវពិនិត្យឃើញថា តិចជាង បែកបាក់ខូចខាត គុណភាពទាប និងទំនិញនាំចេញទៅវិញ ឬ បំផ្លាញចោល ក្រោមការគ្រប់គ្រង ឃ្លាំមើលរបស់គយ ទោះបីនៅក្រោយពេលអនុញ្ញាតឱ្យយកចេញពីគយរួចហើយក៏ដោយ ។

គ-ការបង់លើសដែលបានរកឃើញតាមរយៈសេចក្តីសម្រេចរបស់អាជ្ញាធរទទួលបន្ទុកដោះស្រាយការតវ៉ាដូចមានចែងក្នុងមាត្រា ២៤ នៃច្បាប់នេះ ឬ ដោយតុលាការមានសមត្ថកិច្ច ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវចេញប្រកាសស្តីពីការបង្វិលសងវិញដែលបានរៀបរាប់ខាងលើ និងការបង្វិលសងវិញ ដោយមូលហេតុផ្សេងទៀតរួមទាំងការកម្រិតពេលវេលាផងដែរ ។

ជំពូកទី ៥

ប្រតិវេទន៍គយ និងការទទួលខុសត្រូវចំពោះពន្ធ និងអាករ

មាត្រា ២៩.–

រាល់ទំនិញនាំចេញ ឬ នាំចូល ទោះជាជាប់ពន្ធ និងអាករក្តី ឬ ត្រូវបានលើកលែងពន្ធ និងអាករ ទំនិញទាំងនោះត្រូវតែជាកម្មវត្ថុនៃការធ្វើប្រតិវេទន៍គយ ។

23/45

មាត្រា ៣០.-

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវចេញប្រកាសពាក់ព័ន្ធនឹង :

-ទម្រង់ ខ្លឹមសារ និងសុពលភាពនៃប្រតិវេទន៍ និងឯកសារគយ

-ការតម្កល់ ការផ្ទៀងផ្ទាត់ និង ការចុះបញ្ជីកាប្រតិវេទន៍គយ

-ការកែប្រែ ការបន្ថែម និងការលុប ឬ ប្តូរនូវប្រតិវេទន៍ និង ឯកសារគយ

-ការបែងចែក និងគ្រប់គ្រងផ្លូវត្រួតពិនិត្យ ប្រតិវេទន៍ និងឯកសារគយ ។

មាត្រា ៣១.-

ទំនិញនាំចេញ ឬ នាំចូលត្រូវប្រកាសដោយម្ចាស់ទំនិញ ឬ ដោយបុគ្គលដែលបាន ទទួលការអនុញ្ញាតឱ្យបំពេញបែបបទគយក្នុងនាមម្ចាស់ទំនិញ ។

មាត្រា ៣២.-

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអាចចេញប្រកាសផ្តល់ ឬដកមកវិញនូវការ អនុញ្ញាតបាន ចំពោះបុគ្គលណាមួយជាជើងសាគយ និងកំណត់នូវទីតាំងដែលការអនុញ្ញាត នោះមានសុពលភាព និងល័ក្ខខ័ណ្ឌ ឬ លក្ខណៈសម្បត្តិនានាសម្រាប់ការអនុញ្ញាតនេះ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចបង្កើតគណៈកម្មាធិការមួយបានសម្រាប់ ផ្តល់យោបល់លើការអនុញ្ញាតនេះ និងរាល់បញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងជើងសាគយ ។

ការអនុញ្ញាតជាជើងសាគយ ត្រូវបានផ្តល់សម្រាប់ជនម្នាក់ៗ ។ ប្រសិនបើជាការ ស្នើសុំរបស់នីតិបុគ្គល ការអនុញ្ញាតនឹងត្រូវផ្តល់ជូននីតិបុគ្គលនោះ និងជនដែលទទួលសិទ្ធិ ជាតំណាង ។

ការបដិសេធ ការដកមកវិញនូវការអនុញ្ញាតជាបណ្តោះអាសន្ន ឬ ជាអចិន្ត្រៃយ៍ជា ជើងសាគយពុំត្រូវបានផ្តល់នូវសំណង ឬ ជម្ងឺចិត្តអ្វីឡើយ ។

ជើងសាគយដែលបានអនុញ្ញាត អាចត្រូវតម្កល់និមុត្តិធានាពាក់ព័ន្ធនឹងប្រតិបត្តិ-ការរបស់ខ្លួនតាមទម្រង់ និងចំនួនទឹកប្រាក់ដូចដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ៣៣.-

បុគ្គលណាដែលគ្មានវិជ្ជាជីវៈជាជើងសាគយ អាចបំពេញប្រតិវេទន៍គយបានសម្រាប់

24/45

អាជីវកម្មខ្លួន ។

បុគ្គលដែលមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះអាចទទួលបានការអនុញ្ញាតឱ្យបញ្ចេញទំនិញពីគយសម្រាប់អ្នកដទៃ ។ ការអនុញ្ញាតនេះត្រូវបានផ្តល់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាបណ្តោះអាសន្ន ហើយអាចដកហូតវិញបានសម្រាប់ប្រតិបត្តិការពាក់ព័ន្ធនឹងទំនិញដោយឡែកមួយចំនួន ។

មាត្រា ៣៤.-

ពន្ធ និងអាករនាំចូលត្រូវគណនាដោយផ្អែកលើមូលដ្ឋានអត្រាពន្ធ ឬ អាករ ជាធរមាននៅថ្ងៃចុះបញ្ជិកាប្រតិវេទន៍គយ ។

ពន្ធ និងអាករនាំចូលត្រូវគណនាដោយផ្អែកលើមូលដ្ឋាន ពន្ធគិតតាមតម្លៃ ឬ ពន្ធគិតតាមឯកតា ។

មាត្រា ៣៥.-

អ្នកនាំចូល ឬ ម្ចាស់ទំនិញត្រូវទទួលខុសត្រូវចំពោះពន្ធ និងអាករនាំចូល ។

ក្នុងករណីដែលអ្នកនាំចូល ឬ ម្ចាស់ទំនិញមិនត្រូវបានរកឃើញ ភ្នាក់ងារជើងសាគយត្រូវទទួលខុសត្រូវចំពោះពន្ធ និងអាករនាំចូល ។

ក្នុងករណីសន្និធិគយបណ្តោះអាសន្ន ឬ សន្និធិគយមានដែនកំណត់ ប្រតិបត្តិករនៃសន្និធិទាំងនេះ ជាអ្នកទទួលខុសត្រូវចំពោះពន្ធ អាករ និងកម្រៃផ្សេងៗដោយមិនទាន់គិតដល់ទោសទណ្ឌផ្សេងទៀតដែលអាចត្រូវទទួល រហូតដល់ទំនិញត្រូវបាននាំចេញទៅវិញនាំចូលបណ្តោះអាសន្ន នាំចូលដើម្បីប្រើប្រាស់ក្នុងប្រទេស បង្វែរទៅទីកន្លែងសន្និធិផ្សេងទៀត ឬ បំផ្លាញចោលដោយមានការអនុញ្ញាតពីរដ្ឋបាលគយ ។

នៅក្នុងករណីមាត្រា ២៦ និងមាត្រា ២៧ នៃច្បាប់នេះ ប្រសិនបើល័ក្ខខ័ណ្ឌនៃការលើកលែងពន្ធ និងអាករនាំចូលមិនត្រូវបានបំពេញសព្វគ្រប់ ការទទួលខុសត្រូវចំពោះពន្ធ និងអាករនាំចូលជាបន្ទុករបស់បុគ្គលដែលបានទទួលការលើកលែងពន្ធ និងអាករនាំចូល ប្រសិនបើមិនអាចរកឃើញបុគ្គលនោះ បន្ទុកនេះត្រូវធ្លាក់ទៅលើបុគ្គលដែលកាន់កាប់ទំនិញនោះ ។

ជនណាដែលជាអ្នកកាន់កាប់ទំនិញនាំចូលនាពេលដែលមធ្យោបាយដឹកជញ្ជូនចូល

ក្នុងដែនគយ រាប់បញ្ចូលទាំងប្រតិបត្តិករមធ្យោបាយដឹកជញ្ជូនផង ជននោះជាអ្នកទទួលខុសត្រូវលើពន្ធ និងអាករនាំចូលនៃទំនិញនោះ ។

មាត្រា ៣៦.-

អ្នកនាំចេញ ឬម្ចាស់ទំនិញត្រូវទទួលខុសត្រូវចំពោះពន្ធ និងអាករនាំចេញ ។

ក្នុងករណីដែលអ្នកនាំចេញ ឬ ម្ចាស់ទំនិញមិនអាចត្រូវបានរកឃើញជើងសាគយត្រូវទទួលខុសត្រូវចំពោះពន្ធ និងអាករនាំចេញ ។

ក្នុងករណីសន្និធិគយណ្តោះអាសន្ន និងសន្និធិគយមានដែនកំណត់ ប្រតិបត្តិករនៃសន្និធិទាំងនេះត្រូវទទួលខុសត្រូវចំពោះពន្ធ និងអាករនាំចេញ ។

ជំពូកទី ៦

ការបង់ប្រាក់ពន្ធ និងអាករនាំចូល និងនាំចេញ

ការប្រមូលបំណុល និងនិមុត្តិធានា

មាត្រា ៣៧.-

ពន្ធ និងអាករនាំចេញ និងនាំចូល ព្រមទាំងកម្រៃមានការអនុញ្ញាត ការពិន័យ ការប្រាក់ ឬ ទោសទណ្ឌដែលត្រូវជាប់ក្រោមច្បាប់នេះ និងច្បាប់ផ្សេងទៀតនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបង់នៅកន្លែង តាមរបៀប និង ពេលវេលាកំណត់ ដូចមានចែងក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ពន្ធ និងអាករដែលត្រូវបង់សម្រាប់មុខទំនិញនីមួយៗក្នុងប្រតិវេទន៍គយតែមួយត្រូវគិតជាប្រាក់រៀលដោយដំឡើងដល់ខ្ទង់រយជិតបំផុត ។

បង្កាន់ដៃត្រូវបានផ្តល់សម្រាប់រាល់ការចំណាយដែលបានបង់ ។

មាត្រា ៣៨.-

បំណុលដែលដឹពាក់ស្របតាមបញ្ញត្តិនៃច្បាប់នេះហើយពុំបានបង់ទាំងស្រុង ឬភាគខ្លះតាមពេលវេលាកំណត់ ត្រូវជាប់ការប្រាក់តរពូន ទៅតាមអត្រាដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ៣៩.-

រដ្ឋបាលគយមានបុព្វសិទ្ធិខាងទាមទារយកទំនិញ និងទ្រព្យសម្បត្តិរបស់ឥណាយិក ដែលជំពាក់ស្របតាមបញ្ញត្តិនៃច្បាប់នេះ ។

មាត្រា ៤០.-

នីតិវិធីនៃការប្រមូល និងការលុបចោលនូវបំណុល ដែលមិនអាចប្រមូលបានត្រូវផ្អែកលើបញ្ញត្តិ និងច្បាប់នានាជាធរមាន ។

មាត្រា ៤១.-

និមុត្តិធានាដែលតម្រូវដោយច្បាប់នេះ អាចត្រូវប្រើប្រាស់ម្តង ឬ ច្រើនដងដែលអាចមានទម្រង់ជាសាច់ប្រាក់ ការធានា ឬ ជាលិខិតុបករណ៍ផ្សេងទៀតបាន ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអាចចេញប្រកាសកំណត់បាននូវបញ្ញត្តិដែលពាក់ព័ន្ធនឹងនិមុត្តិធានានេះ ។

មាត្រា ៤២.-

នាយកទីចាត់ការគយនិងរដ្ឋាករអាចដោះបន្ទុកនិមុត្តិធានាដែលបានតម្កល់សម្រាប់ធានាលើការនាំចេញ ឬការនាំចេញបន្តនូវទំនិញខ្លះ ក្រោយពីមានការជូនសំអាងដែលកំណត់ថា ទំនិញទាំងនេះពិតជាបាននាំចេញ ឬ នាំចេញបន្តទៅវិញមែន ។

ជំពូកទី ៧

សន្និធិគយបណ្តោះអាសន្ន និងឃ្លាំងគយមានដែនកំណត់

មាត្រា ៤៣.-

សន្និធិគយបណ្តោះអាសន្ន គឺសំដៅលើសន្និធិទំនិញ ដែលស្ថិតក្រោមការត្រួតពិនិត្យគយ នៅទីកន្លែងដែលបានទទួលការអនុញ្ញាត ដើម្បីរង់ចាំការបំពេញបែបបទបញ្ចេញទំនិញពីគយ ។

អាជ្ញាប័ណ្ណសម្រាប់ប្រតិបត្តិការទីកន្លែងសន្និធិគយបណ្តោះអាសន្ន ត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ អាជ្ញាប័ណ្ណនេះ កំណត់នូវល័ក្ខខ័ណ្ឌសម្រាប់ម្ចាស់

កម្មសិទ្ធិ និងប្រតិបត្តិកររាប់បញ្ចូលទាំងទីតាំង សំណង់ គម្រោងអគារ នីតិវិធីសម្រាប់ចាត់ចែង និងគ្រប់គ្រង ។

ចំណាយពាក់ព័ន្ធនឹងទីកន្លែងសន្និធិគយបណ្តោះអាសន្នរាប់បញ្ចូលទាំងថ្លៃថែទាំ និងជួសជុលជាបន្ទុករបស់ម្ចាស់កម្មសិទ្ធិ ឬ ប្រតិបត្តិករ ។

ម្ចាស់កម្មសិទ្ធិ ឬប្រតិបត្តិករទីកន្លែងសន្និធិគយបណ្តោះអាសន្ន ត្រូវបានដោះស្រាយជូនទីកន្លែងសមរម្យ គ្រប់គ្រាន់ ដោយមិនយកកម្រៃជូនមន្ត្រីគយ ដើម្បីបំពេញការងារដូចមានចែងក្នុងច្បាប់នេះ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញប្រកាសកំណត់បានគ្រប់ករណីទាំងឡាយពាក់ព័ន្ធនឹងសន្និធិគយបណ្តោះអាសន្នរាប់បញ្ចូលទាំងនីតិវិធី និមុត្តិជានា តម្រូវការព័ត៌មាន រយៈពេលសន្និធិ និងប្រភេទទំនិញ ដែលអាចអនុញ្ញាតឱ្យធ្វើសន្និធិ និង ពិន័យលើការធ្វើសន្និធិហួសរយៈពេលកំណត់ ។

មាត្រា ៤៤.-

ភណ្ឌាគារគយមានដែនកំណត់គឺជាទីកន្លែងដែលទំនិញត្រូវបានដាក់ សម្រាប់រយៈពេលជាក់លាក់មួយ ស្ថិតនៅក្រោមការត្រួតពិនិត្យគយ ដោយមានបញ្ជាក់ពីពេលវេលាច្បាស់លាស់ ។

ការដាក់ទំនិញក្នុងភណ្ឌាគារគយមានដែនកំណត់ ត្រូវបានព្យួរការបង់ពន្ធ អាករ និងការដាក់កម្រិតកំណត់ដែលទំនិញទាំងនោះត្រូវជាប់ ។

ភណ្ឌាគារគយមានដែនកំណត់មានបីប្រភេទ :

ក-ភណ្ឌាគារសាធារណៈ ដែលទទួលបានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចធ្វើប្រតិបត្តិការដោយភ្នាក់ងាររបស់រាជរដ្ឋាភិបាល ឬ ដោយបុគ្គលណាមួយបាន ។ ភណ្ឌាគារនេះត្រូវបានប្រើប្រាស់សម្រាប់ផ្តល់សេវាដល់បុគ្គលទាំងឡាយដែលមានសិទ្ធិធ្វើសន្និធិទំនិញ ។

ខ-ភណ្ឌាគារឯកជន ដែលត្រូវបានផ្តល់ការអនុញ្ញាតដោយនាយកទីចាត់ការគយ និងរដ្ឋាករ ត្រូវបានប្រើប្រាស់ដោយឡែក ដោយបុគ្គលណាម្នាក់សម្រាប់ធ្វើសន្និធិទំនិញដើម្បីការប្រើប្រាស់ដោយឡែក រាប់បញ្ចូលទាំងប្រតិបត្តិករអគារលក់ទំនិញរួចពន្ធ ។

គ- ភណ្ឌាគារពិសេស គឺជាប្រភេទភណ្ឌាគារដែលទទួលបានសិទ្ធិពីនាយកដ្ឋានទីចាត់ការគយ និងរដ្ឋាករ សម្រាប់រក្សាប្រភេទទំនិញគ្រោះថ្នាក់ប៉ះពាល់ដល់គុណភាពទំនិញដទៃទៀត ឬ អាចត្រូវការទីកន្លែងពិសេសសម្រាប់រក្សាទំនិញទាំងនោះ ។

អាជ្ញាប័ណ្ណសម្រាប់ភណ្ឌាគារគយមានដែនកំណត់ ត្រូវកំណត់នូវលក្ខខណ្ឌសម្រាប់ម្ចាស់កម្មសិទ្ធិ និងប្រតិបត្តិករ រាប់បញ្ចូលទាំងទីតាំង សំណង់ គម្រោងអគារ នីតិវិធីសម្រាប់ចាត់ចែង និងគ្រប់គ្រង ។

ចំណាយពាក់ព័ន្ធនឹងភណ្ឌាគារគយមានដែនកំណត់ រាប់បញ្ចូលទាំងថ្លៃថែទាំ និងជួសជុលជាបន្ទុករបស់ម្ចាស់កម្មសិទ្ធិ ឬ ប្រតិបត្តិករ ។

ម្ចាស់កម្មសិទ្ធិ ឬ ប្រតិបត្តិករភណ្ឌាគារគយមានដែនកំណត់ ត្រូវធានាដោះស្រាយជូនទីកន្លែងសមរម្យ គ្រប់គ្រាន់ ដោយមិនយកកម្រៃជូនមន្ត្រីគយ ដើម្បីបំពេញការងារដូចមានចែងក្នុងច្បាប់នេះ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញប្រកាសកំណត់គ្រប់ករណីទាំងឡាយពាក់ព័ន្ធនឹងភណ្ឌាគារគយមានដែនកំណត់ រាប់បញ្ចូលទាំងនីតិវិធី និមុត្តិធានា តម្រូវការព័ត៌មាន រយៈពេលសន្និធិ និងប្រភេទទំនិញដែលអាចអនុញ្ញាតឱ្យធ្វើសន្និធិបាន ។

មាត្រា ៥៥.-

ប្រតិបត្តិករភណ្ឌាគារគយមានដែនកំណត់ ត្រូវបង់ពន្ធ និងអាករនានា លើទំនិញដែលបានដាក់នៅក្នុងភណ្ឌាគារ ក្នុងករណីដែលបរិមាណ និងគុណភាពខុសពីមានចែងក្នុងប្រតិវេទន៍ភណ្ឌាគារគយ ដោយមិនទាន់គិតដល់ទោសទណ្ឌដែលអាចកើតមាន ។ ប្រសិនបើជាទំនិញជាប់អាយ័តសម្រាប់ការនាំចូលប្រតិបត្តិករភណ្ឌាគារត្រូវតែបង់ផងដែរនូវចំនួនទឹកប្រាក់ស្មើនឹងតម្លៃទំនិញដោយមិនទាន់គិតដល់ទោសទណ្ឌដែលអាចកើតមានបាន ។

នាយកដ្ឋានទីចាត់ការគយ និងរដ្ឋាករ អាចអនុញ្ញាតបាន ក្រៅពីការនាំចេញទៅវិញឱ្យបំផ្លាញចោលនូវទំនិញដែលខូចខាតនៅក្នុងភណ្ឌាគារគយក្នុងលក្ខខណ្ឌ ដែលសំណល់ពីការបំផ្លាញនេះត្រូវបានបង់ពន្ធ និងអាករ ឬ ឱ្យធ្វើការបង់ពន្ធ និងអាករតាមសភាពទំនិញដែលបានបំផ្លាញកន្លងមកចំពោះរដ្ឋបាលគយ ។

ប្រសិនបើមានការអះអាងថា ការបាត់បង់ទំនិញដែលដាក់នៅក្នុងភណ្ឌាគារគយ

មានដែនកំណត់បណ្តាលមកពីករណីប្រធានស័ក្តិ ឬមូលហេតុពាក់ព័ន្ធនឹងទំនិញប្រតិបត្តិករភណ្ឌាគារត្រូវបានលើកលែងពីការបង់ពន្ធ និង អាករ ឬ ប្រសិនបើជាទំនិញជាប់អាយ័តត្រូវបានរួចពីការបង់ប្រាក់ស្មើនឹងតម្លៃនៃទំនិញនេះ។

មាត្រា ៤៦.-

ទំនិញអាចរក្សាទុកក្នុងភណ្ឌាគារគយមានដែនកំណត់ រហូតដល់រយៈពេលពីរ (២) ឆ្នាំ គិតពីថ្ងៃចុះបញ្ជិកា ។

ផុតរយៈពេលកំណត់ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ទំនិញត្រូវយកចេញពីភណ្ឌាគារដោយមានការអនុញ្ញាតពីគយ ។ បើមិនដូច្នោះទេ រដ្ឋបាលគយនឹងចេញប្រវេសន៍ដល់ប្រតិបត្តិករភណ្ឌាគារ ដោយតម្រូវឱ្យរើទំនិញចេញ ។ ប្រសិនបើការតម្រូវនេះនៅតែគ្មានប្រសិទ្ធភាពក្នុងរយៈពេលមួយ (១) ខែ ចាប់ពីថ្ងៃចេញប្រវេសន៍ ទំនិញត្រូវបានចាត់ទុកជាទំនិញគ្មានការទាមទារ ដូចមានចែងក្នុងមាត្រា ៥៤ នៃច្បាប់នេះ ។ រដ្ឋបាលគយអាចប្រមូលពន្ធ និងអាករ ដែលជំពាក់ពីនិមុត្តិធានាដែលបានតម្កល់ដោយប្រតិបត្តិករភណ្ឌា-គារ ឬ ទំនិញទាំងនោះអាចត្រូវដាក់លក់ ដោយដេញថ្លៃជាសាធារណៈ ដូចមានចែងក្នុងបញ្ញត្តិមាត្រា ៥៥ នៃច្បាប់នេះ ។

ជាការលើកលែង និងលុះត្រាតែទំនិញស្ថិតក្នុងសភាពល្អ រយៈពេលកំណត់ដែលមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ អាចត្រូវបានពន្យាររហូតដល់ដប់ពីរ (១២)ខែ ដោយរដ្ឋបាលគយតាមការស្នើសុំរបស់ប្រតិបត្តិករភណ្ឌាគារ ។

មាត្រា ៤៧.-

មន្ត្រីគយអាចធ្វើការឆែកឆេរដែលចាំបាច់នានា និងផ្ទៀងផ្ទាត់សារពើភណ្ឌទំនិញក្នុងភណ្ឌាគារ ។ ប្រតិបត្តិករត្រូវបង្ហាញទំនិញសម្រាប់ការធ្វើអធិការកិច្ចនេះ ។

មាត្រា ៤៨.-

ពន្ធ និងអាករនាំចូលដែលត្រូវប្រមូល គឺជាពន្ធ និងអាករ ដែលមានជាធរមានក្នុងថ្ងៃចុះបញ្ជិកាប្រតិវេទន៍គយដើម្បីយកទំនិញចេញពីភណ្ឌាគារគយមានដែនកំណត់ ។

30/45

មាត្រា ៤៩.-

ស្ថិតក្នុងកាលៈទេសៈជាក់ស្តែងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចអនុញ្ញាតឱ្យបង្កើតភណ្ឌាគារផលិតកម្មមានដែនកំណត់ ស្ថិតក្រោមការគ្រប់គ្រងរបស់គយក្នុងគោលបំណងកែច្នៃ និងផលិតទំនិញ ។

លើកលែងតែមានបទប្បញ្ញត្តិផ្ទុយពីនេះ ផលិតផលដែលដាក់ចូល ក្នុងភណ្ឌាគារផលិតកម្មមានដែនកំណត់ត្រូវបានព្យួរពន្ធ និងអាករនាំចូល ។

នៅពេលណាទំនិញត្រូវបានបញ្ចេញពីភណ្ឌាគារផលិតកម្មមានដែនកំណត់សម្រាប់ការប្រើប្រាស់ក្នុងប្រទេស ពន្ធ និងអាករដែលបានលើកលែង ដូចមានចែងក្នុងកថាខណ្ឌទី ២ នៃមាត្រានេះ ត្រូវប្រមូលផ្អែកតាមតារាងពន្ធគយ ហើយអត្រាពន្ធ និងអាករ ដែលត្រូវប្រមូល គឺជាអត្រានៅក្នុងថ្ងៃចុះបញ្ជិកាប្រតិវេទន៍គយនៅពេលដែលទំនិញទទួលបានការអនុញ្ញាតឱ្យយកចូលភណ្ឌាគារនោះ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញប្រកាសកំណត់គ្រប់ករណីនានាពាក់ព័ន្ធនឹងភណ្ឌាគារផលិតកម្មមានដែនកំណត់បាន ។

មាត្រា ៥០.-

ប្រតិបត្តិការកែច្នៃ ឬ ចំរាញ់តេលសិលាឆៅ ឬ ប៊ីទីមខនិជ ដើម្បីទទួលបានផលិតផលតេលសិលា ត្រូវដាក់ឱ្យស្ថិតក្រោមរបបភណ្ឌាគារផលិតកម្មមានដែនកំណត់ក្រោមការគ្រប់គ្រងរបស់គយ ។

ការព្យួរពន្ធ និងអាករ ដូចមានចែងក្នុងកថាខណ្ឌទី ២ មាត្រា ៤៩ នៃច្បាប់នេះអាចត្រូវបានផ្តល់ឱ្យសម្រាប់ការនាំចូលតេលសិលាឆៅ ឬ ប៊ីទីមខនិជ សម្រាប់កែច្នៃដើម្បីនាំចេញ ។

លក្ខខណ្ឌសម្រាប់ការអនុវត្តបញ្ញត្តិនៃមាត្រានេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

81/45

ជំពូកទី ៨

ឯកសារ បញ្ជីគណនេយ្យ កំណត់ត្រា និង ព័ត៌មានផ្សេងទៀត ស្តីពីការនាំចេញនិងនាំចូល

មាត្រា ៥១.-

បុគ្គលដែលចូលរួម ឬ ពាក់ព័ន្ធនឹងការនាំចេញ និងនាំចូល ត្រូវតែរក្សាឯកសារ បញ្ជីគណនេយ្យ កំណត់ត្រា និងព័ត៌មានផ្សេងទៀត រាប់បញ្ចូលទាំងព័ត៌មានជាសណ្ឋានអេឡិចត្រូនិកដែលត្រឹមត្រូវ និងគ្រប់គ្រាន់ ដែលពាក់ព័ន្ធនឹងការនាំចេញ ឬ នាំចូលនោះ ។

ត្រូវរាប់បញ្ចូលក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ នូវអ្នកនាំចូល អ្នកនាំចេញ ជើងសាគយ ប្រតិបត្តិករកន្លែងសន្និធិគយបណ្តោះអាសន្ន និង ភណ្ឌាគារគយមានដែនកំណត់ ប្រតិបត្តិករដឹកជញ្ជូន និងបណ្តាភាគីពាក់ព័ន្ធផ្សេងទៀត ។

ឯកសារ បញ្ជីគណនេយ្យ កំណត់ត្រា និងបណ្តាព័ត៌មានផ្សេងទៀត ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ត្រូវរក្សាទុករយៈពេលដប់ (១០) ឆ្នាំ នៅទីកន្លែងធុរកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៥២.-

តាមសំណើរបស់រដ្ឋបាលគយ បុគ្គលដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រា ៥១ នៃច្បាប់នេះ មានកាតព្វកិច្ចផ្តល់បង្ហាញនូវឯកសារ បញ្ជី គណនេយ្យ កំណត់ត្រា និងបណ្តាព័ត៌មានផ្សេងទៀតពាក់ព័ន្ធនឹងការនាំចេញ និងនាំចូល សម្រាប់ការពិនិត្យផ្ទៀងផ្ទាត់របស់គយ ។

ប្រសិនបើបុគ្គលដែលមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះអវត្តមាន អ្នកតំណាងរបស់បុគ្គលនោះ មានកាតព្វកិច្ចក្នុងការផ្តល់ឯកសារ បញ្ជីគណនេយ្យ កំណត់ត្រា និងបណ្តាព័ត៌មានផ្សេងទៀត ។

ក្នុងករណីដែលមន្ត្រីគយតម្រូវ បុគ្គលដូចមានចែងក្នុងកថាខណ្ឌខាងលើនៃមាត្រា នេះ ត្រូវ ៖

ក-ផ្តល់ឯកសារតាមតម្រូវការរបស់មន្ត្រីគយ ។

32/45

ខ- ឆ្លើយរាល់សំណួរដែលត្រូវបានសួរដោយមន្ត្រីគយ ពាក់ព័ន្ធនឹងកិច្ចការទាំងឡាយដែលកើតឡើងក្រោមបញ្ញត្តិនៃច្បាប់នេះ ។

គ- បើកឱ្យដំណើរការនូវរាល់ឧបករណ៍ដើម្បីផ្តល់បង្ហាញនូវព័ត៌មានចាំបាច់នានាដល់មន្ត្រីគយតាមសំណើ ប្រសិនបើព័ត៌មានដូចមានចែងក្នុងកថាខណ្ឌខាងលើនៃមាត្រានេះត្រូវបានរក្សាទុកដោយមធ្យោបាយអេឡិចត្រូនិក ឬ ឧបករណ៍ផ្សេងទៀត ។

មាត្រា ៥៣.-

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញប្រកាសកំណត់តម្រូវការដោយឡែកនានាពាក់ព័ន្ធនឹងឯកសារ បញ្ជីគណនេយ្យ កំណត់ត្រា និងបណ្តាព័ត៌មានផ្សេងទៀតក្រោមបញ្ញត្តិមាត្រា ៥១ នៃច្បាប់នេះ ។

ជំពូកទី ៩

ទំនិញគ្មានការទាមទារ

មាត្រា ៥៤.-

ទំនិញគ្មានការទាមទារគឺជា :

ក- ទំនិញរក្សាទុកក្នុងទីកន្លែងសន្និធិគយបណ្តោះអាសន្ន ឬ នៅក្នុងភណ្ឌាគារគយមានដែនកំណត់ ដែលហួសរយៈពេលកំណត់ក្រោមបញ្ញត្តិនៃច្បាប់នេះ ។

ខ-ទំនិញផ្ញើតាមប្រៃសណីយ៍ដែលគម្រូជនបដិសេធមិនទទួលយកឬ គម្រូជនពុំត្រូវបានរកឃើញនិងមិនអាចបញ្ជូនទំនិញត្រឡប់ទៅអ្នកផ្ញើវិញបាន ។

គ- ទំនិញ និងមធ្យោបាយដឹកជញ្ជូនពុំជាប់អាយ័ត ដែលស្ថិតនៅក្នុងកន្លែងបញ្ចេញទំនិញពីគយ ហើយម្ចាស់បានបោះបង់ចោលជាលាយល័ក្ខណ៍អក្សរ ។

ប្រសិនបើម្ចាស់ទំនិញត្រូវបានស្គាល់ រដ្ឋបាលគយត្រូវជូនដំណឹងជាបន្ទាន់ដល់ម្ចាស់ទំនិញគ្មានការទាមទារថា ទំនិញទាំងនោះនឹងត្រូវដាក់លក់ដោយដេញថ្លៃជាសាធារណៈស្របតាមបញ្ញត្តិមាត្រា ៥៥ នៃច្បាប់នេះ កាលណាពុំមានការទាមទារក្នុងរយៈពេលបុកសិប (៣០) ថ្ងៃ គិតពីថ្ងៃចេញសេចក្តីជូនដំណឹងនេះ ។

ក្នុងករណីពុំអាចរកម្ចាស់ឃើញ ប្រវេសន៍សាធារណៈត្រូវធ្វើតាមពេល និងរបៀប

ដែលនឹងកំណត់ដោយនាយកទីចាត់ការគយ និងរដ្ឋាករ ដើម្បីជាការជូនដំណឹងដល់ម្ចាស់ទំនិញ ។ ក្នុងរយៈពេលហុកសិប (៦០) ថ្ងៃ គិតចាប់ពីថ្ងៃចេញប្រវេសន៍នេះ ម្ចាស់ទំនិញត្រូវធ្វើការទាមទារទំនិញរបស់ខ្លួន ។ ប្រសិនបើហួសរយៈពេលនេះ ទំនិញនឹងត្រូវដាក់លក់ដោយដេញថ្លៃជាសាធារណៈស្របតាមបញ្ញត្តិនៃមាត្រា ៥៥ នៃច្បាប់នេះ ។

ក្នុងរយៈពេលដូចមានចែងក្នុងកថាខណ្ឌទី ២ និងកថាខណ្ឌទី ៣ នៃមាត្រានេះ ទំនិញគ្មានការទាមទារអាចអនុញ្ញាតឱ្យយកចេញពីគយបាន ក្រោយពីបានបង់ពន្ធ អាករ និងកម្រៃផ្សេងៗ និងទោសទណ្ឌនានា រួមទាំងល័ក្ខខ័ណ្ឌកម្រិតកំណត់ទាំងឡាយត្រូវបានបំពេញរួច ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញប្រកាសកំណត់ករណីដែលទំនិញគ្មានការទាមទារអាចត្រូវបំផ្លាញចោល លក់ដោយដេញថ្លៃជាបន្ទាន់ ត្រូវបោះបង់ចោល ឬត្រូវប្រើប្រាស់សម្រាប់ប្រយោជន៍សាធារណៈផ្អែកតាមលក្ខណៈ ឬ តម្លៃទាបនៃទំនិញដោយធ្វើសេចក្តីជូនដំណឹងជាលាយល័ក្ខណ៍អក្សរជូនម្ចាស់ទំនិញ ឬ ចេញប្រវេសន៍សាធារណៈប្រសិនបើរកម្ចាស់ពុំឃើញ ។

មាត្រា ៥៥.-

ការលក់ទំនិញគ្មានការទាមទារ ត្រូវដាក់លក់ដោយដេញថ្លៃជាសាធារណៈ ។

នាយកទីចាត់ការគយ និងរដ្ឋាករ អាចកំណត់ថ្លៃអប្បបរមាបានសម្រាប់ទំនិញដែលត្រូវដាក់លក់ដោយដេញថ្លៃ ។ ប្រសិនបើទំនិញមិនអាចត្រូវលក់ដាច់តាមថ្លៃនេះទេ នាយកទីចាត់ការគយ និងរដ្ឋាករ អាចកំណត់ថ្លៃអប្បបរមាថ្មីមួយ ឬ សុំការសម្រេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបោះបង់ចោល ឬ ទុកប្រើប្រាស់សម្រាប់ផលប្រយោជន៍សាធារណៈ ។

ផលបានមកពីការលក់ត្រូវទូទាត់សងប្រាក់ពន្ធ និងអាករ ដែលមិនទាន់បានបង់ កម្រៃ និងបន្ទុកផ្សេងៗ និងចំណាយរៀបចំការដាក់លក់ ដោយដេញថ្លៃ ។ ម្ចាស់ទំនិញអាចទាមទារយកនូវទឹកប្រាក់នៅសល់ក្រោយពីការទូទាត់នេះបាន ក្នុងរយៈពេលប្រាំមួយ (៦) ខែ តាមសេចក្តីជូនដំណឹងរបស់រដ្ឋបាលគយ ដែលត្រូវធ្វើឡើងក្នុងរង្វង់រយៈពេលប្រាំពីរ (៧) ថ្ងៃ បន្ទាប់ពីការលក់ដោយដេញថ្លៃ ។ ហួសរយៈពេលកំណត់នេះ ប្រសិនជាមិនមាន

ការទាមទារយកទឹកប្រាក់នេះទេ នឹងក្លាយជាទ្រព្យសម្បត្តិរបស់រដ្ឋ ។

ជំពូកទី ១០
សិទ្ធិអំណាច និង ភារកិច្ច

មាត្រា ៥៦.-

មន្ត្រីគយមានសិទ្ធិអំណាចដូចមានចែងក្នុងច្បាប់នេះនៅក្នុងវង់អំណាចគយ ។ ក្នុងករណីដែលទំនិញត្រូវបានកំណត់ក្រោមបញ្ញត្តិនៃកថាខណ្ឌទី ២ ក្នុងមាត្រា ៨ នៃច្បាប់នេះ សិទ្ធិអំណាចរបស់មន្ត្រីគយត្រូវគ្របដណ្តប់នៅទូទាំងដែនគយ ។

ចំពោះទំនិញនាំចេញ ឬ នាំចូល មន្ត្រីគយមានសិទ្ធិអំណាចដូចតទៅ :

ក-ពិនិត្យទំនិញ ហើយបើក ឬ បញ្ជាឱ្យបើកកញ្ចប់ណាមួយ ឬ កុងតឺន័រទំនិញនិងអាចដកយកទំនិញបាន តាមចំនួនសមស្របសម្រាប់ការពិនិត្យ ។

ខ- ឃាត់ បញ្ឈប់ ឡើង ចូល និងត្រួតពិនិត្យឆែកឆេរ មធ្យោបាយដឹកជញ្ជូនទំនិញណាមួយ និងបញ្ជាឱ្យនាំមធ្យោបាយដឹកជញ្ជូនទំនិញនោះទៅការិយាល័យគយ ឬ ទីកន្លែងសមរម្យផ្សេងទៀតដើម្បីធ្វើការត្រួតពិនិត្យឆែកឆេរ ។

គ-ឆែកឆេរលំនៅស្ថានឯកជន ឬ ទីកន្លែងធុរកិច្ច ដើម្បីប្រមូលភស្តុតាង ឬឃាត់ទុកទំនិញជាបណ្តោះអាសន្ន តាមបទប្បញ្ញត្តិ និងច្បាប់នានានៃព្រះរាជាណាចក្រកម្ពុជាក្នុងករណីមានការសង្ស័យដែលមានមូលដ្ឋានគួរឱ្យទុកចិត្តបានថាមានការប្រព្រឹត្តបទល្មើស ។

ឃ- ត្រួតពិនិត្យអត្តសញ្ញាណជនណាមួយដែលចូល ចេញដែនគយ ឃាត់ បញ្ឈប់ សួរ និងឆែកឆេរជននោះ ប្រសិនបើមន្ត្រីគយសង្ស័យថា ជននោះមានលាក់ទំនិញ ឬ របស់អ្វីផ្សេងទៀតនៅជុំវិញខ្លួននិងនៅក្នុងខ្លួនរបស់គេ ដែលអាចជាភស្តុតាងនៃការរំលោភច្បាប់នេះ ឬ ច្បាប់ផ្សេងទៀតនៃព្រះរាជាណាចក្រកម្ពុជា ។

ចំណាយលើការត្រួតពិនិត្យដូចមានចែងក្នុងវាក្យខណ្ឌ ក និងវាក្យខណ្ឌ ខ កថាខណ្ឌទី ២ នៃមាត្រានេះ ជាបន្ទុករបស់ម្ចាស់ ឬ អ្នកទទួលកាន់កាប់ទំនិញ ឬ មធ្យោបាយដឹកជញ្ជូន

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

35/46

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញប្រកាសកំណត់នីតិវិធីសម្រាប់ការធ្វើអធិការកិច្ច និងការត្រួតពិនិត្យ ។

មាត្រា ៥៧.-

តាមពេលវេលាដែលច្បាប់អនុញ្ញាត មន្ត្រីគយមានសិទ្ធិចូលក្នុងទីតាំង ឬ ទីកន្លែងដែលរក្សាទុកឯកសារដូចមានចែងក្នុងមាត្រា ៥១ នៃច្បាប់នេះ ហើយមានសិទ្ធិធ្វើសវនកម្ម ឬពិនិត្យឆែកឆេរឯកសារទាំងនោះ ដែលពាក់ព័ន្ធនឹងកិច្ចចម្លងការដោយឡែក ឬភាពត្រឹមត្រូវ និងអាចទទួលយកបាននៃប្រព័ន្ធកត់ត្រាដោយដៃ ឬ ប្រព័ន្ធអេឡិចត្រូនិក ដែលនៅក្នុងប្រព័ន្ធនោះ ឯកសារទាំងនេះត្រូវបានបង្កើត និងរក្សាទុក ។

មន្ត្រីគយអាចធ្វើអធិការកិច្ចបានលើឯកសារ កំណត់ត្រា និងព័ត៌មានផ្សេងទៀត ឬ ទ្រព្យសម្បត្តិ កិច្ចដំណើរការ ឬ កិច្ចការផ្សេងទៀត ដែលមន្ត្រីគយយល់ថាចាំបាច់ និងពាក់ព័ន្ធនឹងគោលដៅនៃការប្រមូលពន្ធ និង អាករក្រោមបញ្ញត្តិនៃច្បាប់នេះ សម្រាប់អនុវត្តតាមគោលបំណងបំពេញនូវភារកិច្ចរបស់មន្ត្រីគយ ឬ ក្នុងគោលបំណងនៃការប្រមូលព័ត៌មានដែលតម្រូវដោយច្បាប់នេះ ។

មន្ត្រីគយមានសិទ្ធិចេញ និងចូលទៅគ្រប់ទីតាំង កន្លែង អគារ និង ទីកន្លែងនានា ព្រមទាំងមានសិទ្ធិឆែកឆេរ ឯកសារ កំណត់ត្រា និងព័ត៌មានផ្សេងទៀត ទោះបីជាស្ថិតក្រោមការគ្រប់គ្រង ត្រួតពិនិត្យរបស់អ្នកទទួលបានអាជ្ញាប័ណ្ណ អ្នកនាំចេញ ឬ អ្នកនាំចូល ឬ បុគ្គលណាផ្សេងទៀត ។

មន្ត្រីគយអាចដកស្រង់ព័ត៌មាន ឬ ថតចម្លងនូវកំណត់ត្រា ឬ ឯកសារនានាដកហូតយកដោយមានកំណត់ហេតុនិងរក្សាទុកឯកសារដែលបានបង្ហាញពាក់ព័ន្ធនឹងការប្រកាសណាមួយ ឬ តាមតម្រូវការនៃច្បាប់នេះ ដោយគ្មានជាប់បន្ទុកចំណាយអ្វីឡើយ ។

តាមសំណើរបស់ជនដែលកាន់កាប់ឯកសារ មន្ត្រីគយត្រូវផ្តល់ដល់ជននោះនូវឯក-សារថតចម្លងត្រឹមត្រូវដោយមានការបញ្ជាក់ពីរដ្ឋបាលគយ ។

មាត្រា ៥៨.-

មន្ត្រីគយដែលបានសច្ចាប្រណិធាន អាចបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌បាន លុះត្រាតែសាមីខ្លួនបានទទួលនីតិសម្បទាពីអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

មន្ត្រីគយដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ត្រូវធ្វើ និងចុះហត្ថលេខាលើកំណត់ហេតុបទល្មើសគយតាមដែនសមត្ថកិច្ចរបស់ខ្លួន ។

នៅពេលបំពេញបេសកកម្មស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសគយ មន្ត្រីគយត្រូវមានលិខិតបញ្ជាបេសកកម្ម និងត្រូវស្លៀកពាក់ឯកសណ្ឋាន ពាក់សញ្ញាសម្គាល់ ពាក់ឋានន្តរសក្តិ លើកលែងតែមានការណែនាំដោយឡែកពីនាយកទីចាត់ការគយ និងរដ្ឋាករ ។

សំលៀកបំពាក់ឯកសណ្ឋាន សញ្ញាសម្គាល់ និងឋានន្តរសក្តិរបស់មន្ត្រីគយត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៥៩.-

មន្ត្រីគយមានសិទ្ធិកាន់ និងប្រើប្រាស់អាវុធក្នុងពេលបំពេញភារកិច្ចតាមកាលៈទេសៈដូចតទៅ ៖

-សម្រាប់ការពារខ្លួនស្របច្បាប់

-បើពុំអាចឃាត់ បញ្ឈប់ មធ្យោបាយដឹកជញ្ជូន ដែលសង្ស័យថា ពាក់ព័ន្ធនឹងការរត់ពន្ធ ឬសកម្មភាពល្មើសផ្សេងទៀត ដែលអ្នកបើកបរពុំព្រមឈប់តាមការបញ្ជាឱ្យឈប់

- សម្រាប់ហេតុផលផ្សេងទៀត ដូចមានចែងក្នុងបទប្បញ្ញត្តិ និង ច្បាប់នានានៃព្រះរាជាណាចក្រកម្ពុជា ។

អាវុធដែលមន្ត្រីគយ និងរដ្ឋាករ ប្រើប្រាស់ក្នុងកិច្ចប្រតិបត្តិការបំពេញភារកិច្ចត្រូវបានបំពាក់ និងគ្រប់គ្រងដោយក្រសួងមហាផ្ទៃ ។

មាត្រា ៦០.-

មន្ត្រីគយដែលបានសច្ចាប្រណិធានមានលក្ខណៈសម្បត្តិជានគរបាលយុត្តិធម៌អាចសម្រេចឃាត់ខ្លួនបានក្នុងរយៈពេលសែសិបប្រាំបី (៤៨) ម៉ោងយ៉ាងយូរ ដោយអនុវត្តស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌ ។

មាត្រា ៦១.-

ជនគ្រប់រូបមិនត្រូវបង្កឧបសគ្គ ឬ ធ្វើឱ្យរាំងស្ទះដល់មន្ត្រីគយក្នុងការប្រើអំណាចស្របច្បាប់របស់ខ្លួនដូចមានចែងក្នុងច្បាប់នេះ ឬ ច្បាប់ផ្សេងទៀតនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៦២.-

អ្នកបើកបរមធ្យោបាយដឹកជញ្ជូន ក្នុងការធ្វើចលនាមធ្យោបាយដឹកជញ្ជូនរបស់ខ្លួន ត្រូវគោរពតាមបញ្ជារបស់មន្ត្រីគយ ។

មន្ត្រីគយអាចប្រើប្រាស់បរិក្ខារសមស្រប ដើម្បីឃាត់បញ្ឈប់មធ្យោបាយដឹកជញ្ជូន កាលបើអ្នកបើកបរមិនឈប់តាមការបញ្ជាឱ្យឈប់ ។

នៅពេលមានការស្នើសុំអាជ្ញាធរមានសមត្ថកិច្ច នគរបាល និង យោធា ត្រូវជួយជាបន្ទាន់ដល់មន្ត្រីគយក្នុងការបំពេញភារកិច្ចរបស់ខ្លួនដូចមានចែងក្នុងច្បាប់នេះ ។

មាត្រា ៦៣.-

មន្ត្រីគយមិនត្រូវចូលរួមក្នុងសកម្មភាពពាណិជ្ជកម្ម តាមរបៀបពាក់ព័ន្ធ ឬ ទំនាស់ជាមួយនឹងភារកិច្ចផ្លូវការរបស់ខ្លួន ។

ព័ត៌មានដែលទទួលបានដោយមន្ត្រីគយនៅក្នុងការគ្រប់គ្រង ឬ ការអនុវត្តច្បាប់នេះអាចប្រើប្រាស់បានសម្រាប់តែគោលបំណងដែលមានចែងក្នុងច្បាប់នេះ លើកលែងតែមានការអនុញ្ញាតដោយឡែក ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ៦៤.-

មន្ត្រីគយដែលប្រព្រឹត្តបទល្មើសលើច្បាប់នេះនិងបញ្ញត្តិផ្សេងទៀត នឹងត្រូវទទួលការផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

មាត្រា ៦៥.-

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញប្រកាសកំណត់លក្ខខណ្ឌនានាពាក់ព័ន្ធនឹងការផ្តល់រង្វាន់លើកទឹកចិត្តដល់មន្ត្រីគយដែលមានស្នាដៃ និងដល់បណ្តាស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ រាប់បញ្ចូលទាំងកងកម្លាំងប្រដាប់អាវុធនៃកងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ អាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ព្រមទាំងជនទាំងឡាយណាដែលបានចូលរួមសហការ និងគាំទ្រដល់រដ្ឋបាលគយក្នុងការអនុវត្តច្បាប់នេះ ។

មាត្រា ៦៦.-

មន្ត្រីគយមានសិទ្ធិឃាត់ទុកបណ្ដោះអាសន្ននូវទំនិញ និងមធ្យោបាយដឹកជញ្ជូនដែលចូលរួមក្នុងការរំលោភបំពានលើបទប្បញ្ញត្តិនានានៃច្បាប់នេះ ។ ទំនិញ និងមធ្យោបាយដឹកជញ្ជូនទាំងនោះ អាចជាកម្មវត្ថុនៃការរឹបអូសដោយតុលាការមានសមត្ថកិច្ច ។

នៅក្រៅវង់អំណាចគយ ការឃាត់ទុកបណ្ដោះអាសន្ន អាចត្រូវធ្វើឡើងនៅក្នុងការិយាល័យគយ កន្លែងសន្និធិគយបណ្ដោះអាសន្ន ភណ្ឌាគារគយមានដែនកំណត់ និងកន្លែងផ្សេងទៀត ដែលស្ថិតនៅក្រោមអនុរក្សរបស់រដ្ឋបាលគយ ។

ទំនិញដូចមានចែងនៅក្នុងកថាខណ្ឌទី ២ មាត្រា ៨ នៃច្បាប់នេះ អាចត្រូវបានឃាត់ទុកជាបណ្ដោះអាសន្ននៅគ្រប់ទីកន្លែងក្នុងដែនគយ ។

ការឃាត់ទុកបណ្ដោះអាសន្ន អាចត្រូវបានអនុវត្តផងដែរនៅគ្រប់ទីកន្លែងក្នុងដែនគយ ក្នុងករណីមានការដេញប្រជាប់ចាប់ប្រភឹង ឬ ការរកឃើញដោយចៃដន្យនូវទំនិញដែលមិនស៊ីគ្នានឹងការប្រកាស ឬឯកសារដែលមានជាប់នឹងអ្នកកាន់កាប់ ។

មន្ត្រីគយមានសិទ្ធិថតចម្លង ឬ ដកហូតឯកសារ ឬវត្ថុផ្សេងៗទៀត ដែលជាភ័ស្តុតាងនៃការរំលោភបំពានច្បាប់នេះ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញប្រកាសកំណត់នីតិវិធីពាក់ព័ន្ធនឹងការឃាត់ទុកបណ្ដោះអាសន្ននូវទំនិញ មធ្យោបាយដឹកជញ្ជូន ឯកសារ និងវត្ថុផ្សេងៗទៀត ព្រមទាំងការថតចម្លងឯកសារទាំងនោះ ។

មាត្រា ៦៧.-

ឱ្យតែកាលៈទេសៈបើកឱ្យធ្វើបាន ទំនិញ មធ្យោបាយដឹកជញ្ជូន ឬវត្ថុដែលបានឃាត់ទុកបណ្ដោះអាសន្នផ្សេងៗត្រូវបញ្ជូនមកការិយាល័យគយដែលនៅជិតបំផុតនឹងកន្លែងដែលបានឃាត់ទុកនោះ ។ ប្រសិនបើមានការិយាល័យគយច្រើនស្ថិតក្នុងតំបន់តែមួយ វត្ថុឃាត់ទុកបណ្ដោះអាសន្នអាចត្រូវបានដឹកជញ្ជូនទៅការិយាល័យណាមួយក៏បាន ។ កាលបើមិនអាចនាំយកភ្លាមទៅកាន់ការិយាល័យគយ ឬ បើពុំមានការិយាល័យគយនៅក្នុងតំបន់នោះ ទេ វត្ថុឃាត់ទុកបណ្ដោះអាសន្នអាចត្រូវបានប្រគល់ឱ្យជនជាប់ចោទ ឬ តតិយជននៅកន្លែងឃាត់ទុក ឬ កន្លែងផ្សេងទៀតជាអ្នកថែរក្សាទុក ។

39/45

ប្រសិនទំនិញឃាត់ទុកបណ្តោះអាសន្ន មិនជាប់អាយ័ត ទំនិញ មធ្យោបាយដឹកជញ្ជូន ឯកសារ និងវត្ថុចាប់ឃាត់ផ្សេងទៀតមិនតម្រូវសម្រាប់ជាភស្តុតាង វត្ថុឃាត់ទុកទាំងនេះអាចត្រូវបានប្រគល់ទៅម្ចាស់ក្រោយ ពេលបានតម្កល់នូវនិម្មិត្តធានាដូចមានចែងក្រោមបញ្ញត្តិមាត្រា ៤១ នៃច្បាប់នេះ ។

ទំនិញឃាត់ទុកបណ្តោះអាសន្នដែលមិនជាប់អាយ័ត ឬ កម្រិតកំណត់មធ្យោបាយដឹកជញ្ជូន ឬ វត្ថុផ្សេងទៀតដែលប្រើប្រាស់សម្រាប់លាក់បំពាំង ឬ ដឹកជញ្ជូនទំនិញទាំងនោះ ត្រូវប្រគល់ជូនម្ចាស់វិញ បន្ទាប់ពីបានបង់ពន្ធ អាករ បន្ទុកផ្សេងៗ និងប្រាក់ពិន័យគ្រប់ចំនួន ។

មាត្រា ៦៨.-

មន្ត្រីគយដែលធ្វើការឃាត់ទំនិញ ត្រូវធ្វើកំណត់ហេតុឃាត់ទុកដោយមិនបង្អែបង្អង់ ។

បើជនល្មើសវត្តមាន ត្រូវចុះក្នុងកំណត់ហេតុថា បានអានសេចក្តីឱ្យសាមីខ្លួនស្តាប់ បានហៅសាមីខ្លួនឱ្យអាន និងចុះហត្ថលេខា ព្រមទាំងបានផ្តល់ជាបន្ទាន់នូវកំណត់ហេតុមួយច្បាប់ដល់ជននោះ ។

បើជនល្មើសអវត្តមាន សេចក្តីចម្លងកំណត់ហេតុត្រូវបិទផ្សាយក្នុងរង្វង់ម្ភៃបួន (២៤) ម៉ោង បន្ទាប់ពីកំណត់ហេតុត្រូវបានធ្វើរួចនៅការិយាល័យគយជិតបំផុត ឬ នៅការិយាល័យអាជ្ញាធរមូលដ្ឋានជិតបំផុត ប្រសិនបើទីនោះ គ្មានការិយាល័យគយ ។

សេចក្តីលម្អិតនានាពាក់ព័ន្ធនឹងទម្រង់ខ្លឹមសារ នីតិវិធី សម្រាប់ការរៀបចំ និងការដាក់ជូនទៅតុលាការនៃកំណត់ហេតុដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

មាត្រា ៦៩.-

ក្នុងករណីការឃាត់ទុកត្រូវបានធ្វើឡើងលើនាវា និងកប៉ាល់មានជាន់ថ្នាក់ កាលបើការរើទំនិញចេញពុំអាចធ្វើបានភ្លាម អ្នកឃាត់ទុកត្រូវបិទត្រាគយលើសន្ទះ យ្ហប់ និងតម្រប នៃនាវានោះ ។

មាត្រា ៧០.-

ក្នុងករណីដែលការឃាត់ទុកត្រូវបានធ្វើនៅក្នុងលំនៅស្ថាន ទំនិញមិនជាប់អាយ័ត

៤

មិនត្រូវនាំយកទៅទីណាឡើយ បើជនជាប់ចោទបានតម្កល់និមុត្តិធានា ស្របតាមបញ្ញត្តិមាត្រា ៤១ នៃច្បាប់នេះ ។ ប្រសិនបើជនជាប់ចោទមិនបានតម្កល់និមុត្តិធានា ឬ បើជាទំនិញជាប់អាយ័ត ទំនិញនោះត្រូវដឹកជញ្ជូនទៅកាន់ការិយាល័យគយជិតបំផុត ឬ ប្រគល់ឱ្យតតិយ-ជនថែរក្សានៅកន្លែងឃាត់ទុក ឬ នៅកន្លែងផ្សេងទៀត ។

មាត្រា ៧១.-

បុគ្គលដែលត្រូវរងនូវទោសទណ្ឌ ឬ ការឃាត់ទុកនូវទំនិញ មធ្យោបាយដឹកជញ្ជូន ឬវត្ថុផ្សេងទៀត អាចតវ៉ាជាលាយលក្ខណ៍អក្សរទៅនាយកទីចាត់ការគយ និងរដ្ឋាករក្នុងអំឡុងពេលសាមសិប (៣០) ថ្ងៃ ក្រោយបានទទួលសេចក្ដីជូនដំណឹងពីទោសទណ្ឌ ឬ ការឃាត់ទុក ដោយបញ្ជាក់ពីមូលហេតុនៃការតវ៉ា និងតម្កល់និមុត្តិធានាស្របតាមបញ្ញត្តិមាត្រា ៤១ នៃច្បាប់នេះ ។

នាយកទីចាត់ការគយ និងរដ្ឋាករ ត្រូវចេញសេចក្ដីសម្រេចលើការតវ៉ាក្នុងអំឡុងពេលហុកសិប (៦០) ថ្ងៃ គិតចាប់ពីថ្ងៃដែលបានទទួលពាក្យតវ៉ា បើមិនដូច្នោះទេ ការតវ៉ានោះត្រូវបានចាត់ទុកថាបានទទួលការយល់ព្រម ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញប្រកាសកំណត់នីតិវិធីពាក់ព័ន្ធនឹងដំណើរការតវ៉ានេះ ។

ជំពូកទី ១១

ទោសប្បញ្ញត្តិ

មាត្រា ៧២.-

បុគ្គលណាដែលនាំចេញ ឬ នាំចូល ឬ ប៉ុនប៉ងនាំចេញ ឬ ប៉ុនប៉ងនាំចូលទំនិញដោយរំលោភបំពានលើច្បាប់ ឬ បញ្ញត្តិនានា ត្រូវចាត់ទុកថាបានប្រព្រឹត្តបទល្មើស ។

បុគ្គលណាដែលប្រព្រឹត្តបទល្មើសគយ ត្រូវផ្តន្ទាទោសពិន័យរដ្ឋបាលដែលកំណត់ដោយរដ្ឋបាលគយ និងទោសទណ្ឌតាមផ្លូវតុលាការដែលកំណត់ ដោយតុលាការមានសមត្ថ-កិច្ច ឬ ទោសណាមួយនៃទោសទាំងពីរ ។

មាត្រា ៧៣.-

ជនណាដែលរំលោភបំពានកម្រិតទាបលើបញ្ញត្តិ និងបទប្បញ្ញត្តិនៃច្បាប់នេះដោយរាប់បញ្ចូលទាំងការចុះមិនត្រឹមត្រូវ ការភ្លេច ឬ ការខកខានចុះនូវសូចនាករណាមួយ ដែលត្រូវរៀបរាប់ក្នុងប្រតិវេទន៍គយ និងការខកខានបំពេញការតម្រូវ និងកាតព្វកិច្ចនានាដែលមិនប៉ះពាល់ដល់ពន្ធ អាករ អាយ័តភាព ឬការកម្រិតកំណត់ ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពីមួយរយពាន់(១០០.០០០) រៀល ទៅប្រាំរយពាន់ (៥០០.០០០) រៀល ប្រសិនបើអនិយ័តភាពនេះមិនត្រូវបានរងការពិន័យធ្ងន់ធ្ងរជាងនៅក្នុងច្បាប់នេះ ។

មាត្រា ៧៤.-

ជនណាដែលរំលោភបំពានលើបញ្ញត្តិ និងបទប្បញ្ញត្តិនៃច្បាប់នេះ ដោយរាប់បញ្ចូលទាំងការរំលោភដូចមានចែងក្នុងមាត្រា ៧៣ នៃច្បាប់នេះ ដែលមានផលប៉ះពាល់ដល់ពន្ធ ឬ អាករ និងក្នុងករណីដែលទំនិញពុំជាប់អាយ័ត ឬ កម្រិតកំណត់ ត្រូវផ្ដន្ទាទោសរដ្ឋបាលដោយពិន័យជាប្រាក់ស្មើនឹងមួយ (១) ដង ទៅ បី(៣) ដង នៃប្រាក់ពន្ធ និងអាករដែលបានគេចវេះ និង ត្រូវរងនូវទោសទណ្ឌតាមផ្លូវតុលាការ ដោយត្រូវរឹបអូសទំនិញ មធ្យោបាយដឹកជញ្ជូន និងវត្ថុផ្សេងទៀតដែលប្រើសម្រាប់លាក់បិទបាំងទំនិញល្មើស ឬ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពីមួយ (១) ខែ ទៅមួយ (១) ឆ្នាំ ឬ ទោសណាមួយនៃទោសទាំងពីរ ។

ត្រូវបានចាត់ទុកជាប្រភេទបទល្មើស ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ :

ក-ការខកខានរាយការណ៍អំពីទំនិញជូនរដ្ឋបាលគយ ស្របតាមបញ្ញត្តិមាត្រា ១០ និងមាត្រា ១៦ នៃច្បាប់នេះ ។

ខ-ការរើទំនិញចេញពីមធ្យោបាយដឹកជញ្ជូន មុនពេលរាយការណ៍ជូនរដ្ឋបាលគយដូចមានចែងក្នុងបញ្ញត្តិមាត្រា ១២ នៃច្បាប់នេះ ។

គ-ការបើក ការហែក គាស់ ការធ្វើឱ្យបើក ឬហែកកញ្ចប់ទំនិញនាំចូល ដែលមិនទាន់ទទួលបានការអនុញ្ញាតពីរដ្ឋបាលគយឱ្យយកចេញ ការធ្វើឱ្យបែកបាក់ ខូចខាតត្រា សោ ដែលបានចាក់ ឬ បិទភ្ជាប់លើទំនិញ មធ្យោបាយដឹកជញ្ជូន កន្លែងសន្និធិគយឃ្លាំងអាសន្ន ភណ្ឌាគារគយមានដែនកំណត់ ឬ កន្លែងផ្សេងទៀតដែលតម្រូវដោយច្បាប់នេះ ។

ឃ-ការយកទំនិញចេញពីកន្លែងបំពេញបែបបទបញ្ចេញទំនិញពីគយ កន្លែងសន្និធិគយបណ្តោះអាសន្ន ឬ ភណ្ឌាគារគយមានដែនកំណត់ ដោយគ្មានការអនុញ្ញាតពីរដ្ឋបាលគយ ។

ង-ការខកខានដាក់ប្រតិវេទន៍គយស្របតាមបញ្ញត្តិមាត្រា ២៩ នៃច្បាប់នេះ ។

ច-ការខកខានបំពេញតាមបញ្ញត្តិមាត្រា ៣០ នៃច្បាប់នេះ ។

ឆ- ការលក់ ការផ្ទេរ ការបង្វែរ ឬ ការបោះបង់ចោលទំនិញនាំចូល ដែលបានទទួលការលើកលែងពន្ធ និងអាករផ្សេងៗ ដូចចែងក្នុងមាត្រា ២៦ និងមាត្រា ២៧ នៃច្បាប់នេះដោយគ្មានការអនុញ្ញាតពីរដ្ឋបាលគយ ។

ជ-ការខកខានអនុវត្តតាមល័ក្ខខ័ណ្ឌដែលកំណត់ដោយរដ្ឋបាលគយ ពាក់ព័ន្ធនឹងទំនិញដែលស្ថិតក្រោមរបបព្យួរពន្ធ និងអាករ ស្របតាមបញ្ញត្តិនៃច្បាប់នេះ ។

ឈ-ការប្រព្រឹត្ត ការយល់ព្រម ឬ ចូលរួមក្នុងការប្រកាសដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរដែលនាំឱ្យមានភាពមិនត្រឹមត្រូវ ក្លែងបន្លំ ឬ បោកបញ្ឆោតដែលផ្ទុយនឹងច្បាប់នេះ ។

ញ-ការរត់ពន្ធ ឬ ការប៉ុនប៉ងរត់ពន្ធទំនិញ ។

ដ- ការកាន់កាប់ លក់ ទិញ ផ្ទេរ ឬ ទទួលដោយគ្មានការអនុញ្ញាតពីរដ្ឋបាលគយនូវទំនិញដែលបាននាំចូលដោយរំលោភនឹងបញ្ញត្តិនៃច្បាប់នេះ ។

ជនណាប្រព្រឹត្តបទល្មើសដូចខាងក្រោម ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលាន (១.០០០.០០០)រៀល ដល់ប្រាំលាន(៥.០០០.០០០)រៀល និងផ្តន្ទាទោសដាក់ពន្ធនាគារពីមួយ (១) ខែ ដល់ប្រាំមួយ (៦) ខែ ឬ ទោសណាមួយនៃទោសទាំងពីរនេះ :

ក-ការខកខានបំពេញតាមបញ្ញត្តិ ដូចមានចែងក្នុងមាត្រា ៥១ មាត្រា ៥២ និងមាត្រា ៥៣ នៃច្បាប់នេះ ។

ខ-ជនណាដែលបង្កឧបសគ្គ ឬ ធ្វើឱ្យរាំងស្ទះដល់មន្ត្រីគយ តាមបញ្ញត្តិដូចមានចែងក្នុងមាត្រា ៦១ នៃច្បាប់នេះ ។

គ-អ្នកបើកបរមធ្យោបាយដឹកជញ្ជូនដែលមិនគោរពតាមបញ្ជារបស់មន្ត្រីគយ ស្របតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ក្នុងមាត្រា ៦២ នៃច្បាប់នេះ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

43/45

មាត្រា ៧៥.-

ជនណាដែលរំលោភបំពានលើបញ្ញត្តិ និងបទប្បញ្ញត្តិនៃមាត្រា ៧៤ នៃច្បាប់នេះ ដែលពាក់ព័ន្ធនឹងទំនិញជាប់កម្រិតកំណត់ ឬ ជាប់អាយ័តដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រា ៨ នៃច្បាប់នេះ លើកលែងតែវាក្យខណ្ឌ ជ នៃកថាខណ្ឌទី ១ ក្នុងមាត្រា ៧៤ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសរដ្ឋបាល ដោយពិន័យជាប្រាក់រហូតដល់ បី (៣) ដង នៃតម្លៃទំនិញនិងមធ្យោបាយដឹកជញ្ជូន និងត្រូវរងទោសទណ្ឌតាមផ្លូវតុលាការ ដោយរឹបអូសទំនិញ មធ្យោបាយដឹកជញ្ជូន និងវត្ថុផ្សេងទៀត ដែលប្រើប្រាស់សម្រាប់លាក់បំបាំងទំនិញល្មើស ឬ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយ (១) ឆ្នាំ ដល់ ប្រាំ (៥) ឆ្នាំ ឬ ទោសណាមួយនៃទោសទាំងពីរ ។

មាត្រា ៧៦.-

ក្នុងករណីមិនរាងចាល បទល្មើសដូចមានចែងក្នុងច្បាប់នេះត្រូវផ្តន្ទាទោសទ្វេឡើង ទាំងទោសពិន័យរដ្ឋបាល ទាំងទោសទណ្ឌតាមផ្លូវតុលាការ ។

មាត្រា ៧៧.-

រដ្ឋបាលគយមានសិទ្ធិសម្រុះសម្រួល ចំពោះបទល្មើសគយដែលមានចែងក្នុងច្បាប់នេះ ។ សិទ្ធិសម្រុះសម្រួលនេះ ប្រើប្រាស់ចំពោះតែការពិន័យជាប្រាក់តែប៉ុណ្ណោះ ។ ក្នុងករណីមិនអាចសម្រុះសម្រួលបានរដ្ឋបាលគយ ត្រូវបញ្ជូនសំណុំរឿងនេះទៅតុលាការមានសមត្ថកិច្ច ។

ការសម្រុះសម្រួលអាចធ្វើទៅបាន នៅមុនពេលមានសាលក្រមរបស់តុលាការមានសមត្ថកិច្ច ។

លក្ខខណ្ឌសម្រាប់អនុវត្តសិទ្ធិក្នុងការសម្រុះសម្រួលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ROYAUME DU CAMBODGE LE MINISTERE DU PALAIS ROYAL

ក្រសួងព្រះបរមរាជវាំង

ฯ

4445

ជំពូកទី ១២

អន្តរប្បញ្ញត្តិ

មាត្រា ៧៨.–

ការអនុវត្តបញ្ញត្តិដូចមានចែងក្នុងមាត្រា ២១ និងមាត្រា ៦២ នៃច្បាប់នេះ ដែលពាក់ព័ន្ធនឹងការកំណត់តម្លៃគិតពន្ធគយអាចត្រូវបានពន្យារតាមកាលៈទេសៈជាក់ស្តែង ។

ជំពូកទី ១៣

អវសានប្បញ្ញត្តិ

មាត្រា ៧៩.–

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៨០.–

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី *២០* ខែ*កក្កដា* ឆ្នាំ ២០០៧

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស/រកម.០៧០៧.០១០

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា

គាត ឈន់

ព្រះរាជក្រឹត្យ

នស/រកត/០៨០៧/៣២២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូនលោកវរសេនីយ៍ឯក **សួន ផល្លា** អត្តលេខ ០៦០១២ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ៕

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រល.០៧០៨.៣៤៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ.ថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០០៧

លេខ: ៣៣០៤.ល
ជំរឿនជូនចែក
រាជធានីភ្នំពេញ.ថ្ងៃទី០៣ ខែ សីហា ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ុំ ជីនកេន

នស/រកត/០៨០៧/៣២៣

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ជាកិច្ចបច្ឆាមរណៈ

ចំពោះ

សពឯកឧត្តម ឧត្តមសេនីយ៍ឯក ពត សុខ

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រល.០៧០៩.៣៤៦

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ, ថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០០៧

លេខៈ ៣៣២ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៨០៧/៣២៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានលុបឈ្មោះឯកឧត្តម នួច ភានុន ឧត្តមមន្ត្រី ថ្នាក់លេខ ៤ និងជាអគ្គលេខាធិការក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ចេញពីក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៃទីស្តីការគណៈរដ្ឋមន្ត្រី ដោយមូលហេតុ ទទួលមរណភាព ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្ត អោយបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

លេខ ៣៣៣ ច.ល

ដើម្បីចម្លងចែកចាយ

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែសីហា ឆ្នាំ២០០៧

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ជិនកេន

៣៤.០៧០៨.៣៤៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០០៧

ព្រះរាជក្រឹត្យ

នស/រកត/០៨០៧/៣២៥

ស្តីពី

រូបសញ្ញាអប់រំ យុវជន និងកីឡា សញ្ញាសក្តិ ឯកសណ្ឋាន និងសក្តិខ្វាស់លើអាវ ឬ ក្រមាពាន់ សម្រាប់មន្ត្រីអប់រំ ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម និងក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពី គោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤០ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤១ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី ដែលបានឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៧

ភ្ជាប់បន្ទាប់

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា១.-

ត្រូវបានបង្កើតរូបសញ្ញាអប់រំ យុវជន និងកីឡា សញ្ញាសក្តិ ឯកសណ្ឋាន និងសក្តិខ្វាស់លើអាវ ឬ ក្រមាពានា សម្រាប់សម្គាល់មន្ត្រីអប់រំ ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម និងក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន ដែលបម្រើការនៅក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

ជំពូកទី ២

រូបសញ្ញាអប់រំ យុវជន និងកីឡា

មាត្រា២.-

រូបសញ្ញាអប់រំ យុវជន និងកីឡា ត្រូវបានកំណត់ដូចតទៅ ÷

- មានរាងរង្វង់មូល ព័ទ្ធជុំវិញដោយក្បាច់ភ្ញីទេសពណ៌មាស

- មានទទឹងប្រវែង ៤ភាគ៥ នៃកម្ពស់

- ផ្ទៃកខាងក្នុងរង្វង់មូលមានផ្ទៃពណ៌ផ្ទៃមេឃ ដែលរំលេចដោយកាំរស្មីពណ៌មាស ចាំងបំភ្លឺគ្រប់ទិសទី

-នៅខាងក្រោមចំកណ្តាល មានកំណាត់ខ្សែបូពណ៌ផ្ទៃមេឃ និងតែមពណ៌មាសដែលចារឹក ដោយអក្សរពណ៌មាស ថា ក្រសួងអប់រំ យុវជន និងកីឡា

- នៅចំកណ្តាល ពីលើកម្រងផ្កាក្បាច់ភ្ញីទេស មានកងរង្វង់មូលទ្រភ្លើងគុបពណ៌មាស។

រូបសញ្ញាអប់រំ យុវជន និងកីឡា សម្រាប់ប្រើប្រាស់ជាផ្លូវការ និងដាក់លើសក្តិស្មា សក្តិចុងកអាវ សក្តិចុងដៃអាវ និងដាក់នៅលើ សក្តិខ្វាស់លើអាវបុរស ឬ លើក្រមាពានារបស់នារី នៃមន្ត្រីអប់រំក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម និង ក្របខ័ណ្ឌគ្រូបង្រៀន កម្រិតមូលដ្ឋាន។

រូបសញ្ញាអប់រំ យុវជន និងកីឡានេះ មានរូបភាពដូចក្នុងឧបសម្ព័ន្ធទី១។

ជំពូកទី៣

សញ្ញាសក្តិ ឯកសណ្ឋាន និងសក្តិខ្វាស់លើអាវ ឬ ក្រមាពានា នៃមន្ត្រីអប់រំ ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម និងក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន

ផ្នែកទី១

អំពីសញ្ញាសក្តិ

ROYAUME DU CAMBODGE * LE JOURNAL ROYAL *

មាត្រា៣.-

សញ្ញាសក្តិមន្ត្រីអប់រំក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម និងក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន ត្រូវបានកំណត់ដូចតទៅ ÷

ក- ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម

១- អំពីសក្តិស្មា

សក្តិស្មា មានផ្ទៃកម្ចីពណ៌ខៀវទឹកប៊ិច រចនាតុបតែង ដោយក្បាច់ភ្ញីទេសពីរទងពណ៌មាស មួយវែង មួយខ្លី និងមានផ្កាមួយនៅលើទងវែង និងផ្លែពីរ។ នៅពីលើក្បាច់នេះ មានរូបសញ្ញាអប់រំ យុវជន និងកីឡា និងមានឡេវរូបព្រះសង្ហារពណ៌មាសមួយ នៅខាងលើរូបសញ្ញាអប់រំ យុវជន និងកីឡា។ នៅខាងក្រៅ មានក្បាច់ធ្មេញក្របី មួយខ្សែពណ៌មាសព័ទ្ធជុំវិញ។ ផ្ទៃខាងក្រៅនៃក្បាច់ធ្មេញក្របី មានខ្សែពួរវេញពណ៌មាសព័ទ្ធជុំវិញ ដែលមានលក្ខណៈសម្គាល់ខុសគ្នាបីយ៉ាង គឺៈ បីខ្សែ សម្រាប់សម្គាល់ឋានន្តរសក្តិគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ពីរខ្សែសម្រាប់សម្គាល់ឋានន្តរសក្តិគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ និងមួយខ្សែ សម្រាប់សម្គាល់ឋានន្តរសក្តិគ្រូបង្រៀនកម្រិតឧត្តម។

ខ្នាតសក្តិស្មាមានកំណត់ដូចខាងក្រោម ÷

- បាតធំប្រវែង ៦ សង្ទីម៉ែត្រ
- ទទឹងមុខកាត់ផ្នែកខាងលើប្រវែង ៤,៤០ សង្ទីម៉ែត្រ នៅខាងចុងមានរាងជាមុំទាល
- បណ្តោយពីបាតលើដល់បាតក្រោមប្រវែង ១៣ សង្ទីម៉ែត្រ។

២- អំពីសក្តិចុងកអាវសងខាង

សក្តិចុងកអាវមានផ្ទៃកម្ចីពណ៌ខៀវទឹកប៊ិច រចនាតុបតែងដោយសន្លឹកភ្ញីទេសពណ៌មាសមួយទង មានផ្កាមួយ និងផ្លែពីរនៅបន្ទាប់ពីរូបសញ្ញាអប់រំ យុវជន និងកីឡា។ នៅផ្នែកខាងលើ និងចំហៀងខាងមុខ មានក្បាច់ធ្មេញក្របីពណ៌មាសមួយខ្សែ។ នៅខាងក្រៅស្របនឹងខ្សែនៃក្បាច់ធ្មេញក្របី មានខ្សែពួរវេញពណ៌មាស ដែលមានលក្ខណៈសម្គាល់ខុសគ្នា គឺៈ បីខ្សែ សម្រាប់សម្គាល់ឋានន្តរសក្តិគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ពីរខ្សែសម្រាប់សម្គាល់ឋានន្តរសក្តិគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ និងមួយខ្សែសម្រាប់សម្គាល់ឋានន្តរសក្តិគ្រូបង្រៀនកម្រិតឧត្តម។

ខ្នាតសក្តិចុងកអាវមានកំណត់ដូចខាងក្រោម ÷

- រាងជាប្រលេឡូក្រាម
- បណ្តោយប្រវែង ៩ សង្ទីម៉ែត្រ
- ទទឹងប្រវែង ៣,៨ សង្ទីម៉ែត្រ។

៣- អំពីសក្តិចុងដៃអាវទាំងសងខាង

សក្តិចុងដៃអាវមានផ្ទៃខៀវទឹកប៊ិច។ នៅចំកណ្តាលនៃតួសក្តិ មានរូបសញ្ញាអប់រំ យុវជន និងកីឡា ដែលរចនា តុបតែងដោយសន្លឹកភ្ញីទេសពណ៌មាសបួនទង ពីរទងខាងលើវែង និងពីរទងខាងក្រោមខ្លី នៅអមសងខាងមានលក្ខណៈជាជញ្ជីងថ្លឹងស្មើ។ នៅលើទងទាំងបួន មានផ្កាបួន លើទងវែងពីរ លើទងខ្លីពីរ និងផ្លែម្ភៃពីរ នៅលើទងវែងដប់ប្រាំមួយ លើ

ROYAUME DU CAMBODGE

ទងខ្មី ប្រាំមួយ ។ នៅផ្នែកខាងលើ និងចំហៀងសងខាង មានក្បាច់ធ្មេញក្របីពណ៌មាសមួយខ្សែ ។ នៅខាងក្រៅស្របនឹងខ្សែនៃក្បាច់ធ្មេញក្របី មានខ្សែពួរវេញពណ៌មាស ដែលមានលក្ខណៈសម្គាល់ខុសគ្នា គឺ : បីខ្សែ សម្រាប់សម្គាល់ឋានន្តរសក្តិគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ពីរខ្សែសម្រាប់សម្គាល់ឋានន្តរសក្តិគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ និងមួយខ្សែសម្រាប់សម្គាល់ឋានន្តរសក្តិគ្រូបង្រៀនកម្រិតឧត្តម ។

ខ្នាតសក្តិចុងដៃអាវមានកំណត់ដូចខាងក្រោម ÷

- រាងជាបួនជ្រុងទ្រវែង
- បណ្តោយប្រវែង៣២ សង្ទីម៉ែត្រសម្រាប់បុរស
- ទទឹងប្រវែង៩ សង្ទីម៉ែត្រ ។

សក្តិស្មា សក្តិចុងកអាវ និងសក្តិចុងដៃអាវ សម្រាប់សម្គាល់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស មានគំរូដូចក្នុងឧបសម្ព័ន្ធទី២ សម្រាប់សម្គាល់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ មានគំរូដូចក្នុងឧបសម្ព័ន្ធទី៣ និងសម្រាប់សម្គាល់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម មានគំរូដូចក្នុងឧបសម្ព័ន្ធទី៤ ។

ខ- ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន

សក្តិស្មា សក្តិចុងកអាវ និងសក្តិចុងដៃអាវ សម្រាប់មន្ត្រីក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន មានលក្ខណៈទម្រង់ដូចគ្នាទាំងស្រុង ទៅនឹងមន្ត្រីក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម ប៉ុន្តែក្បាច់ភ្ញីទេស ក្បាច់ធ្មេញក្របី និងខ្សែពួរវេញ មានពណ៌ទឹកប្រាក់ ។ លក្ខណៈសម្គាល់ប្រភេទទាំងបី នៃឋានន្តរសក្តិមន្ត្រីក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន គឺ : ខ្សែពួរវេញពណ៌ទឹកប្រាក់បីខ្សែ សម្រាប់សម្គាល់ឋានន្តរសក្តិគ្រូបង្រៀនកម្រិតមូលដ្ឋានដើមខ្សែពិសេស ពីរខ្សែសម្រាប់សម្គាល់ឋានន្តរសក្តិគ្រូបង្រៀនកម្រិតមូលដ្ឋានដើមខ្សែ និងមួយខ្សែសម្រាប់សម្គាល់ឋានន្តរសក្តិគ្រូបង្រៀនកម្រិតមូលដ្ឋាន ។

សក្តិស្មា សក្តិចុងកអាវ និងសក្តិចុងដៃអាវ សម្រាប់សម្គាល់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋានដើមខ្សែពិសេស មានគំរូដូចក្នុងឧបសម្ព័ន្ធទី៥ សម្រាប់សម្គាល់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋានដើមខ្សែ មានគំរូដូចក្នុងឧបសម្ព័ន្ធទី៦ និងសម្រាប់សម្គាល់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន មានគំរូដូចក្នុងឧបសម្ព័ន្ធទី៧ ។

ដោយឡែក សក្តិស្មា សក្តិចុងកអាវ សក្តិចុងដៃអាវទាំងសងខាង សម្រាប់នារី មានទំហំដូចខាងក្រោមនេះ ÷

- ចំពោះសក្តិស្មា អាចមានទំហំ ៨០% ៨៥% ៩០% នៃទំហំសក្តិស្មាបុរស អាស្រ័យលើមាឌរបស់នារី
- សក្តិចុងកអាវ មានទំហំទទឹង៣ សង្ទីម៉ែត្រ ទៅ៣,៥០ សង្ទីម៉ែត្រ អាស្រ័យលើកម្ពស់របស់នារី
- សក្តិចុងដៃអាវអាចមានទំហំស្មើនឹង៧០% ទៅ ៧៥%នៃទំហំសក្តិចុងដៃអាវបុរស អាស្រ័យលើមាឌរបស់នារី ។

ជំពូកទី ២

អំពីឯកសណ្ឋាន

មាត្រា៤.-

ប្រភេទឯកសណ្ឋាន សម្រាប់មន្ត្រីអប់រំក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម និងក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន ត្រូវបានកំណត់ដូចតទៅ ÷

ROYAUME DU CAMBODGE

ក- ឯកសណ្ឋានផ្លូវការ

១- ចំពោះបុរស

- អាវកុដពណ៌ស កត្រង់ ដៃវែង កាត់រាងអាវធំ មានបន្ទះលើស្មាសម្រាប់ដាក់សក្តិ និងគ្មានផែកខ្នង។ នៅខាងមុខ មានប៊ិទឡេវរូបព្រះសង្ហារចំនួន៧គ្រាប់ ពណ៌មាស សម្រាប់សម្គាល់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម និងពណ៌ប្រាក់ សម្រាប់សម្គាល់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន និងមានហោប៉ៅចំនួន៤ គឺ : ហោប៉ៅខាងលើពីរ និងហោប៉ៅ ខាងក្រោមពីរ ដេរបង្កប់ មានគម្របរាងស្លឹកពោធិ៍។ នៅលើគម្របហោប៉ៅនីមួយៗ មានចោះរន្ធប៊ិទឡេវរូបព្រះសង្ហារមួយគ្រាប់ ពណ៌មាស ឬ ពណ៌ប្រាក់ ស្របតាមប្រភេទក្របខ័ណ្ឌនីមួយៗ

- ខោជើងវែងពណ៌ស ស្បែកជើងឃ្លុបពណ៌ខ្មៅ ចងខ្សែ និងស្រោមជើងពណ៌ខ្មៅ។

២- ចំពោះស្ត្រី

- អាវជីបរាងពណ៌ស ដោយប្រើប្រភេទកំណាត់ ដូចឈុតអាវរបស់បុរស កតាំងដៃវែងត្រឹមភ្នែកគោលដៃ គ្មានផែកខ្នង កាត់រាងអាវធំ នៅខាងមុខមានប៊ិទឡេវរូបព្រះសង្ហារចំនួន៥ គ្រាប់ ពណ៌មាស សម្រាប់សម្គាល់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម និងពណ៌ប្រាក់ សម្រាប់សម្គាល់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន។ ចុងកអាវមានសក្តិលើស្មាមានបន្ទះសម្រាប់ដាក់សក្តិ និងមានហោប៉ៅចំនួន៤ ដេរបង្កប់ គឺ : ហោប៉ៅលើពីរ និងហោប៉ៅក្រោមពីរ ដែលមានគម្របរាងស្លឹកពោធិ៍ ហើយ នៅពីលើគម្របនីមួយៗ មានចោះរន្ធប៊ិទឡេវរូបព្រះសង្ហារមួយគ្រាប់ ពណ៌មាស ឬ ពណ៌ប្រាក់ ស្របតាមប្រភេទក្របខ័ណ្ឌនីមួយៗ

- សំពត់ផាមួងពណ៌ខៀវទឹកប៊ិច រងជើងមានចាក់ខ្សែសយពណ៌មាស ឬ ពណ៌ប្រាក់ ស្របតាមប្រភេទក្របខ័ណ្ឌនីមួយៗ។ សំពត់នេះមានសម្រុងលើភ្នែកគោលនៃស្មងជើង ប្រវែងពី១០ ទៅ១៥ សង្ទីម៉ែត្រ អនុលោមតាមមាឌ និងកម្ពស់របស់នារី

- ស្បែកជើងអេស្កាប៉ាងពណ៌ស។

ឯកសណ្ឋានផ្លូវការសម្រាប់បុរស និងស្ត្រី នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម មានគំរូដូចក្នុងឧបសម្ព័ន្ធទី៨ និងក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន មានគំរូដូចក្នុងឧបសម្ព័ន្ធទី១០ នៃព្រះរាជក្រឹត្យនេះ។

ខ- ឯកសណ្ឋានប្រពៃណីជាតិ

១- ចំពោះបុរស

- អាវកុដពណ៌ស កត្រង់ ដៃវែង កាត់រាងអាវធំ មានបន្ទះលើស្មាសម្រាប់ដាក់សក្តិ និងគ្មានផែកខ្នង។ នៅខាងមុខមានប៊ិទឡេវរូបព្រះសង្ហារចំនួន៧ គ្រាប់ ពណ៌មាស សម្រាប់សម្គាល់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម និងពណ៌ប្រាក់ សម្រាប់សម្គាល់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន និងមានហោប៉ៅចំនួន៤ គឺ : ហោប៉ៅខាងលើពីរ និងហោប៉ៅខាងក្រោមពីរ ដេរបង្កប់ មានគម្របរាងស្លឹកពោធិ៍។ នៅលើគម្របហោប៉ៅនីមួយៗ មានចោះរន្ធប៊ិទឡេវរូបព្រះសង្ហារ ចំនួនមួយគ្រាប់ ពណ៌មាស ឬ ពណ៌ប្រាក់ ស្របតាមប្រភេទក្របខ័ណ្ឌនីមួយៗ

- សំពត់ផាមួងចងក្បិន មានពណ៌ស្របតាមថ្ងៃដែលប្រើប្រាស់

- ស្បែកជើងឃ្លុបពណ៌ខ្មៅ កខ្លី មានចងខ្សែ និងស្រោមជើងពណ៌ខ្មៅ ដល់ក្បាលជង្គង់ ។

ROYAUME DU CAMBODGE

២- ចំពោះស្ត្រី

- អាវជីបរាង ធ្វើអំពីកំណាត់ចាក់ពណ៌ស មានកអាងអប្សរា ដៃវែងត្រឹម ៣/៤ រូតខ្ទងបន្តិច
- ពានាក្រមាតាមពណ៌សំពត់ ឬ តាមពិធីការកំណត់
- សំពត់ផាមួងចងក្បិន មានពណ៌ស្របតាមថ្ងៃដែលប្រើប្រាស់
- ស្បែកជើងអេស្កាប៉ាំងពណ៌ស
- កាបូបយួរដៃពណ៌ស ឬ ពណ៌ខ្មៅ ។

ឯកសណ្ឋានប្រពៃណីសម្រាប់បុរស និងស្ត្រី នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម មានគំរូដូចក្នុងឧបសម្ព័ន្ធទី៩ និង ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន មានគំរូដូចក្នុងឧបសម្ព័ន្ធទី១១ នៃព្រះរាជក្រឹត្យនេះ។

ផ្នែកទី៣
អំពីសក្តិខ្ទាស់លើអាវ ឬ ក្រមាពានា

មាត្រា៥.-

សក្តិខ្ទាស់លើអាវ ឬ ក្រមាពានា មានរាងពងក្រពើ ដែលមានរូបសញ្ញាអប់រំ យុវជន និងកីឡា។ នៅខាងក្នុងចំកណ្តាល ធ្វើអំពីជ័រវីងថ្លា ចាក់ស្រោបពីក្រៅរូបសញ្ញាអប់រំ យុវជន និងកីឡា និងមានផ្ទៃពណ៌ខៀវទឹកប៊ិច។ សក្តិខ្ទាស់លើអាវ ឬ ក្រមាពានា មានទំហំ និងខ្នាតទទឹងប្រវែង៣ សង្ទីម៉ែត្រ មានខ្សែព័ទ្ធជុំវិញទៅតាមប្រភេទក្របខ័ណ្ឌ និងឋានន្តរសក្តិនៃអង្គមន្ត្រីនីមួយៗ។

សក្តិខ្ទាស់លើអាវនេះ សម្រាប់ខ្ទាស់លើអាវនៅពេលបំពេញការងារ។ សក្តិនេះក៏សម្រាប់ខ្ទាស់លើក្រមាពានានារី ក្នុងឯកសណ្ឋានប្រពៃណី។

សក្តិខ្ទាស់លើអាវ ឬ ក្រមាពានា មានគំរូដូចក្នុងឧបសម្ព័ន្ធទី១២ នៃព្រះរាជក្រឹត្យនេះ។

ផ្នែកទី៤
អំពីការប្រើប្រាស់ឯកសណ្ឋាន

មាត្រា៦.-

ការប្រើប្រាស់ឯកសណ្ឋាន សម្រាប់មន្ត្រីអប់រំក្របខ័ណ្ឌគ្រូបង្រៀន ទាំងពីរកម្រិត ត្រូវបានកំណត់ដូចខាងក្រោម ÷

- ឯកសណ្ឋានផ្លូវការ សម្រាប់ប្រើប្រាស់ក្នុងពិធីបុណ្យជាតិ និងពិធីការផ្សេងៗ
- ឯកសណ្ឋានប្រពៃណី សម្រាប់ប្រើប្រាស់ក្នុងពិធីបុណ្យប្រពៃណីជាតិ និងបុណ្យសាសនា ដែលប្រារព្ធធ្វើនៅក្នុងព្រះបរមរាជវាំង ក្នុងទីវត្តអារាម ឬ ទីកន្លែងផ្សេងៗ។

ជំពូកទី ៤
របបកំណត់ឯកសណ្ឋាន និងសញ្ញាសក្តិ

ROYAUME DU CAMBODGE

មាត្រា៧.-

ត្រូវបានផ្ដល់ជូនដល់មន្ត្រីម្នាក់ៗ នូវឯកសណ្ឋានផ្លូវការមួយសម្រាប់ និងឯកសណ្ឋានប្រពៃណីមួយសម្រាប់ ព្រមទាំងសក្ដិខ្នាស់លើអាវ ឬ ក្រមាពានា និងសម្ភារៈផ្សេងៗទៀត ដូចបានកំណត់ក្នុងព្រះរាជក្រឹត្យនេះ។ ឯកសណ្ឋានទាំងនេះត្រូវផ្ដល់ជូនក្នុងរយៈពេលបីឆ្នាំម្ដង។

ជំពូកទី ៥

អវសានប្បញ្ញត្តិ

មាត្រា៨.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៩.-

នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តព្រះរាជក្រឹត្យ នេះចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១ ខែសីហា ឆ្នាំ២០០៧

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

៣/ល.០៧០៨.៣៤៩

ហត្ថលេខា

ហ៊ុន សែន

លេខ:៣៣៤ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ,ថ្ងៃទី ០៦ ខែសីហា ឆ្នាំ២០០៧

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ជិនកេន

ឧបសម្ព័ន្ធទី.១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៨០៧/៣៦២ ចុះថ្ងៃទី.១...ខែសីហា ឆ្នាំ២០០៧
ស្តីពីរូបសញ្ញាអប់រំ យុវជន និងកីឡា សញ្ញាសក្តិ ឯកសណ្ឋាន និងសក្តិខ្ទាស់លើអាវ ឬ ក្រមាពាទា
សម្រាប់មន្ត្រីអប់រំ ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម និងកម្រិតមូលដ្ឋាន

ក្រសួងអប់រំយុវជននិងកីឡា

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

9/20

ឧបសម្ព័ន្ធទី ០២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៨០៧/៣៦២ ចុះថ្ងៃទី ១... ខែសីហា ឆ្នាំ២០០៧
ស្តីពីរូបសញ្ញាអប់រំ យុវជន និងកីឡា សញ្ញាសក្តិ ឯកសណ្ឋាន និងសក្តិខ្ទាស់លើអាវ ឬ ក្រវាត់ក
សម្រាប់មន្ត្រីអប់រំ ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម និងកម្រិតមូលដ្ឋាន

សញ្ញាសក្តិសម្រាប់សម្គាល់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តមជើងខ្សែពិសេស

សក្តិករអាវ



សក្តិស្មា



សក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី.០៣ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥៨៧/៣២.៥.ចុះថ្ងៃទី..១...ខែសីហា ឆ្នាំ២០០៧
ស្តីពីរូបសញ្ញាអប់រំ យុវជន និងកីឡា សញ្ញាសក្តិ ឯកសណ្ឋាន និងសក្តិខ្ទាស់លើអាវ ឬ ក្រមាពានា
សម្រាប់មន្ត្រីអប់រំ ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម និងកម្រិតមូលដ្ឋាន

សញ្ញាសក្តិសម្រាប់សម្គាល់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ

សក្តិករអាវ

សក្តិស្មា



សក្តិចុងដៃអាវ



ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ឧបសម្ព័ន្ធទី.១៤. នៃព្រះរាជក្រឹត្យលេខ នស/រកត/០៨០៧/៧២៥ ចុះថ្ងៃទី.១...ខែសីហា.ឆ្នាំ២០០៧
ស្តីពីរូបសញ្ញាអប់រំ យុវជន និងកីឡា សញ្ញាសក្តិ ឯកសណ្ឋាន និងសក្តិខ្នាស់លើអាវ ឬ ក្រមាពាទា
សម្រាប់មន្ត្រីអប់រំ ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម និងកម្រិតមូលដ្ឋាន

សញ្ញាសក្តិសម្រាប់សម្គាល់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម

សក្តិកអាវ



សក្តិស្មា



សក្តិចុងដៃអាវ



12/20

ឧបសម្ព័ន្ធទី.១៥. នៃព្រះរាជក្រឹត្យលេខ នស/រកត/០៨០៧/៣៧២ ចុះថ្ងៃទី.១...ខែសីហា.ឆ្នាំ២០០៧
ស្តីពីរូបសញ្ញាអប់រំ យុវជន និងកីឡា សញ្ញាសក្តិ ឯកសណ្ឋាន និងសក្តិខ្ទាស់លើអាវ ឬ ក្រមាពានា
សម្រាប់មន្ត្រីអប់រំ ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម និងកម្រិតមូលដ្ឋាន

សញ្ញាសក្តិសម្រាប់សម្គាល់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋានដើមខ្សែពិសេស

សក្តិកអាវ



សក្តិស្មា



សក្តិចុងដៃអាវ



ឧបសម្ព័ន្ធទី.១៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៨០៧/៦៣៤ ចុះថ្ងៃទី..២..ខែសីហា.ឆ្នាំ២០០៧
ស្តីពីរូបសញ្ញាអប់រំ យុវជន និងកីឡា សញ្ញាសក្តិ ឯកសណ្ឋាន និងសក្តិខ្ទាស់លើអាវ ឬ ក្រមាពាក់
សម្រាប់មន្ត្រីអប់រំ ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម និងកម្រិតមូលដ្ឋាន

សញ្ញាសក្តិសម្រាប់សម្គាល់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋានដើមខ្សែ

សក្តិករអាវ



សក្តិស្មា



សក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី.០៧ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៨០៧/៣២៥ចុះថ្ងៃទី..១..ខែសីហា.ឆ្នាំ២០០៧
ស្តីពីរូបសញ្ញាអប់រំ យុវជន និងកីឡា សញ្ញាសក្តិ ឯកសណ្ឋាន និងសក្តិខ្ទាស់លើអាវ ឬ ក្រមាពានា
សម្រាប់មន្ត្រីអប់រំ ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម និងកម្រិតមូលដ្ឋាន

សញ្ញាសក្តិសម្រាប់សម្គាល់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន

សក្តិកអាវ



សក្តិស្មា



សក្តិចុងដៃអាវ



ឧបសម្ព័ន្ធទី.០៨ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៨០៧/៣២៥ ចុះថ្ងៃទី..១..ខែសីហា.ឆ្នាំ២០០៧ ស្តីពីរូបសញ្ញាអប់រំ យុវជន និងកីឡា សញ្ញាសក្តិ ឯកសណ្ឋាន និងសក្តិខ្វាស់លើអាវ ឬ ក្រមាពានា សម្រាប់មន្ត្រីអប់រំ, ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម និងកម្រិតមូលដ្ឋាន

ឯកសណ្ឋានផ្លូវការសម្រាប់សម្គាល់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម



ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

16/20

ឧបសម្ព័ន្ធទី.០៩ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥០៧/៧២៥ចុះថ្ងៃទី..១..ខែឧសភា.ឆ្នាំ២០០៧ ស្តីពីរូបសញ្ញាអប់រំ យុវជន និងកីឡា សញ្ញាសក្តិ ឯកសណ្ឋាន និងសក្តិខ្ទាស់លើអាវ ឬ ក្រមាពានា សម្រាប់មន្ត្រីអប់រំ ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម និងកម្រិតមូលដ្ឋាន

ឯកសណ្ឋានប្រពៃណីសម្រាប់សម្គាល់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម



ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

17/20

ឧបសម្ព័ន្ធទី.១០ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៨០៧/៣២៥ចុះថ្ងៃទី..១...ខែសីហា.ឆ្នាំ២០០៧ ស្តីពីរូបសញ្ញាអប់រំ យុវជន និងកីឡា សញ្ញាសក្តិ ឯកសណ្ឋាន និងសក្តិខ្វាស់លើអាវ ឬ ក្រមាពានា សម្រាប់មន្ត្រីអប់រំ ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម និងកម្រិតមូលដ្ឋាន

ឯកសណ្ឋានផ្លូវការសម្រាប់សម្គាល់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន



ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

18/20

ឧបសម្ព័ន្ធទី.១១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៨០៧/៧២៥ ចុះថ្ងៃទី.១...ខែសីហា.ឆ្នាំ២០០៧ ស្តីពីរូបសញ្ញាអប់រំ យុវជន និងកីឡា សញ្ញាសក្តិ ឯកសណ្ឋាន និងសក្តិខ្នាស់លើអាវ ឬ ក្រមាពានា សម្រាប់មន្ត្រីអប់រំ ក្របខណ្ឌគ្រូបង្រៀនកម្រិតឧត្តម និងកម្រិតមូលដ្ឋាន

ឯកសណ្ឋានប្រពៃណីសម្រាប់សម្គាល់ក្របខណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន



ROYAUME DU CAMBODGE · LE MINISTÈRE DU PALAIS ROYAL

19/20

ឧបសម្ព័ន្ធទី.១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៨០៧/៧២៥.ចុះថ្ងៃទី..១..ខែសីហា.ឆ្នាំ២០០៧
ស្តីពីរូបសញ្ញាអប់រំ យុវជន និងកីឡា សញ្ញាសក្តិ ឯកសណ្ឋាន និងសក្តិខ្ចាស់លើអាវ ឬ ក្រមាពានា
សម្រាប់មន្ត្រីអប់រំ ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម និងកម្រិតមូលដ្ឋាន

សក្តិខ្ចាស់លើអាវ ឬ ក្រមាពានាសម្រាប់សម្ភារប៉ក្របខ័ណ្ឌគ្រូបង្រៀន

កម្រិតឧត្តមដើមខ្សែពិសេស



កម្រិតឧត្តមដើមខ្សែ



កម្រិតឧត្តម



កម្រិតមូលដ្ឋានដើមខ្សែពិសេស



កម្រិតមូលដ្ឋានដើមខ្សែ



កម្រិតមូលដ្ឋាន



ROYAUME du CAMBODGE • LE MINISTRE du PALAIS ROYAL •

20/29

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៩១...អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការរៀបចំ និងការប្រព្រឹត្តទៅរបស់
ក្រសួងពាណិជ្ជកម្ម

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម /០១៩៦ /១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៧

ស ម្រេ ច

ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

អនុក្រឹត្យនេះមានគោលដៅរៀបចំបណ្តាអង្គភាព នៃក្រសួងពាណិជ្ជកម្ម និងកំណត់បេសកកម្មរបស់ក្រសួង

និងមុខងារ នៃអគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន នាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទ ។

ជំពូកទី ២
បេសកកម្ម និងរចនាសម្ព័ន្ធ

មាត្រា ២.-

ក្រសួងពាណិជ្ជកម្ម ត្រូវបានរាជរដ្ឋាភិបាលកម្ពុជា ប្រគល់ឱ្យទទួលបេសកកម្មដឹកនាំ និងគ្រប់គ្រងលើវិស័យពាណិជ្ជកម្មក្នុង និងក្រៅប្រទេស នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣.-

ក្រសួងពាណិជ្ជកម្ម មានមុខងារ និងភារកិច្ច ដូចតទៅ ÷

- រួមចំណែកកសាងគោលនយោបាយពាណិជ្ជកម្ម ដោយឈរលើមូលដ្ឋានច្បាប់ និងបទប្បញ្ញត្តិអន្តរជាតិ ពិសេសអង្គការពាណិជ្ជកម្មពិភពលោក
- កំណត់អំពីសន្និធិទំនិញយុទ្ធសាស្ត្រ
- តាមដានថ្លៃទំនិញ និងដំណើរការទីផ្សារ
- ចលនា និងផ្សព្វផ្សាយការប្រើប្រាស់ដល់អតិថិជន និងចាត់វិធានការការពារផលប្រយោជន៍អ្នកប្រើប្រាស់
- ជួយរកទីផ្សារជូនកសិករ និងពាណិជ្ជករ
- រៀបចំដឹកនាំ និងត្រួតពិនិត្យពាណិជ្ជកម្មក្រៅប្រទេស និងផ្តល់អាជ្ញាប័ណ្ណសម្រាប់ការនាំចេញ នាំចូលទំនិញ តាមការកំណត់របស់រាជរដ្ឋាភិបាល
- អនុវត្តនយោបាយ ដើម្បីអភិវឌ្ឍវិស័យឯកជន ធានាសេរីភាព និងការធ្វើពាណិជ្ជកម្មប្រកបដោយសមធម៌
- ចាត់ចែងតាក់តែងច្បាប់ពាណិជ្ជកម្ម បទប្បញ្ញត្តិពាណិជ្ជកម្ម និងគ្រប់គ្រងមជ្ឈមណ្ឌលតម្កល់ឯកសារ និងព័ត៌មានពាណិជ្ជកម្ម
- គាំទ្រ និងឧបត្ថម្ភដល់មជ្ឈមណ្ឌលជាតិ នៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម
- ជំរុញវិស័យពាណិជ្ជកម្ម និងវិស័យពាក់ព័ន្ធនឹងពាណិជ្ជកម្ម តាមការរៀបចំអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្មទាំងមូល
- គ្រប់គ្រង និងរៀបចំដឹកនាំ ការតម្កល់លិខិតជូនដំណឹង នៃប្រតិបត្តិការដែលមានកិច្ចធានា
- រៀបចំ និងគ្រប់គ្រងមជ្ឈមណ្ឌលពិព័រណ៍ពាណិជ្ជកម្មជាតិ ខេត្ត ក្រុង និងតំបន់
- ជំរុញឱ្យមានគុណភាពទំនិញនាំចេញ នាំចូល
- ផ្សព្វផ្សាយ និងធ្វើទំនាក់ទំនងជាមួយទីផ្សារអន្តរជាតិ តាមរយៈការដាក់តំណាងពាណិជ្ជកម្មដើម្បីលើក

ទិសដៅអភិវឌ្ឍន៍វិស័យពាណិជ្ជកម្មក្រៅប្រទេស ឈរលើមូលដ្ឋានសេដ្ឋកិច្ចទីផ្សារ

- សិក្សាស្រាវជ្រាវស្ថានភាពសេដ្ឋកិច្ចជាតិ និងអន្តរជាតិ ព្រមទាំងព្យាករណ៍និន្នាការទីផ្សារសម្រាប់ផ្សព្វផ្សាយដល់ផលិតករ និងពាណិជ្ជករ ដើម្បីងាយស្រួលធ្វើជំនួញនៅក្នុង និងក្រៅប្រទេស
- សម្របសម្រួលការងារកម្មសិទ្ធិបញ្ញា គ្រប់គ្រងដោយផ្ទាល់ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ការសម្គាល់ភូមិសាស្ត្រទំនិញ និងការការពារព័ត៌មានសម្ងាត់ពាណិជ្ជកម្ម
- ត្រួតពិនិត្យគុណភាព បរិមាណ ទម្ងន់ យថាប្រភេទទំនិញ នាំចេញ នាំចូល
- បង្ក្រាបការក្លែងបន្លំ គុណភាពទំនិញនៅលើទីផ្សារ លើកលែងតែផលិតផលឱសថ បរិក្ខារពេទ្យ និងគ្រឿងសម្អាង
- គ្រប់គ្រង និងអនុវត្តបទប្បញ្ញត្តិនៃប្រព័ន្ធអនុគ្រោះទូទៅ និងប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មនានា ព្រមទាំងចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ
- ធ្វើអាណាព្យាបាលសភាពាណិជ្ជកម្ម សហគ្រាសជំនួញរបស់រដ្ឋ សហគ្រាសសេដ្ឋកិច្ចចម្រុះរដ្ឋ និងឯកជនដែលស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេស របស់ក្រសួងពាណិជ្ជកម្ម
- ធ្វើសហប្រតិបត្តិការ និងធ្វើសមាហរណកម្មសេដ្ឋកិច្ចពាណិជ្ជកម្ម ជាមួយសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ដែលហៅកាត់ថា អាស៊ាន និងជាមួយបណ្តាប្រទេសនានា ព្រមទាំងអង្គការអន្តរជាតិ នានា
- កាន់កាប់បញ្ជីពាណិជ្ជកម្ម និងគ្រប់គ្រងសមត្ថភាពពាណិជ្ជកម្ម ដូចមានចែងក្នុងច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ។

មាត្រា ៤.-

ក្រសួងពាណិជ្ជកម្ម មានរចនាសម្ព័ន្ធ ដូចតទៅ ÷

ក. ថ្នាក់កណ្តាល ÷

- ខុទ្ទកាល័យ
- នាយកដ្ឋានសវនកម្មផ្ទៃក្នុង
- អគ្គាធិការដ្ឋាន
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

អគ្គនាយកដ្ឋាននេះ មាននាយកដ្ឋានចំណុះ ចំនួន ០៣ គឺ ÷

១-នាយកដ្ឋានរដ្ឋបាល

២-នាយកដ្ឋានបុគ្គលិក

៣-នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ

- អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ

អគ្គនាយកដ្ឋាននេះ មាននាយកដ្ឋានចំណុះ ចំនួន ០៦ គឺ ÷

១-នាយកដ្ឋានពាណិជ្ជកម្មទ្វេភាគី

២-នាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម

៣-នាយកដ្ឋានពាណិជ្ជកម្មពហុភាគី

៤-នាយកដ្ឋានជំរុញពាណិជ្ជកម្ម

៥-នាយកដ្ឋានផ្តល់ព័ត៌មាន និងផ្ទៀងផ្ទាត់ច្បាប់

៦-នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ

- អគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស

អគ្គនាយកដ្ឋាននេះ មាននាយកដ្ឋានចំណុះចំនួន ០៥ គឺ ÷

១-នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ

២-នាយកដ្ឋានកម្មសិទ្ធិបញ្ញា

៣-នាយកដ្ឋានស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម

៤-នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម

៥-នាយកដ្ឋាននីតិកម្ម

ខ. អង្គភាពមូលដ្ឋាន ÷

- មន្ទីរពាណិជ្ជកម្មខេត្ត ក្រុង
- ការិយាល័យពាណិជ្ជកម្មស្រុក ខណ្ឌ

គ. សហគ្រាសសាធារណៈ ÷

- ក្រុមហ៊ុនហ្រ្គីនត្រេដ

អង្គការលេខរបស់ក្រសួងពាណិជ្ជកម្ម ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

ជំពូកទី ៣
ខុទ្ទកាល័យរដ្ឋមន្ត្រី

មាត្រា ៥.-

ខុទ្ទកាល័យរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មទាំងឡាយ ដែលកំណត់តាមបទប្បញ្ញត្តិ នៃអនុក្រឹត្យ លេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ដូចមានយោងក្នុងមូលបទខាងលើ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន ។

ជំពូកទី ៤
នាយកដ្ឋានសវនកម្មផ្ទៃក្នុង

មាត្រា ៦.-

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ទទួលភារកិច្ចអនុវត្តមុខងារ និងភារកិច្ច តាមខ្លឹមសារអនុក្រឹត្យ លេខ ៤០ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃសវនកម្មផ្ទៃក្នុង នៅតាមបណ្តាក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ ។

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់។

ជំពូកទី ៥
អគ្គាធិការដ្ឋាន

មាត្រា ៧.-

អគ្គាធិការដ្ឋាន មានភារកិច្ចដូចតទៅ ÷

- ធ្វើអធិការកិច្ចជាប្រចាំ ទៅលើគ្រប់អង្គភាពក្រោមឱវាទក្រសួងពាណិជ្ជកម្ម
- ធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រី ពីការប្រព្រឹត្តទៅរបស់អង្គភាព ដែលបានធ្វើអធិការកិច្ចហើយ និងពីមធ្យោបាយកែលំអការប្រព្រឹត្តទៅ របស់អង្គភាពទាំងនោះ
- អនុវត្តភារកិច្ចផ្សេងៗ ទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

អគ្គាធិការដ្ឋាន ដឹកនាំដោយអគ្គាធិការមួយរូប និងអមដោយអគ្គាធិការរងមួយ ឬច្រើនរូបជាជំនួយការតាមការចាំបាច់។

ជំពូកទី ៦
អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

មាត្រា ៨.-

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មានភារកិច្ចដូចតទៅ ÷

- គ្រប់គ្រងការងាររដ្ឋបាល បូកសរុប របាយការណ៍ ឯកសារ បុគ្គលិក ផែនការ ហិរញ្ញវត្ថុ សម្ភារបរិក្ខារ បណ្តុះបណ្តាល គ្របខ័ណ្ឌក្រសួង សិក្សាស្រាវជ្រាវ និងធ្វើតុល្យភាពការងារ
- សម្របសម្រួលរាល់សកម្មភាពរដ្ឋបាលនៅក្នុងក្រសួង ជាមួយបណ្តាអង្គភាពមូលដ្ឋានខេត្ត ក្រុង និងជាមួយបណ្តាក្រសួងពាក់ព័ន្ធនានា

- អនុវត្តភារកិច្ចផ្សេងៗ ទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន។

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ដឹកនាំដោយអគ្គនាយកមួយរូប និងអមដោយអគ្គនាយករងមួយចំនួន ជាជំនួយការ តាមការចាំបាច់។

មាត្រា ៩.-

នាយកដ្ឋានរដ្ឋបាល មានភារកិច្ចដូចតទៅ ៖

- សម្របសម្រួលរាល់កិច្ចការរបស់ក្រសួងនៅថ្នាក់កណ្តាល និងរវាងថ្នាក់កណ្តាលជាមួយនឹងអង្គភាពមូលដ្ឋានក្រោមឱវាទ
- គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់ក្រសួង
- ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល
- សរុប និងធ្វើរបាយការណ៍ការងារ និងសកម្មភាពផ្សេងៗរបស់ក្រសួង
- អនុវត្តភារកិច្ចផ្សេងៗ ទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន។

នាយកដ្ឋានរដ្ឋបាល ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួន ជាជំនួយការ តាមការចាំបាច់។

មាត្រា ១០.-

នាយកដ្ឋានបុគ្គលិក មានភារកិច្ចដូចតទៅ ៖

- គ្រប់គ្រងរដ្ឋបាលមន្ត្រីរាជការដោយទំនាក់ទំនងជាមួយ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងក្រសួង ស្ថាប័នពាក់ព័ន្ធ
- រៀបចំសំណុំឯកសារ សម្រាប់ការគ្រប់គ្រងអាជីពរបស់មន្ត្រីរាជការ មានជាអាទិ៍ ការតែងតាំង ការតាំងស៊ប់ ការផ្ទេរផ្លាស់ប្តូរកន្លែងធ្វើការ ការដំឡើងថ្នាក់ ឋានន្តរសក្តិ លើកសរសើរ ជូនគ្រឿងឥស្សរិយយស ការដាក់វិន័យ ការដាក់ឱ្យនៅក្រៅក្របខ័ណ្ឌដើម ការដាក់ឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស ការលុបឈ្មោះចេញពីក្របខ័ណ្ឌ ការរៀបចំសំណុំឯកសារចូលនិវត្តន៍ ការបាត់បង់សម្បទាវិជ្ជាជីវៈ
- គ្រប់គ្រង និងថែរក្សាសំណុំលិខិតមន្ត្រីរាជការ
- រៀបចំគ្រប់គ្រងស្ថិតិលើទិន្នន័យបុគ្គលិក និងតារាងព័ត៌មានប្រតិបត្តិ
- ធ្វើកម្មវិធីតំណែងឯកទេស និងធនធានមនុស្ស
- លើកសំណើបង្កើត ឬរំសាយអង្គភាពនានា រៀបចំតួនាទីភារកិច្ច កែសម្រួលរចនាសម្ព័ន្ធតាម ស្ថានភាពជាក់ស្តែង

- គ្រប់គ្រង និងធ្វើកម្មវិធីបណ្តុះបណ្តាលធនធានមនុស្ស
- លើកផែនការ និងធ្វើការវាយតម្លៃតម្រូវការបណ្តុះបណ្តាលមន្ត្រីរាជការ
- រៀបចំផែនការក្របខ័ណ្ឌប្រចាំឆ្នាំ
- រៀបចំប្រឡងជ្រើសរើសមន្ត្រីថ្មី ជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា និងពលករអណ្តែត
- រៀបចំគម្រោងបៀវត្ស និងត្រួតពិនិត្យតារាងបៀវត្សមន្ត្រីរាជការ
- អនុវត្តភារកិច្ចផ្សេងៗ ទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន។

នាយកដ្ឋានបុគ្គលិក ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់។

មាត្រា ១១.-

នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ មានភារកិច្ចដូចតទៅ ÷

- លើកសរុបគម្រោងថវិកាក្រសួង និងតាមដានវិលើកពីការប្រតិបត្តិ បូកសរុបកម្មវិធីចំណូលចំណាយប្រចាំខែ ត្រីមាស ឆ្នាំ
- ប្រមូលចំណូល និងបង់ចំណូលជូនថវិការដ្ឋឱ្យបានសមស្របតាមច្បាប់ហិរញ្ញវត្ថុកំណត់
- ប្រមូលផ្តុំ និងសម្របសម្រួលរាល់ការចំណាយរបស់ក្រសួង
- តាមដានវិលើកការគ្រប់គ្រងគណនីពិសេស
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សម្ភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ
- ធ្វើកម្មវិធីចំណាយ បែងចែកប្រេងឥន្ធនៈ និងគ្រឿងបន្លាស់
- កាន់បញ្ជីជាប្រចាំនូវសលាកបត្រ និងគណនេយ្យរូបធាតុ
- គ្រប់គ្រងព័ត៌មានវិទ្យា សកម្មភាពខាងហិរញ្ញវត្ថុ និងបន្ទុកគណនី
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន។

នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់។

ជំពូកទី ៧

អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ

មាត្រា ១២.-

អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ មានភារកិច្ចដូចតទៅ ÷

- ប្រតិបត្តិរាល់គោលនយោបាយ និងបេសកកម្មរបស់ក្រសួង ក្នុងការគ្រប់គ្រង ដឹកនាំការងារពាណិជ្ជកម្មអន្តរជាតិ
- ស្រាវជ្រាវ និងរៀបចំគោលនយោបាយពាណិជ្ជកម្មក្រៅប្រទេស ឱ្យស្របតាមគោលនយោបាយ របស់រាជរដ្ឋាភិបាល
- ចាត់ចែង និងសម្របសម្រួលនូវរាល់ការងារបច្ចេកទេស នៃកិច្ចការរបស់ក្រសួង ជាមួយនឹងអង្គភាពចំណុះក្រសួង
- ពិនិត្យពិច័យ និងលើកឡើងនូវអនុសាសន៍សំខាន់ៗ ដើម្បីសុំសេចក្តីសម្រេចពីរដ្ឋមន្ត្រី
- ធ្វើរបាយការណ៍បច្ចេកទេសចំពោះបញ្ហាសំខាន់ៗ ដែលជាមុខការរបស់ក្រសួងពាណិជ្ជកម្ម
- ពិនិត្យ និងរៀបចំឯកសារសម្រាប់ធ្វើការជាមួយអង្គការអន្តរជាតិនានា រួមទាំងឯកសារសម្រាប់ចូលរួមក្នុងសន្និសីទសេដ្ឋកិច្ច ពាណិជ្ជកម្មអន្តរជាតិ
- ស្រាវជ្រាវ និងវិភាគនយោបាយពាណិជ្ជកម្ម សម្រាប់ធ្វើជាមូលដ្ឋាន នៃការចរចាបើកច្រកទីផ្សារ
- ធ្វើសហប្រតិបត្តិការជាមួយបណ្តាប្រទេស និងសហគមន៍ដៃគូអភិវឌ្ឍន៍ ដើម្បីរកថវិកាសម្រាប់បណ្តុះបណ្តាលធនធានមនុស្ស និងពង្រឹងសមត្ថភាពស្ថាប័ន
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន។

អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ ដឹកនាំដោយអគ្គនាយកមួយរូប និងអមដោយអគ្គនាយករងមួយចំនួនជាជំនួយការ តាមការចាំបាច់។

មាត្រា ១៣.-

នាយកដ្ឋានពាណិជ្ជកម្មទ្វេភាគី មានភារកិច្ចដូចតទៅ ÷

- ធ្វើការចរចា និងរៀបចំកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគី និងកិច្ចព្រមព្រៀងពាណិជ្ជកម្មតាមព្រំដែន
- ធ្វើទំនាក់ទំនងជាមួយបរទេស ដើម្បីប្រមូលព័ត៌មានទីផ្សារ សិក្សាពីរបាំងពន្ធ និងរបាំងបច្ចេកទេសរបស់ប្រទេសនានា
- អនុវត្តគោលនយោបាយសម្រួលពាណិជ្ជកម្មសម្រាប់វិនិយោគិន និងពាណិជ្ជករ
- ផ្សព្វផ្សាយនូវវិធានប្រភពដើមទំនិញរបស់សហគមន៍អឺរ៉ុប និងចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញនាំចេញទៅកាន់សហគមន៍អឺរ៉ុប
- គ្រប់គ្រងការធ្វើពាណិជ្ជកម្មជាមួយសហគមន៍អឺរ៉ុប រួមមានការអនុវត្តឱ្យបានត្រឹមត្រូវ នូវវិធានប្រភពដើមទំនិញ
- ចេញអាជ្ញាប័ណ្ណនាំចេញ នាំចូលទំនិញ ផ្អែកតាមការកំណត់របស់ច្បាប់ និងបទប្បញ្ញត្តិ និងតាមការ

កំណត់របស់រាជរដ្ឋាភិបាល

- រៀបចំធ្វើសន្ទស្សន៍សេដ្ឋកិច្ច និងវិភាគលើស្ថានភាពពាណិជ្ជកម្មទ្វេភាគី
- ចូលរួមតាមការចាំបាច់ ជាមួយស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំកិច្ចព្រមព្រៀងទ្វេភាគី និងពហុភាគី
- សម្របសម្រួលការងារជាមួយស្ថានតំណាងពាណិជ្ជកម្មប្រចាំនៅបរទេស
- សិក្សាផលប៉ះពាល់ដល់មុខទំនិញផលិតកម្ម ក្នុងស្រុកនូវមុខទំនិញនាំចូលទាំងឡាយ ដើម្បីលើកយោបល់ជូនរដ្ឋមន្ត្រី សម្រាប់មានវិធានការទប់ទល់
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន ។

នាយកដ្ឋានពាណិជ្ជកម្មទ្វេភាគី ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

មាត្រា ១៤.-

នាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម មានភារកិច្ចដូចតទៅ ÷

- សិក្សាស្រាវជ្រាវ ពីវិធានប្រភពដើមទំនិញរាល់ទីផ្សារសំខាន់ៗ ដើម្បីរក្សាជាឯកសារច្បាប់សម្រាប់ផ្តល់វិញ្ញាបនបត្រ និងណែនាំដល់អ្នកនាំចេញកម្ពុជាឱ្យបំពេញទៅតាមលក្ខខណ្ឌតម្រូវនានា
- ចុះបញ្ជីផ្តល់សិទ្ធិនាំចេញ ក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មទូទៅ ដល់វិនិយោគិន និងអ្នកនាំចេញ
- ពិនិត្យសំណើ និងចេញវិញ្ញាបនបត្រប្រភពដើមទំនិញជូនវិនិយោគិន និងអ្នកនាំចេញសម្រាប់ទិសដៅទ្វីបអាមេរិក ក្រៅពីសហគមន៍អឺរ៉ុប ក្រៅពីអាស៊ាន និងក្រៅពីដៃគូអាស៊ានក្នុងតំបន់
- ផ្សព្វផ្សាយ និងណែនាំពីវិធានប្រភពដើមទំនិញ អំពីប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម និងពីបែបបទសុំវិញ្ញាបនបត្រប្រភពដើមទំនិញ
- តាមដាន កត់ត្រានូវរាល់ប្រភពដើមនៃវត្ថុធាតុដើម សម្រាប់បម្រើការងារផលិតក្នុងទិសដៅនាំចេញ
- ពិនិត្យស្រាវជ្រាវថ្លៃដើមផលិតកម្មរបស់ផលិតផល ដែលស្នើសុំវិញ្ញាបនបត្រប្រភពដើម ដើម្បីកំណត់ប្រភពដើមផលិតផលដែលនាំចេញ
- ស្រាវជ្រាវអត្រាពន្ធ MFN/GSP របស់ប្រទេស ដែលផ្តល់ភាពអនុគ្រោះពាណិជ្ជកម្ម ដល់កម្ពុជាសម្រាប់ធ្វើការផ្សព្វផ្សាយ
- ធ្វើជាសេនាធិការឱ្យថ្នាក់ដឹកនាំក្រសួងក្នុងការប្រមូលព័ត៌មាន និងឯកសារស្តីពីការនាំចេញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ដើម្បីធ្វើការវិភាគ និងលើកឡើងនូវវិធានការសមស្របនានា ក្នុងការថែរក្សាទីផ្សារនាំចេញរបស់កម្ពុជា
- ត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម សំដៅការពារទីផ្សារនាំចេញរបស់កម្ពុជា

- សហការជាមួយប្រទេសដែលផ្តល់ប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ក្នុងការផ្ទៀងផ្ទាត់ឯកសារចាំបាច់នានា និងទប់ស្កាត់ការក្លែងបន្លំប្រភពដើមទំនិញ
- សិក្សាពីគោលនយោបាយ ដែលទាក់ទងទៅនឹងអនាគត នៃគម្រោងប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ចំពោះផលិតផលនាំចេញពីកម្ពុជា ជាពិសេសសម្លៀកបំពាក់ និងស្បែកជើង
- សហការជាមួយអង្គភាពពាក់ព័ន្ធ ក្នុងការចរចាលើកិច្ចព្រមព្រៀងជាមួយប្រទេស ដែលផ្តល់ប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ដើម្បីពង្រីកភាពអនុគ្រោះពាណិជ្ជកម្មបន្ថែមទៀត
- រៀបចំគោលនយោបាយ បង្កើនសមត្ថភាពប្រកួតប្រជែងរបស់វិស័យឯកជន ដើម្បីការពារវិនិយោគដែលមានស្រាប់ និងទាក់ទាញវិនិយោគថ្មី
- សហការដោះស្រាយបាតុភាព ដែលទាក់ទងដល់ការប្រើប្រាស់ប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន ។

នាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

មាត្រា ១៥.-

នាយកដ្ឋានពាណិជ្ជកម្មពហុភាគី មានភារកិច្ចដូចតទៅ ៖

- ទទួលបន្ទុកការងារសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្ម ក្នុងក្របខ័ណ្ឌអនុតំបន់ ក្របខ័ណ្ឌតំបន់ និងក្របខ័ណ្ឌពិភពលោក
- ធ្វើការស្រាវជ្រាវ និងវិភាគ ដើម្បីរៀបចំឯកសារគោលនយោបាយ យុទ្ធសាស្ត្រពាណិជ្ជកម្ម ជូនក្រសួង និងរាជរដ្ឋាភិបាល
- ជួយដល់អ្នកចរចាជាន់ខ្ពស់ ក្នុងការរៀបចំយុទ្ធសាស្ត្រចរចាពាណិជ្ជកម្ម ក្នុងក្របខ័ណ្ឌតំបន់ និងពិភពលោក
- ជំរុញការអនុវត្តកាតព្វកិច្ចរបស់កម្ពុជា ដែលបានសន្យាជាមួយអង្គការពាណិជ្ជកម្មពិភពលោក និងអាស៊ាន
- សហការជាមួយអង្គភាពពាក់ព័ន្ធទាំងឡាយ ដើម្បីតាមដាន និងជំរុញការអនុវត្តលទ្ធផលនៃការចរចាឱ្យមានប្រសិទ្ធភាពខ្ពស់ សំដៅការពារផលប្រយោជន៍ពាណិជ្ជកម្មកម្ពុជា
- ចូលរួមដោយផ្ទាល់ និងណែនាំឱ្យមន្ត្រីតំណាង ដែលប្រចាំការនៅស្ថានបេសកកម្មកម្ពុជាប្រចាំអង្គការ

ពាណិជ្ជកម្មពិភពលោក អង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិនានា នៅទីក្រុងហ្សឺណែវ ឱ្យចូលរួមប្រជុំ និងតាមដានរាល់ការវិវឌ្ឍនៃការចរចាពាណិជ្ជកម្ម ដើម្បីរាយការណ៍ជូនថ្នាក់ដឹកនាំក្រសួង និងរៀបចំគោលនយោបាយជូនថ្នាក់ដឹកនាំសម្រាប់ចរចាបន្ត

- ស្រាវជ្រាវ និងប្រមូលផ្តុំព័ត៌មានទាក់ទងនឹងច្រកចូលទីផ្សារ របស់បណ្តាប្រទេសសមាជិកអាស៊ាន ប្រទេសដៃគូរបស់អាស៊ាន និងបណ្តាប្រទេសជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក
- រៀបចំលិខិតបទដ្ឋានបច្ចេកទេស និងច្បាប់ទាក់ទងនឹងវិធានប្រភពដើមទំនិញរបស់កម្ពុជា តាមការតម្រូវរបស់ប្រទេសក្នុងអនុតំបន់ តំបន់ និងក្នុងពិភពលោក
- រៀបចំ និងពិនិត្យឯកសារចេញវិញ្ញាបនបត្រប្រភពដើមទំនិញ សម្រាប់ការនាំចេញទំនិញទៅកាន់ប្រទេសអាស៊ាន និងប្រទេសដៃគូសេដ្ឋកិច្ចរបស់អាស៊ាន
- ធ្វើជាសេនាធិការរបស់ឧត្តមមន្ត្រីសេដ្ឋកិច្ចអាស៊ាន រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន និងរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ក្នុងក្របខ័ណ្ឌដទៃទៀត
- ធ្វើជាលេខាធិការដ្ឋានជាតិ សម្រាប់ការងារអង្គការពាណិជ្ជកម្មពិភពលោក
- សហការជាមួយអង្គភាពពាក់ព័ន្ធ រៀបចំវគ្គបណ្តុះបណ្តាលនានា ដើម្បីលើកកម្ពស់សមត្ថភាពការងារ និងបច្ចេកទេសចរចាពាណិជ្ជកម្ម ដល់មន្ត្រីក្នុងក្រសួង
- សហការជាមួយអង្គភាពពាក់ព័ន្ធ ដើម្បីផ្សព្វផ្សាយលទ្ធផល នៃការចរចាបើកច្រកទីផ្សារទំនិញ សេវាកម្ម និងអំពីវិធានច្បាប់ សន្ធិសញ្ញា និងកិច្ចព្រមព្រៀងនានា ជូនដល់មន្ត្រីមកពីក្រសួង ស្ថាប័ន ខេត្ត ក្រុង និងវិស័យឯកជន តាមរយៈការចុះទៅផ្សព្វផ្សាយដោយផ្ទាល់ និងតាមរយៈគេហទំព័រ
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន។

នាយកដ្ឋានពាណិជ្ជកម្មពហុភាគី ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួន ជាជំនួយការតាមការចាំបាច់។

មាត្រា ១៦.-

នាយកដ្ឋានជំរុញពាណិជ្ជកម្ម មានភារកិច្ចដូចតទៅ ÷

- រៀបចំ និងចូលរួមពិព័រណ៍ពាណិជ្ជកម្មក្នុង និងក្រៅប្រទេសព្រមទាំងធ្វើការណែនាំ និងលើកទឹកចិត្តដល់ការចូលរួមរបស់ផលិតករជាតិ នៅក្នុងកម្មវិធីពិព័រណ៍ក្រៅប្រទេស
- គ្រប់គ្រងមជ្ឈមណ្ឌលពិព័រណ៍ពាណិជ្ជកម្មជាតិខេត្ត ក្រុង និងតំបន់
- សម្របសម្រួល និងលើកទឹកចិត្តដល់ការរៀបចំពិព័រណ៍ពាណិជ្ជកម្មនៅក្នុង និងក្រៅប្រទេស ដែលរៀបចំដោយក្រុមហ៊ុនក្នុងស្រុក និងក្រុមហ៊ុនបរទេស

- ទទួលបន្ទុកជាចំណុចប្រសព្វ សម្រាប់ការងារការិយាល័យពិព័រណ៍អន្តរជាតិ (BIE) និងការងារជាលេខាធិការដ្ឋាន នៃគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំចូលរួមពិព័រណ៍ពិភពលោក និងពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិ
- គ្រប់គ្រងទីផ្សារ និងអនុវត្តគោលនយោបាយពាណិជ្ជកម្មក្នុងស្រុក ដូចជា ៖ បិទស្លាកថ្លៃទំនិញ ត្រួតពិនិត្យស្តុកទំនិញយុទ្ធសាស្ត្រ និងទំនិញចាំបាច់តាមការកំណត់របស់រាជរដ្ឋាភិបាល
- អភិវឌ្ឍទីផ្សារ ៖ រៀបចំយុទ្ធសាស្ត្រ ស្វែងរកទីផ្សារ ស្រាវជ្រាវវិភាគ និងកសាងគោលនយោបាយទីផ្សារក្នុងស្រុក និងជំរុញការនាំចេញ
- ចូលរួមអនុវត្តគោលនយោបាយផលិតផលជាតិ ក្នុងគោលដៅបម្រើទីផ្សារក្នុងស្រុក និងនាំចេញ
- ផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធ ដល់ការងារជំរុញពាណិជ្ជកម្ម និងទីផ្សារក្រៅប្រទេស
- រៀបចំ និងគ្រប់គ្រងគេហទំព័រ សម្រាប់ជំរុញពាណិជ្ជកម្ម
- ចូលរួមរៀបចំគោលនយោបាយអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម
- រៀបចំយុទ្ធសាស្ត្រពាណិជ្ជកម្មក្នុងប្រទេស និងការងារសហប្រតិបត្តិការជាមួយដៃគូពាណិជ្ជកម្ម
- រៀបចំលិខិតបទដ្ឋានច្បាប់គ្រប់គ្រងការងារប្រកួតប្រជែងពាណិជ្ជកម្ម
- ជួយចាត់ចែងកិច្ចសម្រួលពាណិជ្ជកម្ម ៖ ពិគ្រោះយោបល់ការងារពាណិជ្ជកម្ម និងសេវាកម្មពាណិជ្ជកម្មជូនដល់វិស័យឯកជន
- ជួយរៀបចំសភាពាណិជ្ជកម្ម និងជួយណែនាំលើកិច្ចការច្បាប់ និងបច្ចេកទេសទាក់ទងនឹងគោលនយោបាយពាណិជ្ជកម្ម និងសេដ្ឋកិច្ច
- តាមដានការងាររបស់បណ្តាមន្ទីរពាណិជ្ជកម្មខេត្ត ក្រុង លើការចេញលិខិតអនុញ្ញាតធ្វើអាជីវកម្មជូនអាជីវករ សេវាករ ដែលមិនជាប់ពន្ធលើប្រាក់ចំណេញ
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន។

នាយកដ្ឋានជំរុញពាណិជ្ជកម្ម ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួន ជាជំនួយការតាមការចាំបាច់។

មាត្រា ១៧.-

នាយកដ្ឋានផ្តល់ព័ត៌មាន និងផ្ទៀងផ្ទាត់ច្បាប់ មានភារកិច្ច ដូចតទៅ ៖

- ចូលរួមផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ បទប្បញ្ញត្តិ និងលិខិតបទដ្ឋាននានា របស់ព្រះរាជាណាចក្រកម្ពុជា ដែលទាក់ទងនឹងកិច្ចព្រមព្រៀង សន្ធិសញ្ញាពាណិជ្ជកម្មតំបន់ និងពិភពលោក ដែលព្រះរាជាណាចក្រកម្ពុជា ជាសមាជិកហត្ថលេខី ដើម្បីធានានូវភាពស្របគ្នា

- ធ្វើជាលេខាធិការសម្រាប់សម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីជូនដំណឹងទៅលេខាធិការដ្ឋានអាស៊ាន និងលេខាធិការដ្ឋានអង្គការពាណិជ្ជកម្មពិភពលោក អំពីលិខិតបទដ្ឋាន ច្បាប់អនុម័តថ្មី និងធ្វើវិសោធនកម្ម ការជូនដំណឹងផ្សេងទៀត តាមការតម្រូវរបស់អាស៊ាន និងអង្គការពាណិជ្ជកម្មពិភពលោក
- ផ្សព្វផ្សាយលិខិតបទដ្ឋានច្បាប់ដែលបានអនុម័តរួច នៅក្នុងគេហទំព័ររបស់នាយកដ្ឋាន និងរបស់ក្រសួង
- រៀបចំបណ្ណាល័យសម្រាប់រក្សាទុកនូវលិខិតបទដ្ឋាន ច្បាប់របស់ជាតិ និងអន្តរជាតិ ដែលទាក់ទងនឹងការងារសេដ្ឋកិច្ច និងពាណិជ្ជកម្ម ព្រមទាំងធ្វើការផ្សព្វផ្សាយជូនវិស័យឯកជន
- ដើរតួជាមជ្ឈមណ្ឌលសម្របសម្រួលសម្រាប់ទទួល និងផ្តល់ព័ត៌មានទាក់ទងនឹងវិស័យសេវាកម្ម វិស័យពាណិជ្ជកម្ម និងវិស័យផ្សេងទៀតរបស់ព្រះរាជាណាចក្រកម្ពុជា
- ស្រាវជ្រាវ និងប្រមូលឯកសារ លិខិតបទដ្ឋានច្បាប់នានា ដើម្បីចូលរួមដោះស្រាយវិវាទពាណិជ្ជកម្មអន្តរជាតិ
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន ។

នាយកដ្ឋានផ្តល់ពត៌មាន និងផ្ទៀងផ្ទាត់ច្បាប់ ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

មាត្រា ១៨.-

នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ មានភារកិច្ចដូចតទៅ ÷

- ធ្វើជាចំណុចទាក់ទងសម្រាប់សម្របសម្រួលជំនួយទាក់ទងនឹងពាណិជ្ជកម្មជាមួយបណ្តាប្រទេស និងអង្គការអន្តរជាតិ
- ធ្វើសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការពិភាក្សាជាមួយបណ្តាប្រទេស និងអង្គការអន្តរជាតិនានា ដើម្បីរកជំនួយសម្រាប់អភិវឌ្ឍវិស័យពាណិជ្ជកម្ម
- កៀរគរជំនួយបច្ចេកទេស សម្រាប់បណ្តុះបណ្តាលធនធានមនុស្ស និងសម្រាប់ពង្រឹងស្ថាប័ន ក្នុងវិស័យពាណិជ្ជកម្ម
- គ្រប់គ្រងជំនួយបរទេសជាទំនិញ ក្រោមសមត្ថភាពក្រសួងពាណិជ្ជកម្ម តាមការប្រគល់ភារកិច្ចរបស់រាជរដ្ឋាភិបាល
- រៀបចំបញ្ជីព័ត៌មានគ្រប់ជ្រុងជ្រោយ អំពីជំនួយទាក់ទងនឹងពាណិជ្ជកម្ម ដែលព្រះរាជាណាចក្រកម្ពុជាទទួលបាន ព្រមទាំងធ្វើការកែសម្រួលជាប្រចាំជូនក្រសួង
- រៀបចំសូចនាករសម្រាប់តាមដាន អំពីវឌ្ឍនភាពនៃការអនុវត្តគម្រោងជំនួយនានា និងរាយការណ៍ជូនថ្នាក់ដឹកនាំក្រសួងជាប្រចាំ

- ត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាពនៃការអនុវត្តកម្មវិធី និងគម្រោងជំនួយ
- ពិគ្រោះជាមួយដៃគូអភិវឌ្ឍនានា ដើម្បីបង្កើតយន្តការសម្រាប់គ្រប់គ្រងជំនួយតាមការចាំបាច់
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន ។

នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

ជំពូកទី ៨

អគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស

មាត្រា ១៩.-

អគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស មានភារកិច្ចដូចតទៅ ÷

- អនុវត្តរាល់សកម្មភាពរបស់ក្រសួង លើគោលនយោបាយគ្រប់គ្រង ដឹកនាំពាណិជ្ជកម្មក្នុងប្រទេស
- ស្រាវជ្រាវ និងរៀបចំគោលនយោបាយពាណិជ្ជកម្មក្នុងប្រទេស
- ធានាសេរីភាព និងការធ្វើពាណិជ្ជកម្ម ប្រកបដោយសមធម៌របស់ផ្នែកឯកជន ក្នុងសកម្មភាពសេដ្ឋកិច្ច និងពាណិជ្ជកម្ម
- ចូលរួមអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ដើម្បីអភិវឌ្ឍវិស័យឯកជន
- រៀបចំបទដ្ឋានបច្ចេកទេសពាណិជ្ជកម្ម តាមការណែនាំរបស់រដ្ឋមន្ត្រី
- សម្របសម្រួលការងាររបស់ក្រសួង ជាមួយនឹងអង្គភាពចំណុះក្រសួង
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន ។

អគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស ដឹកនាំដោយអគ្គនាយកមួយរូប និងអមដោយអគ្គនាយករងមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

មាត្រា ២០.-

នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ មានភារកិច្ចដូចតទៅ ÷

- ផ្តល់សេវាត្រួតពិនិត្យទំនិញ នាំចេញ នាំចូល រួមជាមួយស្ថាប័នគយ និងរដ្ឋាករ ផ្អែកលើកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ
- ការពារអ្នកប្រើប្រាស់ ធានាគុណភាព សុវត្ថិភាពផលិតផលទំនិញ និងបង្ក្រាបការក្លែងបន្លំ ដោយសហការជាមួយក្រសួងពាក់ព័ន្ធ
- ធ្វើវិញ្ញាបនបត្រកម្ម ចំពោះទំនិញនាំចេញ តាមសំណើរបស់អ្នកស្នើសុំ ដើម្បីបំពេញលក្ខខណ្ឌតម្រូវ

នៃប្រទេសនាំចូល

- ត្រួតពិនិត្យភាពអនុលោមតាមស្តង់ដារជាតិ នូវគុណភាព សុវត្ថិភាពផលិតផលទំនិញ ដែលមានប្រើសញ្ញាស្តង់ដារជាតិ
- សហការត្រួតពិនិត្យជាមុន នូវប្រតិវេទន៍ នៃផលិតផលទំនិញ ឬសេវាទាំងឡាយណាដែលអាចប៉ះពាល់ដល់សុវត្ថិភាព សុខភាព នៃអ្នកប្រើប្រាស់ ឬផលិតកម្ម ឬពាណិជ្ជកម្ម នៃផលិតផលទំនិញ និងសេវាកម្មទាំងនោះ ដែលផ្តល់ដោយស្ថាប័នមានសមត្ថកិច្ច
- ត្រួតពិនិត្យផលិតផលទំនិញ និងសេវា ក្នុងតំណាក់កាលធ្វើចរាចរណ៍ពាណិជ្ជកម្មលើទីផ្សារ
- គ្រប់គ្រងមន្ទីរពិសោធន៍របស់ក្រសួងពាណិជ្ជកម្ម ដើម្បីវិភាគគុណភាពផលិតផលទំនិញ
- ផ្តល់សេវាត្រួតពិនិត្យលក្ខណពាណិជ្ជកម្ម
- ប្រមូលកម្រៃសេវាត្រួតពិនិត្យទំនិញនាំចេញ នាំចូល និងកម្រៃវិភាគគុណភាពទំនិញ
- ជាលេខាធិការដ្ឋាន នៃគណៈកម្មាធិការ Codex ជាតិ
- ជាចំណុចទាក់ទងសម្រាប់ទទួល និងផ្តល់ព័ត៌មានពីអនាម័យ និងភូតគាមអនាម័យ
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន។

នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួន ជាជំនួយការ តាមការចាំបាច់។

មាត្រា ២១.-

នាយកដ្ឋានកម្មសិទ្ធិបញ្ញា មានភារកិច្ចដូចតទៅ ÷

- ជាលេខាធិការដ្ឋាន នៃគណៈកម្មការគ្រប់គ្រងកម្មសិទ្ធិបញ្ញាកម្ពុជា
- សហការ និងជំរុញក្រសួងពាក់ព័ន្ធចងក្រង និងអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា ស្របតាមការសន្យា ចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោករបស់កម្ពុជា
- សហការជាមួយក្រសួងពាក់ព័ន្ធទទួល និងប្រើប្រាស់ជំនួយបច្ចេកទេស ពាក់ព័ន្ធនឹងវិស័យកម្មសិទ្ធិបញ្ញាពីអង្គការអន្តរជាតិ និងប្រទេសនានា
- ទទួលបន្ទុកជាចំណុចកណ្តាល ក្នុងការសម្របសម្រួលកិច្ចសហប្រតិបត្តិការ ទ្វេភាគី ឬពហុភាគី លើវិស័យកម្មសិទ្ធិបញ្ញា ជាមួយបណ្តាប្រទេស និងអង្គការអន្តរជាតិផ្សេងៗ
- សហការផ្សព្វផ្សាយច្បាប់ និងបទប្បញ្ញត្តិនានា និងចំណេះដឹងកម្មសិទ្ធិបញ្ញា ដល់មហាជន ស្ថាប័ន អប់រំ និងមន្ត្រីអនុវត្តច្បាប់
- ទទួលបន្ទុក និងសហការរៀបចំច្បាប់ និងបទប្បញ្ញត្តិ ទាក់ទងនឹងកម្មសិទ្ធិបញ្ញា ដូចខាងក្រោម ÷

+ ម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់

+ ការសម្គាល់ភូមិសាស្ត្រទំនិញ

+ ការការពារព័ត៌មានសម្ងាត់ពាណិជ្ជកម្ម

+ ការផ្ទេរអាជ្ញាប័ណ្ណ និងសិទ្ធិធ្វើអាជីវកម្ម

+ កម្មសិទ្ធិបញ្ញាផ្សេងៗ ទៀត ដែលជាសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្ម ។

- ធ្វើការចុះបញ្ជីម៉ាក និងការសម្គាល់ភូមិសាស្ត្រទំនិញ ព្រមទាំងកត់ត្រាការផ្តល់អាជ្ញាប័ណ្ណ និងការផ្តល់សិទ្ធិធ្វើអាជីវកម្មម៉ាក
- ចេញលិខិតទទួលស្គាល់សិទ្ធិផ្តាច់មុខម៉ាកផលិតផលស្របតាមច្បាប់ និងតាមសំណូមពររបស់ ម្ចាស់ម៉ាកស្របច្បាប់
- សហការជាមួយមន្ទីរពាណិជ្ជកម្មខេត្ត ក្រុង ក្នុងការទទួលពាក្យចុះបញ្ជី និងដោះស្រាយវិវាទ អំពីម៉ាក និងការសម្គាល់ភូមិសាស្ត្រទំនិញ
- ដោះស្រាយវិវាទនានា ទាក់ទងនឹងកម្មសិទ្ធិបញ្ញា ដែលជាសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្ម
- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ច និងស្ថាប័នតុលាការ ដើម្បីបញ្ឈប់ការរំលោភកម្មសិទ្ធិបញ្ញា
- បង្កើត និងគ្រប់គ្រងគេហទំព័រ ដើម្បីផ្សព្វផ្សាយច្បាប់ និងបទប្បញ្ញត្តិនានា ព្រមទាំងទិន្នន័យកម្មសិទ្ធិបញ្ញា ដែលបានចុះបញ្ជីរួច
- ចូលរួមសិក្សាស្រាវជ្រាវកិច្ចព្រមព្រៀង និងអនុសញ្ញាអន្តរជាតិនានា ដែលទាក់ទងនឹងកម្មសិទ្ធិបញ្ញា និងធ្វើការពិចារណាអំពីប្រយោជន៍ជាតិ ក្នុងការចូលជាសមាជិកនៃកិច្ចព្រមព្រៀង ឬអនុសញ្ញាទាំងនោះ
- ជំរុញការធ្វើពាណិជ្ជកម្មកម្មសិទ្ធិបញ្ញា និងការវាយតម្លៃទ្រព្យសម្បត្តិកម្មសិទ្ធិបញ្ញា ដែលជាសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្ម
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន ។

នាយកដ្ឋានកម្មសិទ្ធិបញ្ញា ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

មាត្រា ២២.-

នាយកដ្ឋានស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម មានភារកិច្ចដូចតទៅ ÷

- ស្រាវជ្រាវនយោបាយពាណិជ្ជកម្ម
- រៀបចំធ្វើសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ចាំបាច់សំខាន់ៗ
- ស្រាវជ្រាវ និងធ្វើស្ថិតិពាណិជ្ជកម្ម

- ធ្វើសហប្រតិបត្តិការលើវិស័យស្ថិតិពាណិជ្ជកម្ម ជាមួយបណ្តាប្រទេសក្នុងតំបន់ និងពិភពលោក
- ចងក្រង និងណែនាំអនុវត្ត ដោយឯកភាពតាមចំណាត់ថ្នាក់ព័ត៌មានស្ថិតិពាណិជ្ជកម្ម
- ផ្សព្វផ្សាយទិន្នន័យស្ថិតិពាណិជ្ជកម្ម ស្តីពីស្ថានភាពនៃការវិវត្តលើផ្នែកពាណិជ្ជកម្មក្នុង និងក្រៅប្រទេស
- សិក្សា វិភាគ តាមដានទិន្នន័យថ្លៃទំនិញលើទីផ្សារអន្តរជាតិ
- សិក្សាស្រាវជ្រាវ ប្រមូល និងវិភាគព័ត៌មានតាមលំដាប់ ដើម្បីបង្កើតតារាងនៃការប្រែប្រួលថ្លៃ
- បោះផ្សាយព្រឹត្តិបត្ររបស់ក្រសួង
- ធ្វើគម្រោងបណ្តុះបណ្តាលសមត្ថភាពមន្ត្រីជំនាញ ផ្នែកស្ថិតិពាណិជ្ជកម្មនិងពត៌មានពាណិជ្ជកម្ម ថ្នាក់កណ្តាល រហូតដល់មូលដ្ឋានតាមតម្រូវការការងារ
- ទទួលបន្ទុកជាមជ្ឈមណ្ឌលព័ត៌មានពាណិជ្ជកម្មរបស់ក្រសួង
- គ្រប់គ្រង និងអភិវឌ្ឍបច្ចេកទេសព័ត៌មានវិទ្យា (គ្រប់គ្រងគេហទំព័រ)
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន។

នាយកដ្ឋានស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់។

មាត្រា ២៣.-

នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម មានភារកិច្ចដូចតទៅ ÷

- កាន់កាប់បញ្ជីពាណិជ្ជកម្ម គ្រប់គ្រងទិន្នន័យ ឈ្មោះក្រុមហ៊ុន សហគ្រាស តាមប្រព័ន្ធព័ត៌មានវិទ្យា
- ចុះបញ្ជីពាណិជ្ជកម្ម និងគ្រប់គ្រងសមត្ថភាពសហគ្រាស ក្រុមហ៊ុនពាណិជ្ជកម្ម ដូចមានចែងក្នុងច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម និងគ្រប់គ្រងការចុះបញ្ជីតាមខេត្ត ក្រុង
- រៀបចំលិខិតបទដ្ឋាន ស្តីពីការចុះបញ្ជីពាណិជ្ជកម្ម ការកែប្រែ ការរំលាយក្រុមហ៊ុន និងសហគ្រាសឯកបុគ្គល
- ដោះស្រាយវិវាទ ដែលទាក់ទងដល់ការចុះបញ្ជីពាណិជ្ជកម្ម ការកែប្រែ និងការរំលាយក្រុមហ៊ុន
- ណែនាំតាមដាន និងត្រួតពិនិត្យការអនុវត្តច្បាប់ស្តីពីវិធានពាណិជ្ជកម្ម បញ្ជីពាណិជ្ជកម្ម និងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- គ្រប់គ្រង ពិនិត្យការបំពេញប្រតិវេទន៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុន ដូចមានចែងក្នុងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- ត្រួតពិនិត្យ និងរៀបចំលិខិតបទដ្ឋានដើម្បីលុបឈ្មោះក្រុមហ៊ុនចេញពីបញ្ជីពាណិជ្ជកម្ម
- គ្រប់គ្រងមណ្ឌលឃ្លាំងឯកសារ

- ស្រាវជ្រាវ និងផ្តល់ពតិមានជូនអតិថិជនទាក់ទងនឹងការចុះបញ្ជីពាណិជ្ជកម្ម
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន ។

នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

មាត្រា ២៤.-

នាយកដ្ឋាននីតិកម្ម មានភារកិច្ចដូចតទៅ ÷

- សិក្សា ស្រាវជ្រាវ ឯកសារច្បាប់ជាតិ អន្តរជាតិ និងលិខិតបទដ្ឋាននានា ពាក់ព័ន្ធលើការគ្រប់គ្រងវិស័យពាណិជ្ជកម្ម និងលើកយោបល់ជូនថ្នាក់ដឹកនាំក្រសួង
- រៀបចំ កសាងផែនការច្បាប់ និងលិខិតបទដ្ឋាននានារបស់ក្រសួង
- រៀបចំ តាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋាននានា លើវិស័យពាណិជ្ជកម្ម ដោយធ្វើការទំនាក់ទំនងជាមួយអង្គភាពជំនាញ និងស្ថាប័នអ្នកច្បាប់
- ចងក្រង និងតម្កល់ទុក រាល់ឯកសារច្បាប់ទាំងឡាយពាក់ព័ន្ធលើវិស័យពាណិជ្ជកម្ម និងសន្ធិសញ្ញាដែលទាក់ទងនឹងពាណិជ្ជកម្ម
- ផ្សព្វផ្សាយ និងតាមដានការអនុវត្តច្បាប់ លិខិតបទដ្ឋាននានារបស់វិស័យពាណិជ្ជកម្ម
- ផ្សះផ្សាវិវាទពាណិជ្ជកម្ម
- សហការលើការងារច្បាប់ ជាមួយមជ្ឈមណ្ឌលជាតិ នៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងតុលាការពាណិជ្ជកម្ម ដើម្បីសម្របសម្រួលការអនុវត្តច្បាប់ពាណិជ្ជកម្មឱ្យមានប្រសិទ្ធភាព
- គ្រប់គ្រងការិយាល័យតម្កល់លិខិតជូនដំណឹង និងរៀបចំបែបបទស្តីពីការតម្កល់លិខិតជូនដំណឹង
- គ្រប់គ្រងគេហទំព័ររបស់នាយកដ្ឋាន
- ធ្វើជាអ្នកប្រឹក្សាច្បាប់ពាណិជ្ជកម្មឱ្យក្រសួង និងវិស័យឯកជន
- ទទួលភារកិច្ចពាក់ព័ន្ធផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន ។

នាយកដ្ឋាននីតិកម្ម ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

ជំពូកទី ៩
អង្គភាពមូលដ្ឋាន

មាត្រា ២៥.-

នៅតាមបណ្តាខេត្ត ក្រុង មានមន្ទីរពាណិជ្ជកម្មខេត្ត ក្រុង ដែលទទួលបន្ទុកគ្រប់គ្រង និងអនុវត្តការងារពាណិជ្ជកម្មនៅមូលដ្ឋាន ។

នៅតាមស្រុក ខណ្ឌ មានការិយាល័យពាណិជ្ជកម្ម ដែលទទួលបន្ទុកអនុវត្ត ការងាររបស់ក្រសួង និងបទបញ្ជារបស់មន្ទីរពាណិជ្ជកម្ម ។

ជំពូកទី ១០
សហគ្រាសសាធារណៈ

មាត្រា ២៦.-

អង្គភាពសហគ្រាសសាធារណៈជានីតិបុគ្គល ដែលទទួលបន្ទុកធ្វើការងារតាមជំនាញឯកទេសរបស់ខ្លួនស្របតាមច្បាប់ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ អនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះ ថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រមស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ និងអនុក្រឹត្យលេខ ៧២ អនក្រ.បកចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការបង្កើតក្រុមហ៊ុនហ្គ្រីនត្រេដ ។

ជំពូកទី ១១
អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

មាត្រា ២៧.-

អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមលក្ខខណ្ឌនៃបទបញ្ញាកំណត់ក្នុងអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិកាក្នុងបណ្តាក្រសួង ។

ជំពូកទី ១២
អវសានប្បញ្ញត្តិ

មាត្រា ២៨.-

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងនៅរដ្ឋបាលកណ្តាល ចាប់ពីថ្នាក់ក្រោមនាយកដ្ឋានចុះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

មាត្រា ២៩.-

បទប្បញ្ញត្តិនៃអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៧ អនុក្រឹត្យលេខ ១២៦ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០២ និងបទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៣០.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ៧ ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣០
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧

អង្គការលេខ របស់ក្រសួងពាណិជ្ជកម្ម



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :...១៥៤...អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកែសម្រួលមាត្រា ៧ ថ្មី ជំពូកទី ៥ ថ្មី នៃអនុក្រឹត្យលេខ ១០០ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៥ និងការប្រជាប់បញ្ចូលជំពូកទី ១០ និងទី ១១ នៃអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦០ ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៥/២៦៥ ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥ ស្តីពី វិសោធនកម្មមាត្រា ៤ មាត្រា ១០ និង មាត្រា ១៣ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៩០០ /១៦០ ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់ មីន និង សង្គ្រោះជនពិការដោយសារមីន
- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន
- បានឃើញអនុក្រឹត្យលេខ ១០០ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីវិសោធនកម្មជំពូកទី ៤ ជំពូកទី ៥ ជំពូកទី ៦ ជំពូកទី ៧ ជំពូកទី ៨ ជំពូកទី ១៣ និងជំពូកទី ១៥ នៃអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន
- យោងតាមតម្រូវការការងារចាំបាច់

សម្រេច

មាត្រា មួយ.-

ត្រូវបានកែសំរួលមាត្រា ៧ ថ្មី ជំពូកទី ៥ ថ្មី នៃអនុក្រឹត្យលេខ ១០០ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៥ និងច្របាច់បញ្ចូលជំពូកទី ១០ និងទី ១១ នៃអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន ដូចតទៅ :

មាត្រា ៧.- ថ្មី ពីរ

៧. អគ្គលេខាធិការដ្ឋាន ត្រូវស្ថិតក្រោមការដឹកនាំគ្រប់គ្រងរបស់អគ្គលេខាធិការ ។ ដើម្បី ធានាឱ្យមានប្រសិទ្ធភាព និងសុក្រិតភាពការងារខ្ពស់របស់ "អាជ្ញាធរ" អគ្គលេខាធិការដ្ឋានមាននាយកដ្ឋាន ចំនួន ០៥ (ប្រាំ) សំរាប់បំរើការងារតាមមុខងារដូចតទៅ :

៧.១. នាយកដ្ឋានបទប្បញ្ញត្តិ និងត្រួតពិនិត្យ

៧.២ នាយកដ្ឋានផែនការ សេដ្ឋកិច្ចសង្គម និង គ្រប់គ្រងទិន្នន័យ

៧.៣ នាយកដ្ឋានសង្គ្រោះជនពិការដោយសារមីន

៧.៤ នាយកដ្ឋានទំនាក់ទំនងសាធារណៈ

៧.៥ នាយកដ្ឋានរដ្ឋបាលទូទៅ ។

ជំពូកទី ១០ ថ្មី

មាត្រា ១៥.-ថ្មី

នាយកដ្ឋានរដ្ឋបាលទូទៅ ត្រូវទទួលបន្ទុកការងាររដ្ឋបាល បុគ្គលិក ភស្តុភារ និងហិរញ្ញវត្ថុ មាន ភារកិច្ចចំបងដូចតទៅ :

១៥.១. រៀបចំចាត់ចែងភស្តុភារ និងការទិញសំភារៈតាមតម្រូវការចាំបាច់

១៥.២. រៀបចំតាក់តែង និង តាមដានការអនុវត្តបទបញ្ជាផ្ទៃក្នុង និង បទប្បញ្ញត្តិពាក់ព័ន្ធ

១៥.៣. គាំទ្រផ្នែកលិខិតស្នាម និងភស្តុភារ សំរាប់មន្ត្រី និងថ្នាក់ដឹកនាំ "អាជ្ញាធរមីន" បំពេញបេសកកម្ម នៅក្នុង និងក្រៅប្រទេស

១៥.៤. គ្រប់គ្រងរាល់លិខិតបទដ្ឋាន និងឯកសារចេញ-ចូល

១៥.៥. រៀបចំនិងធ្វើការជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យាតាមលក្ខណៈវិនិច្ឆ័យប្រកបដោយ តម្លាភាព និង អនុលោមទៅតាមច្បាប់ និងបទប្បញ្ញត្តិនានារបស់រាជរដ្ឋាភិបាល

១៥.៦. រៀបចំគំរោងថវិកា និង អនុវត្តការប្រើប្រាស់ថវិកា

១៥.៧. តាមដានការអនុវត្តបទប្បញ្ញត្តិហិរញ្ញវត្ថុរបស់ប្រតិបត្តិករសកម្មភាពមីនទាំងអស់

១៥.៨. ចេញចំណាយសាច់ប្រាក់ តាមការបញ្ជារបស់ថ្នាក់ដឹកនាំ "អាជ្ញាធរមីន"

១៥.៩. រៀបចំ និង បញ្ជាក់និយ័តភាពគណនេយ្យប្រចាំឆមាស និង ប្រចាំឆ្នាំ

១៥.១០ធ្វើរបាយការណ៍លំអិតពីចំណូល-ចំណាយ ដោយភ្ជាប់ជាមួយនូវតារាងសមតុល្យរៀងរាល់ខែជូនថ្នាក់ដឹកនាំ "អាជ្ញាធរមីន" ។

មាត្រា ពីរ.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា បី.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួនឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា បី
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ប្រតិទិនឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ ២០០៨

រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា.
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់រដ្ឋធម្មនុញ្ញបន្ថែមសំដៅ ធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ.
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា.
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី.
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០៨០៥/៣៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការកែសម្រួល គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ទៅជា គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ។
- បានឃើញ សេចក្តីសំរេចរបស់ក្រុមប្រឹក្សារាជសម្បត្តិ លេខ គរស/សសរ/ ១០០៤/០០១ ចុះថ្ងៃ ១៤ ខែ តុលា ឆ្នាំ ២០០៤ ស្តីពីការជ្រើសរើស ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា.
- យោងអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការកំណត់ពេលវេលាបំពេញការងារប្រចាំសប្តាហ៍របស់មន្ត្រីរាជការស៊ីវិល ក្នុងព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ

ស ម្រេ ច

មាត្រា ១.-

អនុញ្ញាតឱ្យមន្ត្រីរាជការ និយោជិត កម្មករ នៃព្រះរាជាណាចក្រកម្ពុជា បានឈប់ សម្រាកការងារ ឆ្នាំ ២០០៨ តាមប្រតិទិន ដូចខាងក្រោម :

- ថ្ងៃទី ០១	មករា	ទិវាចូលឆ្នាំសកល	សម្រាក ០១ ថ្ងៃ

- ថ្ងៃទី ០៧	មករា	ទិវាជ័យជំនះលើរបបប្រល័យពូជសាសន៍	សម្រាក ០១ ថ្ងៃ
- ថ្ងៃទី ២១	កុម្ភៈ	ពិធីបុណ្យមាឃបូជា	សម្រាក ០១ ថ្ងៃ
- ថ្ងៃទី ០៨	មីនា	ទិវានារីអន្តរជាតិ	សម្រាក ០១ ថ្ងៃ
- ថ្ងៃទី ១៣-១៤-១៥	មេសា	ពិធីបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ	សម្រាក ០៣ ថ្ងៃ
- ថ្ងៃទី ០១	ឧសភា	ទិវាពលកម្មអន្តរជាតិ	សម្រាក ០១ ថ្ងៃ
- ថ្ងៃទី ១៣-១៤-១៥	ឧសភា	ព្រះរាជពិធីបុណ្យចម្រើនព្រះជន្មព្រះករុណាព្រះបាទសម្តេច **ព្រះបរមនាថ នរោត្តម សីហមុនី**	សម្រាក ០៣ ថ្ងៃ
- ថ្ងៃទី ១៩	ឧសភា	ពិធីបុណ្យវិសាខបូជា	សម្រាក ០១ ថ្ងៃ
- ថ្ងៃទី ២៣	ឧសភា	ព្រះរាជពិធីច្រត់ព្រះនង្គ័ល	សម្រាក ០១ ថ្ងៃ
- ថ្ងៃទី ១៨	មិថុនា	ព្រះរាជពិធីបុណ្យចម្រើនព្រះជន្មសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតា **នរោត្តម មុនិនាថ សីហនុ**	សម្រាក ០១ ថ្ងៃ
- ថ្ងៃទី ២៤	កញ្ញា	ទិវាប្រកាសរដ្ឋធម្មនុញ្ញ	សម្រាក ០១ ថ្ងៃ
- ថ្ងៃទី ២៨-២៩-៣០	កញ្ញា	ពិធីបុណ្យភ្ជុំបិណ្ឌ	សម្រាក ០៣ ថ្ងៃ
- ថ្ងៃទី ២៩	តុលា	ព្រះរាជពិធីគ្រងរាជសម្បត្តិរបស់ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា	សម្រាក ០១ ថ្ងៃ
- ថ្ងៃទី ៣១	តុលា	ព្រះរាជពិធីបុណ្យចម្រើនព្រះជន្មព្រះវររាជបិតា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ**	សម្រាក ០១ ថ្ងៃ
- ថ្ងៃទី ០៩	វិច្ឆិកា	ពិធីបុណ្យឯករាជ្យជាតិ	សម្រាក ០១ ថ្ងៃ
- ថ្ងៃទី ១១-១២-១៣	វិច្ឆិកា	ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក	សម្រាក ០៣ ថ្ងៃ
- ថ្ងៃទី ១០	ធ្នូ	ទិវាសិទ្ធិមនុស្សអន្តរជាតិ	សម្រាក ០១ ថ្ងៃ

មាត្រា ២.-

ពេលវេលាឈប់សម្រាកទាំងឡាយណាដែលត្រូវចំថ្ងៃណាមួយនៃថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ (សៅរ៍ ឬ អាទិត្យ) ត្រូវបានឱ្យឈប់ចំនួន ០១ថ្ងៃ នៃថ្ងៃបន្ទាប់ជាបន្ថែមទៀត ។ ប៉ុន្តែ ក្នុងករណីត្រូវចំទាំងពីរថ្ងៃជាប់គ្នា គឺទាំងថ្ងៃសៅរ៍ ទាំងថ្ងៃអាទិត្យនោះ ចំនួនថ្ងៃបន្ទាប់ដែលត្រូវអនុញ្ញាតអោយឈប់សម្រាកបន្ថែមជាជំនួស គឺឈប់ចំនួន ០១ ថ្ងៃតែប៉ុណ្ណោះ ។

មាត្រា ៣.-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជា និរាករណ៍ ។

មាត្រា ៤.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន និងអភិបាលខេត្ត-ក្រុង ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែសីហា ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៧៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ នស ៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ និងប្រកាសលេខ ១៤០១ សហវ.ប្រក.ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៧១ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សម្រេច

មាត្រា១: ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ៨.២៨០ លានរៀល (ប្រាំបីពាន់ ពីររយប៉ែតសិបលានរៀលគត់) ពីជំពូក ៦៤ (បន្ទុកបុគ្គលិក) មកជំពូក ៦០ (ការទិញ) ចំនួន ៨.០៤០ លានរៀល (ប្រាំបីពាន់ សែសិបលានរៀល) និង មកជំពូក ៦៥ (ឧបត្ថម្ភកធន និង ជំនួយសង្គម) ចំនួន ២៤០ លានរៀល (ពីររយសែសិបលានរៀល) ជូនក្រសួងការពារជាតិ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។

មាត្រា២: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ទូទាត់សងថ្លៃផ្គត់ផ្គង់អង្ករ ឆ្នាំ ២០០៧ ជូនកងយោធពលខេមរៈភូមិន្ទ និង ប្រាក់របបអាហារអ្នកជំងឺសំរាកពេទ្យ ។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៤១ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ** ជូនដល់លោកគ្រូ អ្នកគ្រូ ចំនួន៨៧រូប នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដែលមានស្នាដៃល្អក្នុងការសំដែង និងបង្ហាត់បង្រៀនសិស្ស និស្សិត រួមចំណែក ក្នុងការលើកស្ទួយវិស័យសិល្បៈវប្បធម៌ជាតិ ដូចមានរាយនាមខាងក្រោម :-

១-លោកស្រី	**រស់**	**គង់**	គ្រូរបាំបុរាណ	នៃ សាលាមធ្យមវិចិត្រសិល្បៈ
២-លោកស្រី	**សុត**	**សំអុន**	គ្រូរបាំបុរាណ	នៃ សាលាមធ្យមវិចិត្រសិល្បៈ
៣-លោក	**ផង់**	**ចំរើន**	គ្រូរបាំ	នៃ សាលាមធ្យមវិចិត្រសិល្បៈ
៤-លោកស្រី	**ណេវ**	**សីសុភាព**	គ្រូចម្រៀងរបាំបុរាណ	នៃ សាលាមធ្យមវិចិត្រសិល្បៈ
៥-លោក	**ពុំ**	**ម៉ុនចំន្ទរ័ត្ន**	គ្រូរបាំ	នៃ សាលាមធ្យមវិចិត្រសិល្បៈ
៦-លោកស្រី	**គីម**	**សុផន**	គ្រូរបាំ	នៃ សាលាមធ្យមវិចិត្រសិល្បៈ
៧-លោកស្រី	**ផន**	**ឆួរ៉េន**	គ្រូរបាំ	នៃ សាលាមធ្យមវិចិត្រសិល្បៈ
៨-លោក	**យ៉ាន់**	**ប៊ូរិន**	គ្រូរបាំ	នៃ សាលាមធ្យមវិចិត្រសិល្បៈ
៩-លោកស្រី	**ហឿង**	**ណៃរតន់**	គ្រូរបាំ	នៃ សាលាមធ្យមវិចិត្រសិល្បៈ
១០-លោកស្រី	**ឱម**	**យុទណ្ណា**	គ្រូរបាំ	នៃ សាលាមធ្យមវិចិត្រសិល្បៈ
១១-លោកស្រី	**ហឿង**	**ណៃរតូ**	គ្រូរបាំ	នៃ សាលាមធ្យមវិចិត្រសិល្បៈ

១២-លោកស្រី	កៅ	ទ៉ាន់ចាន់	គ្រូរបាំ	នៃ សាលាមធ្យមវិចិត្រសិល្បៈ
១៣-លោកស្រី	ឆន់	សាទ៉ាង	គ្រូរបាំ	នៃ សាលាមធ្យមវិចិត្រសិល្បៈ
១៤-លោកស្រី	ម៉ែន	សុខឃួន	គ្រូរបាំ	នៃ សាលាមធ្យមវិចិត្រសិល្បៈ
១៥-លោកស្រី	ឈឹម	សុខា	គ្រូរបាំ	នៃ សាលាមធ្យមវិចិត្រសិល្បៈ
១៦-លោក	ឡុយ	ប្រសិទ្ធ	គ្រូរបាំ	នៃ សាលាមធ្យមវិចិត្រសិល្បៈ
១៧-លោក	ម៉ៅ	ភឿង	គ្រូភ្លេងបុរាណ	នៃ សាលាមធ្យមវិចិត្រសិល្បៈ
១៨-លោក	ង៉ី	គង់	គ្រូភ្លេងបុរាណ	នៃ សាលាមធ្យមវិចិត្រសិល្បៈ
១៩-លោក	អ៊ុំ	នាង	គ្រូភ្លេងបុរាណ	នៃ សាលាមធ្យមវិចិត្រសិល្បៈ
២០-លោក	ចាវ	មុយថូ	គ្រូភ្លេង	នៃ សាលាមធ្យមវិចិត្រសិល្បៈ
២១-លោក	សុខ	ថុល	គ្រូភ្លេង	នៃ សាលាមធ្យមវិចិត្រសិល្បៈ
២២-លោក	ម៉ក់	សុខ	គ្រូរបាំស្វា	នៃ សាលាមធ្យមវិចិត្រសិល្បៈ
២៣-លោក	ញឹម	ស៊ិន	គ្រូរបាំស្វា	នៃ សាលាមធ្យមវិចិត្រសិល្បៈ
២៤-លោក	យិត	សារិន	គ្រូរបាំខោល	នៃ សាលាមធ្យមវិចិត្រសិល្បៈ
២៥-លោក	ម៉ូ	ឡេង	គ្រូភ្លេងកុងត្រីបាស់	នៃ សាលាមធ្យមវិចិត្រសិល្បៈ
២៦-លោក	ទ្រឿង	ព្រួន	គ្រូភ្លេងពិណពាទ្យ	នៃ សាលាមធ្យមវិចិត្រសិល្បៈ
២៧-លោក	សាន	គីមស្វួ	គ្រូភ្លេងបុរាណ	នៃ សាលាមធ្យមវិចិត្រសិល្បៈ
២៨-លោក	ស៊ិន	ចាន់ថន	គ្រូគំនូរបុរាណ	នៃ សាលាមធ្យមវិចិត្រសិល្បៈ
២៩-លោក	សែម	សំយោល	គ្រូគំនូរផ្សាយ	នៃ សាលាមធ្យមវិចិត្រសិល្បៈ
៣០-លោក	ចាន់	ឡៃហេង	គ្រូសិល្បៈសូនរូប	នៃ សាលាមធ្យមវិចិត្រសិល្បៈ
៣១-លោក	ថោង	សុផន	គ្រូសិល្បៈសូនរូប	នៃ សាលាមធ្យមវិចិត្រសិល្បៈ
៣២-លោក	ឆឹង	ស្រ៊ាង	គ្រូពុម្ពមូលដ្ឋាន	នៃ សាលាមធ្យមវិចិត្រសិល្បៈ
៣៣-លោក	ឆៅ	ឡេង	គ្រូសិល្បៈសូនរូប	នៃ សាលាមធ្យមវិចិត្រសិល្បៈ
៣៤-លោកស្រី	កែវ	នាវ	គ្រូសិល្បៈសូនរូប	នៃ សាលាមធ្យមវិចិត្រសិល្បៈ
៣៥-លោកស្រី	ប្រាង	សុន	គ្រូសិល្បៈសូនរូប	នៃ សាលាមធ្យមវិចិត្រសិល្បៈ
៣៦-លោក	ម៉ម	ស៊ីណា	គ្រូសិល្បៈសូនរូប	នៃ សាលាមធ្យមវិចិត្រសិល្បៈ
៣៧-លោក	ជេត	ចន	គ្រូសិល្បៈសូនរូប	នៃ សាលាមធ្យមវិចិត្រសិល្បៈ
៣៨-លោកស្រី	ដួង	សារ៉េ	គ្រូសិល្បៈសូនរូប	នៃ សាលាមធ្យមវិចិត្រសិល្បៈ
៣៩-លោក	ស្រៀង	អ៊ី	គ្រូចម្លាក់ឈើ	នៃ សាលាមធ្យមវិចិត្រសិល្បៈ
៤០-លោក	អ៊ុច	សុខខន	គ្រូល្ខោននិយាយ	នៃ សាលាមធ្យមវិចិត្រសិល្បៈ
៤១-លោក	អៀ	សុខន	គ្រូល្ខោននិយាយ	នៃ សាលាមធ្យមវិចិត្រសិល្បៈ
៤២-លោកស្រី	ឆិត្យ	សារិន	គ្រូល្ខោន	នៃ សាលាមធ្យមវិចិត្រសិល្បៈ
៤៣-លោកស្រី	ហាក្យ	ស៊ីធឿន	គ្រូល្ខោន	នៃ សាលាមធ្យមវិចិត្រសិល្បៈ
៤៤-លោក	ចេង	គីយាន	គ្រូល្ខោនបាសាក់	នៃ សាលាមធ្យមវិចិត្រសិល្បៈ

៤៥-លោកស្រី	សេង	សុគន្ធារី	គ្រូចំណេះទូទៅ	នៃ សាលាមធ្យមវិចិត្រសិល្បៈ
៤៦-លោក	ខាវ	ហុក	គ្រូចំណេះទូទៅ	នៃ សាលាមធ្យមវិចិត្រសិល្បៈ
៤៧-លោក	ឃន	យ៉េយ	គ្រូចំណេះទូទៅ	នៃ សាលាមធ្យមវិចិត្រសិល្បៈ
៤៨-លោកស្រី	ម៉ៅ	សុភាព	គ្រូចំណេះទូទៅ	នៃ សាលាមធ្យមវិចិត្រសិល្បៈ
៤៩-លោក	យឹម	សាំង	គ្រូខ្លុយ	នៃ សាលាមធ្យមវិចិត្រសិល្បៈ
៥០-លោក	លួន	សារី	គ្រូល្ខោននិយាយ	នៃ សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
៥១-លោកស្រី	សរ	សារឿន	គ្រូរបាំបុរាណ	នៃ នាយកដ្ឋានសិល្បៈទស្សនីយភាព
៥២-លោកស្រី	ឯម	ឆាយ	គ្រូរបាំបុរាណ	នៃ នាយកដ្ឋានសិល្បៈទស្សនីយភាព
៥៣-លោកស្រី	ដួង	ម៉ារី	គ្រូចម្រៀងរបាំបុរាណ	នៃ នាយកដ្ឋានសិល្បៈទស្សនីយភាព
៥៤-លោកស្រី	ណារ	គុន	គ្រូរបាំបុរាណ	នៃ នាយកដ្ឋានសិល្បៈទស្សនីយភាព
៥៥-លោកស្រី	ស៊ិន	សាម៉ាដឺកឆូ	គ្រូចម្រៀងរបាំបុរាណ	នៃ នាយកដ្ឋានសិល្បៈទស្សនីយភាព
៥៦-លោកស្រី	ស៊ឹម	មន្ថា	គ្រូរបាំបុរាណ	នៃ នាយកដ្ឋានសិល្បៈទស្សនីយភាព
៥៧-លោកស្រី	ទេព	ម៉ារី	គ្រូភ្លេងបុរាណ	នៃ នាយកដ្ឋានសិល្បៈទស្សនីយភាព
៥៨-លោក	ឆាំ	ស៊ុន	គ្រូភ្លេងរបាំ	នៃ នាយកដ្ឋានសិល្បៈទស្សនីយភាព
៥៩-លោកស្រី	ឃួន	ណារី	គ្រូរបាំប្រពៃណី	នៃ នាយកដ្ឋានសិល្បៈទស្សនីយភាព
៦០-លោក	នូ	សាត	ភ្លេងប្រពៃណី	នៃ នាយកដ្ឋានសិល្បៈទស្សនីយភាព
៦១-លោក	អ៊ិប	ខា	គ្រូភ្លេងប្រពៃណី	នៃ នាយកដ្ឋានសិល្បៈទស្សនីយភាព
៦២-លោក	ផ្លុង	មឿក	គ្រូអាយ៉ៃ	នៃ នាយកដ្ឋានសិល្បៈទស្សនីយភាព
៦៣-លោក	ទឹង	ទ៊ាន់	គ្រូអាយ៉ៃ	នៃ នាយកដ្ឋានសិល្បៈទស្សនីយភាព
៦៤-លោក	អ៊ុក	សំអឿន	គ្រូអាយ៉ៃ	នៃ នាយកដ្ឋានសិល្បៈទស្សនីយភាព
៦៥-លោក	ប្រាក់	ឌន	គ្រូភ្លេងអាយ៉ៃ	នៃ នាយកដ្ឋានសិល្បៈទស្សនីយភាព
៦៦-លោក	ដួង	យាន	គ្រូអាយ៉ៃ	នៃ នាយកដ្ឋានសិល្បៈទស្សនីយភាព
៦៧-លោកស្រី	សួន	សំអឿន	គ្រូអាយ៉ៃ	នៃ នាយកដ្ឋានសិល្បៈទស្សនីយភាព
៦៨-លោក	គង់	ណៃ	គ្រូចាប៉ីដងវែង	នៃ នាយកដ្ឋានសិល្បៈទស្សនីយភាព
៦៩-លោក	ហែម	ផៃ	គ្រូល្ខោន	នៃ នាយកដ្ឋានសិល្បៈទស្សនីយភាព
៧០-លោក	ព្រឹង	សាឃន	គ្រូល្ខោន	នៃ នាយកដ្ឋានសិល្បៈទស្សនីយភាព
៧១-លោក	ម៉ុក	សារ៉ាន់	គ្រូល្ខោនខោល	នៃ នាយកដ្ឋានសិល្បៈទស្សនីយភាព
៧២-លោក	កែវ	សុន្ទីវ៉េត	គ្រូល្ខោនខោល	នៃ នាយកដ្ឋានសិល្បៈទស្សនីយភាព
៧៣-លោកស្រី	នូ	សណ្តាប់	គ្រូល្ខោននិយាយ	នៃ នាយកដ្ឋានសិល្បៈទស្សនីយភាព
៧៤-លោក	ចិន្ត	នាគ	គ្រូល្ខោននិយាយ	នៃ នាយកដ្ឋានសិល្បៈទស្សនីយភាព
៧៥-លោក	ទង់	ជុន	គ្រូល្ខោននិយាយ	នៃ នាយកដ្ឋានសិល្បៈទស្សនីយភាព
៧៦-លោក	ព្រំ	ឡេង	គ្រូល្ខោននិយាយ	នៃ នាយកដ្ឋានសិល្បៈទស្សនីយភាព

៧៧-លោក	ឯល	ម៉ុនណា	អ្នកនិពន្ធបទភ្លេង	នៃ នាយកដ្ឋានសិល្បៈទស្សនីយភាព
៧៨-លោក	សេង	សំអាន	អ្នកនិពន្ធ	នៃ នាយកដ្ឋានសិល្បៈទស្សនីយភាព
៧៩-លោក	ម៉ុត	ឡឿន	គ្រូតន្ត្រី	នៃ នាយកដ្ឋានសិល្បៈទស្សនីយភាព
៨០-លោកស្រី	ដេង	សុផារ៉ា	គ្រូតន្ត្រី	នៃ នាយកដ្ឋានសិល្បៈទស្សនីយភាព
៨១-លោកស្រី	ឈឹម	សុខៃ	គ្រូតន្ត្រី	នៃ នាយកដ្ឋានសិល្បៈទស្សនីយភាព
៨២-លោកស្រី	ឈឹម	សុខាំ	គ្រូតន្ត្រី	នៃ នាយកដ្ឋានសិល្បៈទស្សនីយភាព
៨៣-លោក	ឈុន	ឆន	គ្រូជាងទង	នៃ នាយកដ្ឋានសិល្បៈទស្សនីយភាព

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/៖

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួល :

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា ១ និង មាត្រា ២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៧៧ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនដល់លោកគ្រូ អ្នកគ្រូ ចំនួន១៩រូប នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដែលមានស្នាដៃល្អក្នុងការសំដែងនិងបង្ហាត់បង្រៀនសិស្ស និស្សិត រួមចំណែកក្នុងការលើកស្ទួយវិស័យសិល្បៈ វប្បធម៌ជាតិ ដូចមានរាយនាមខាងក្រោម :-

១-លោក	**កែវ**	**ម៉ាលីស**	គ្រូរបាំ	នៃ សាលាមធ្យមវិចិត្រសិល្បៈ
២-លោកស្រី	**ទន្ស**	**មេត្រី**	គ្រូរបាំ	នៃ សាលាមធ្យមវិចិត្រសិល្បៈ
៣-លោក	**នែម**	**សុខ**	គ្រូភ្លេងបុរាណ	នៃ សាលាមធ្យមវិចិត្រសិល្បៈ
៤-លោក	**សឿង**	**ខួនលី**	គ្រូភ្លេងបុរាណ	នៃ សាលាមធ្យមវិចិត្រសិល្បៈ
៥-លោក	**ភាច**	**ឡឿង**	គ្រូភ្លេងបុរាណ	នៃ សាលាមធ្យមវិចិត្រសិល្បៈ
៦-លោក	**សយ**	**សារេត**	គ្រូភ្លេងប្រពៃណី	នៃ សាលាមធ្យមវិចិត្រសិល្បៈ
៧-លោក	**មិន**	**សំមឹន**	គ្រូភ្លេង	នៃ សាលាមធ្យមវិចិត្រសិល្បៈ
៨-លោក	**សេក**	**សាវុធ**	គ្រូល្ខោន	នៃ សាលាមធ្យមវិចិត្រសិល្បៈ
៩-លោក	**យិន**	**យាន**	គ្រូល្ខោន	នៃ សាលាមធ្យមវិចិត្រសិល្បៈ
១០-លោក	**ម៉ែន**	**ឈាវស្រុខ**	គ្រូសិល្បៈសូនរូប	នៃ សាលាមធ្យមវិចិត្រសិល្បៈ
១១-លោកស្រី	**គង់**	**ជាឡា**	គ្រូចំណេះទូទៅ	នៃ សាលាមធ្យមវិចិត្រសិល្បៈ

១២-លោកស្រី	សៀង ទៀង	គ្រូចំណេះទូទៅ	នៃ សាលាមធ្យមវិចិត្រសិល្បៈ
១៣-លោក	ស៊ុំ ស៊ីណារ៉ា	គ្រូចំណេះទូទៅ	នៃ សាលាមធ្យមវិចិត្រសិល្បៈ
១៤-លោកស្រី	សុទ្ធ សុម៉ាលី	គ្រូរបាំបុរាណ	នៃ សាលាមធ្យមវិចិត្រសិល្បៈ
១៥-លោក	ឈុប សំអឿន	គ្រូរបាំបុរាណ	នៃ នាយកដ្ឋានសិល្បៈទស្សនីយភាព
១៦-លោក	ស្មើន ចំរើន	គ្រូរបាំប្រពៃណី	នៃ នាយកដ្ឋានសិល្បៈទស្សនីយភាព
១៧-លោក	សូ ម៉ុនធឿន	គ្រូរបាំប្រពៃណី	នៃ នាយកដ្ឋានសិល្បៈទស្សនីយភាព
១៨-លោក	មាស សាឯម	គ្រូភ្លេងបុរាណ	នៃ នាយកដ្ឋានសិល្បៈទស្សនីយភាព
១៩-លោក	សេក សឿន	គ្រូតន្ត្រីត្រុំប៉ែត	នៃ នាយកដ្ឋានសិល្បៈទស្សនីយភាព

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ៣ [illegible] ខែ [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា ១ និង មាត្រា ២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧២៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនជប៉ុន ចំនួន ០២ រូប ដែលបានផ្តល់ថវិកាចំនួន ៥៤.២១២.៦៤ ដុល្លារអាមេរិក ក្នុងការជួយកសាងអាគារសិក្សា ០១ ខ្នង មាន ០៥ បន្ទប់ ទិញម៉ាស៊ីនថតចំលង ០១ គ្រឿង ទិញទូដាក់សម្ភារៈឧបទេស ព្រមទាំងចាក់ដីបំពេញទីធ្លានៅមុខអាគារ និងបានផ្តល់អាហារូបករណ៍ ដល់សិស្សវិទ្យាល័យមិត្តភាពខ្មែរ-ជប៉ុន ចំនួន ២២ រូប ឱ្យមករៀននៅមហាវិទ្យាល័យនានា នៅទីក្រុងភ្នំពេញ ដូចមានរាយនាមខាងក្រោម :

១- Mr. Raita Hirai — President of Rakuda Methode

២- Professor, Fujita Satoshi — Chairman of Friends of Cambodia-Japan Friendship High School ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និងមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧២៤ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់ភារកិច្ចជូនមន្ត្រីរាជការចំនួន ០២រូប នៅខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម :

១- លោក **កុយ សំអុល** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ៤ ជាអភិបាលរងខេត្ត

២- លោក **ចោទ ឆៀម** ឋានន្តរសក្តិ នាយក្រមការ ថ្នាក់លេខ ៦ ជាអភិបាលស្រុកកៀនស្វាយ ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៣ (ដើម្បីអនុវត្ត)*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៧២៥ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការតែងតាំង ផ្ទេរសម្រួលភារកិច្ច និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រង ការអនុវត្ត ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងមន្ត្រីរាជការក្រសួងយុត្តិធម៌ដូចខាងក្រោម :

១-លោក **កែច សុផល** ជាអគ្គនាយករងនៃអគ្គនាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍន៍លើវិស័យយុត្តិធម៌ ។

២-លោក **ម៉ិនយ៉េ ណារិន** ជាអគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ។

មាត្រា ២ : ត្រូវបានផ្ទេរសម្រួលភារកិច្ច លោក **ស៊ុំ ឫទ្ធីសែន** ពីប្រធាននាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាលជាប្រធាននាយកដ្ឋានកិច្ចការបុគ្គលិក ។

